ក្រសួងការបរទេសនៃសហព័ន្ធរុស្ស៊ី

# សៀវភៅស

## ស្ដីអំពី

## ការរំលោភសិទ្ធិមនុស្ស និង នីតិរដ្ឋនៅក្នុងប្រទេសអ៊ុយក្រែន

(កក្កដា-វិច្ឆិកា ២០១៤)

**«ការបកប្រែក្រោមជំនួយឧបត្ថម្ភហិរញ្ញវត្ថុពីក្រុមហ៊ុន RCBCC Co. Ltd»**

ទីក្រុងម៉ូស្គូ
ខែ វិច្ឆិកា ឆ្នាំ ២០១៤

តារាងមាតិកា

សេចក្តីផ្តើម
ការរំលោភសិទ្ធិរស់រានមានជីវិត សេរីភាព និង សន្តិសុខ
ការរឹតបន្តឹងសេរីភាពសារព័ត៌មាន និង សកម្មភាពអ្នកសារព័ត៌មាន
ការរំលោភសិទ្ធិប្រមូលផ្តុំ និង សមាគម ការបោះឆ្នោតដោយសេរី ការបំភិតបំភ័យ និង ការចាប់ដំរិតអ្នកនយោបាយប្រឆាំង
ការរំលោភសិទ្ធិក្រុមមនុស្សភាគតិច ការរើសអើង ការស្អប់ជនបរទេស និង ជាតិនិយមជ្រុល
ការរំលោភសិទ្ធិសេរីភាពនៃការគិត មនសិការ និង សាសនា
ជនផ្លាស់ប្តូរទីកន្លែងក្នុងប្រទេស និង ជនភៀសខ្លួន
ការរំលោភសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌
ការសន្និដ្ឋាន

# សេចក្តីផ្តើម

ចាប់តាំងពីការបោះពុម្ព «សៀវភៅស» លើកទីពីរ ស្ថានភាពនៃការមិនអើពើអំពីសិទ្ធិមនុស្ស និងនីតិរដ្ឋនៅក្នុងប្រទេសអ៊ុយក្រែនមានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើងៗ ។

ក្នុងរយៈកាលនៃការតាក់តែងសៀវភៅនេះ( ពីខែ កក្កដា ដល់ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ) ក្រុមកងកម្លាំងយោធា និងក្រុមអ្នកជាតិនិយមជ្រុលអ៊ុយក្រែនដែលប្រដាប់ដោយអាវុធ បានរំលោភបំពានយ៉ាងគឃ្លើនក្នុងទ្រង់ទ្រាយធំ និង ដោយចេតនាទៅលើច្បាប់អន្តរជាតិ សិទ្ធិមនុស្ស និង នីតិរដ្ឋ។

ក្នុងខណៈពេលនៃការបោះពុម្ពផ្សាយសៀវភៅ ក្រុមអង្គការឯកទេសអន្តរជាតិបានឱ្យដឹងថាតាមរយៈការគណនាក្នុងកំឡុងនៃវិបត្តិអ៊ុយក្រែនមានមនុស្សចំនួនជាង៤០០០នាក់ត្រូវបានសម្លាប់ក្នុងប្រតិបត្តិការ «ប្រឆាំងភេរវកម្ម» និង ជាង ៩០០០ នាក់បានរងរបួស ដែលក្នុងនោះរួមមានស្ត្រី កុមារ មនុស្សចាស់ជរានិង ជនពិការ។គួរអោយកត់សម្គាល់ថា ចំនួនអ្នកស្លាប់ពិតប្រាកដនឹងអាចកើនឡើងខ្ពស់ជាងនេះ។នៅក្នុងបណ្តាតំបន់ដែលប៉ះពាល់ដោយជម្លោះ មានប្រជាជនជិត២.៥លាននាក់កំពុងបន្តរស់នៅទីនោះ។ ចំនួនអ្នករត់គេចពីតំបន់ជម្លោះក្នុងប្រទេសអ៊ុយក្រែននៅត្រឹមខែតុលាមានចំនួនជិត ៤១៥ ពាន់នាក់។តាមទិន្នន័យរបស់ភ្នាក់ងារអន្តោប្រវេសន៏សហព័ន្ធបានអោយដឹងថាចំនួនសរុបប្រជាជនអ៊ុយក្រែនដែលបានភៀសខ្លួនមកជ្រកកោននៅប្រទេសរុស្ស៊ីបានកើនឡើងរហូតដល់ ៨៣០ពាន់នាក់ (បណ្តាជនរុស្ស៊ីបានផ្តល់ជម្រកដល់ជនភៀសខ្លួនអ៊ុយក្រែនជិត ៤៤៤០០០នាក់)។

ចំនួននៃជនភៀសខ្លួននឹងអាចកើនឡើងកាន់តែខ្លាំង ដោយយោលទៅលើសន្ទុះជាតិនិយមជ្រុលមានលក្ខណៈបង្កអរិភាពក្នុងចំណោមអ្នកនយោបាយអ៊ុយក្រែន ដែលបន្លឺចេញពីមាត់របស់ពួកគេនូវភាពស្អប់ខ្ពើមមនុស្សជាតិ ការគាំទ្រសកម្មភាពណាស៊ីបែបថ្មី (Neo-Nazi) និងការដើរក្បួនដោយក្នុងដៃមានកាន់ចន្លុះភ្លើងរាតត្បាតពេញក្រុងនានានៃប្រទេសអ៊ុយក្រែន ។

រដ្ឋអំណាចអ៊ុយក្រែនបានប្រើប្រាស់មិនត្រឹមតែអាវុធធុនធ្ងន់និងយន្តហោះចម្បាំងប្រឆាំងនឹង ជនស៊ីវិលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រើប្រាស់នូវអាវុធសាហាវព្រៃផ្សៃផ្សេងទៀតដូចជា អាវុធធេះ គ្រាប់បែកចង្កោម និង សារជាតិផូស្វ័រ "Grad"និង"Uragan" មីស៊ីលបាលីស្ទិក "Scarab B" កាំភ្លើងប្លោង និងកាំភ្លើង ២៤០ ម.ម.។ ព័ត៌មានទាំងនេះត្រូវបានអះអាងដោយបណ្តាញសារព័ត៌មាន សាក្សីមើលឃើញផ្ទាល់ភ្នែក អង្គការក្រៅរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សដូចជា អង្គការឃ្លាំមើលសិទ្ធីមនុស្ស (Human Rights Watch) និង អង្គការលើកលែងទោសអន្តរជាតិ (Amnesty International Organization) ព្រមទាំងប្រភពដែលអាចទុកចិត្តបាននៃអ្នកកាសែតអន្តរជាតិ រួមទាំងរដ្ឋាភិបាលនានា និង អ្នកស៊ើបការសំងាត់របស់លោកខាងលិច។

នៅខែតុលា ជាលទ្ធផលនៃការវាយលុកដោយការបាញ់ផ្គត់គ្រាប់មីស៊ីលទៅលើសង្កាត់នានាក្នុងតំបន់ដូញៀតស្គ័(Donetsk) ពីទីតាំងដែលស្ថិតក្រោមការគ្រប់គ្រងរបស់កងកម្លាំង និង កងវរសេនាតូចជាតិអ៊ុយក្រែនបានសម្លាប់កុមារជាច្រើននាក់ ដែលនេះអាចចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងជនស៊ីវិលស្លូតត្រង់។

នៅតំបន់ដូញៀតស្គ័(Donetsk) និង តំបន់ ឡូហាន់ស្គ័ (Lugansk) រណ្តៅសាកសពរួមត្រូវបានគេរក
ឃើញជាមួយសញ្ញាជាច្រើនដែលបញ្ជាក់អំពីការដាក់ទោសដោយមិនឆ្លងកាត់តុលាការ។
ជារួម ការប្រើប្រាស់អាវុធយុទ្ធភ័ណ្ឌដោយកងប្រដាប់អាវុធអ៊ុយក្រែនអាចសន្និដ្ឋានអោយឃើញពីការ
ប្រើប្រាស់អាវុធដែលគេហាមប្រាមនិងយុទ្ធសាស្ត្រសង្គ្រាម។ ការធ្លាក់យន្តហោះ ប៊ូអ៊ីង ៧៧៧ នៃក្រុម
ហ៊ុនម៉ាឡេស៊ីកាលពីខែកក្កដាឆ្នាំនេះនៅតំបន់ដូញៀតស្គ័បានបណ្តាលអោយមនុស្សស្លាប់ចំនួន ២៩៨
នាក់។ ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធិភាពនិងអាព្យាក្រឹតនៃសោកនាដកម្មនេះមិនទាន់ត្រូវបាន
គេធ្វើឡើងនៅឡើយនោះទេ ហើយនេះបានបង្ហាញអោយឃើញយ៉ាងជាក់ច្បាស់អំពីការ ការរំលោភ
ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ២១៦៦ ចុះកាលបរិច្ឆេទនៅ
ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤ និងការរំលោភលើបទបញ្ញតិនៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ
(ICAO)ដោយក្រុមដែលពុំចាប់អារម្មណ៏ក្នុងការស្វែងរកការពិត។
ជាលទ្ធផលនៃសកម្មភាពយោធារបស់រដ្ឋាភិបាលក្រុងគៀវ ប៉ែកខាងកើតឆៀងខាងត្បូងនៃប្រទេស
អ៊ុយក្រែនបានបង្ហាញអោយឃើញនូវស្ថានភាពខូចខាតខ្ទេចខ្ទីជាអ្វីហៅដែលគេហៅថា មហន្តរាយ
មនុស្សជាតិ។ យោងតាមការប៉ាន់ប្រមាណរបស់អ្នកជំនាញអង្គការសហប្រជាតិ នៅក្នុងទីក្រុងមួយ
ចំនួននៃតំបន់នោះលំនៅដ្ឋានលើសពី ៦០ភាគរយត្រូវបានបំផ្លាញដោយផ្នែកឬទាំងស្រុងតែម្តង។
ដូចដែលប្រធានាធិបតីអ៊ុយក្រែនP. Poroshenko បានសារភាពថា ៤២ភាគរយនៃគ្រឿងបរិក្ខារនៃ
រោងចក្រឧស្សាហកម្ម និង ពាក់កណ្តាលនៃហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ដូនប៉ាស់ (Donbass) ត្រូវ
បានបំផ្លិចបំផ្លាញ។

ផលវិបាកនៃការវាយប្រហារដ៏មហន្តរាយពីសំណាក់កងទ័ពអ៊ុយក្រែន អគារ និងគ្រឿងបរិក្ខារនានា
ដែលបំរើដល់ការរស់នៅនិងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន រួមមាន មន្ទីរពេទ្យ (តាមរបាយការណ៏
អង្គការសហប្រជាជាតិ មានមន្ទីរពេទ្យជាង ៣0 នៅក្នុងតំបន់ដូញៀតស្គ័ Donetsk)មន្ទីរពេទ្យសម្ភព
សាលាមត្តេយ្យ និង មជ្ឈមណ្ឌលកុមារកំព្រា មជ្ឈមណ្ឌលចាស់ជរាចូលនិវត្តន៏ សាលារៀន សកលវិទ្យា
ល័យ ស្ថានីយ៏ផ្គត់ផ្គង់អគ្គិសនី ខ្សែតបណ្តាញផ្គត់ផ្គង់អគ្គីសនី និង ឃ្លាំ ងឪសថនានា ត្រូវបានបំផ្លិច
បំផ្លាញ។ នៅក្នុងក្រុងមួយចំនួននៃតំបន់ ដូញៀតស្គ័ (Donetsk)និង ឡូហានស្គ័(Lugansk) ប
ណ្តាញទូរស័ព្ទ បណ្តាញផ្គត់ផ្គង់ទឹក និង ហ្គាស ត្រូវបានកាត់ផ្តាច់។ ប្រជាជនជាច្រើនបានបាត់បង់
ការងារ ផ្ទះសម្បែង និង លទ្ធភាពនៃការរស់នៅសមរម្យ។

ដោយយល់ឃើញខុសពីតថភាពពិត ប្រទេសអ៊ុយក្រែន និង បណ្តាលោកខាងលិចបានបង្កប់នូវការ
មន្ទិលសង្ស័យ និង បានបង្កើតឧបសគ្គផ្សេងៗរំខានដល់កិច្ចប្រឹងប្រែងរបស់ប្រទេសរុស្ស៊ីដើម្បីបញ្ជូន
ជំនួយមនុស្សធម៌ទៅប៉ែកខាងត្បូង និង ខាងកើតនៃប្រទេសអ៊ុយក្រែន។
កស្តុតាងត្រូវបានរកឃើញដោយសកម្មជនសិទ្ធិមនុស្ស ដែលរួមមានទាំងអង្គការសង្គមស៊ីវិលរុស្ស៊ី«មូល
និធិដើម្បីការសិក្សាលទ្ធិប្រជាធិបតេយ្យ»អំពីការធ្វើទណ្ឌកម្មដ៏ឃោរឃៅ អមនុស្សធម៌និង ការបន្ទាប

បន្ថោកតម្លៃជាមនុស្សរបស់បណ្ដាជន និង អ្នកទោសដែលមកពីភាគអាគ្នេយ៍ប្រទេសពីសំណាក់កង កម្លាំងប្រដាប់អាវុធ និង  កងសន្តិសុខអ៊ុយក្រែន (កងទ័ព ក្រសួងមហាផ្ទៃ ភ្នាក់ងារសន្តិសុខ រួមទាំង ក្រុមអ្នកជាតិនិយមជ្រុល«កងស្ម័គ្រចិត្ត»)។ វិធីដាក់ទណ្ឌកម្មមានជាអាទិ៍ ការដុតដោយប្រើដែកក្ដៅ ការបញ្ជូនអោយរត់កាត់ចំការមីន   ការបាញ់ស៊ីប  និង ការបោះចូលក្នុងរណ្ដៅជាមួយសាកសព និង ការបញ្ច្រកទឹកតាមមាត់ ដែលនេះជាវិធីសាស្ត្រដែលពេញនិយមប្រើដោយក្រុមភ្នាក់ងារសំងាត់អាមេរិក ក្នុងការសួរចម្លើយអ្នកទោសបរទេសពិសេស និងនៅជំរំគុក Guantanamo ។

ក្នុងកំឡុងពេលនៃការសិក្សាស្រាវជ្រាវចងក្រងឯកសារនេះ  មានការកត់សំគាល់អំពីស្ថានភាពកាន់តែ អាក្រក់ទៅនៃសេរីភាពក្នុងការបញ្ចេញមតិ និង   ការរឹតបន្តឹងសេរីភាពសារព័ត៌មានដោយអាជ្ញាធរក្រុង គៀវ។  វិទ្យាស្ថានអន្តរជាតិដើម្បីសន្តិសុខអ្នកសារព័ត៌មានបានទទួលស្គាល់ថា  អ៊ុយក្រែនគឺជាប្រទេស ដែលមានគ្រោះថ្នាក់បំផុតសំរាប់អ្នកសារព័ត៌មាននៅក្នុងពិភពលោក។ នៅដើមខែសីហា  អ្នកថតរូបនិង ជាអ្នកយកការណ៏អោយភ្នាក់ងារសារព័ត៌មានអន្តរជាតិ «រុស្ស៊ីថ្ងៃនេះ» លោក អា. ស្តេនីន ត្រូវបាន សម្លាប់នៅជិតតំបន់ដូញៀតស្កិ (Donetsk) ។
ក្នុងកំឡុងពេលខាងលើនេះ ការបាញ់ប្រហារ ការវាយធ្វក់ ការវាយតប់ និង ការចាប់ពង្រត់អ្នកសារព័ត៌ មាននៅតែបន្ត។ មានភស្តុតាងនៃការចាប់ខ្លួន និង ការឃុំឃាំងពលរដ្ឋដោយលាក់បាំង  និង  ព័ត៌មាន ស្តីអំពីស្ថានភាពពិតនៃអ្វីដែលបានកំពុងកើតឡើងនៅភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែនត្រូវបាន គេចែកផ្សព្វនៅលើប្រព័ន្ធអ៊ីនធឺណេត។
អាជ្ញាធរអ៊ុយក្រែនបានដាក់ចេញនូវនយោបាយរឹតបន្តឹងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេស។   ជាក់ស្តែ ងអាជ្ញាធរបានកាត់ផ្ដាច់ប៉ុស្ដិ៍ទូរទស្សន៍រុស្ស៊ីទាំងអស់ដែលមានការពេញនិយមយ៉ាងខ្លាំងនៅក្នុងប្រទេស អ៊ុយក្រែន។  ក្នុងករណីដែលមន្ត្រីក្នុងស្រុកនៅតែបន្តការផ្សព្វផ្សាយនោះពួកគេនឹងត្រូវប្រឈមមុខទៅ នឹងបទល្មើសព្រហ្មទណ្ឌ។ ការគាបសង្កត់   និង  ការធ្វើទុកបុកម្នេញក្នុងទ្រង់ទ្រាយធំត្រូវបានប្រកាន់ យកដោយអាជ្ញាធរអ៊ុយក្រែន ដើម្បីប្រឆាំងទៅនឹងបណ្ដាអ្នកនយោបាយទាំងឡាយណាដែលមាន និន្នាការផ្សេងពីខ្លួន។      ដើម្បីសម្រេចនូវគោលបំណងរបស់ខ្លួនពួកអ្នកកាន់អំណាចក្រុងគៀវបាន ប្រើប្រាស់ការសម្លាប់បំបិទមាត់អ្នកនយោបាយប្រឆាំង ប្រឌិតរឿងដើម្បីចោទប្រកាន់ក្នុងបទព្រហ្មទណ្ឌ ការរកចាប់ខ្លួនដោយខុសច្បាប់ការរឹបអូសទ្រព្យសម្បត្តិ  ការលួចវាយប្រហារ ឬ ទង្វើបាតសង្គមផ្សេងៗ តួយ៉ាងដូចជាការចាប់អ្នកនយោបាយបោះចូលទៅក្នុង «ធុងសំរាម» ព្រមទាំងវិធីសាស្ត្រផ្សេងៗទៀត ដែលផ្ទុយនឹងច្បាប់  គោលការណ៏នីតិរដ្ឋ និង លទ្ធិប្រជាធិបតេយ្យ។
ការបោះឆ្នោតសភាដែលប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែ តុលាឆ្នាំ ២០១៤   ត្រូវបានកត់សំគាល់ទៅ ដោយភាពមិនប្រក្រតីជាច្រើនក្នុងកំឡុងពេលនៃការឃោសនាបោះឆ្នោត  ថ្ងៃបោះឆ្នោត និង កំឡុង ពេលរាប់សន្លឹកឆ្នោត  ដែល    បានរំលោភបំពានយ៉ាងធ្ងន់ធ្ងរដល់មូលដ្ឋានគ្រឹះស្តង់ដារអន្តរជាតិនៃការ បោះឆ្នោតបែបលទ្ធិប្រជាធិបតេយ្យ។

ស្ថានភាពមិនប្រក្រតី និង ឫសគល់របស់វាត្រូវបានសិក្សាយ៉ាងពិស្តារនៅក្នុងរបាយការណ៍វិភាគរបស់គណកម្មាធិការកណ្តាលរៀបចំការបោះឆ្នោតរុស្ស៊ី។

ដូចនឹងការបោះពុម្ពពីរលើកមុនដែរ សៀវភៅនេះត្រូវបានចងក្រងដោយផ្អែកទៅលើលទ្ធផលនៃការតាមដានយ៉ាងម៉ត់ចត់នៃប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានអន្តរជាតិ អ៊ុយក្រែន និងរុស្ស៊ី សាក្សីដែលបានឃើញហេតុការណ៍និងអ្នកសរសេរប្លុក សេចក្តីថ្លែងការណ៍និងការស្រង់ពាក្យសំដីពីសំណាក់ថ្នាក់ដឹកនាំអ៊ុយក្រែន និង អ្នកតំណាងកងប្រដាប់អាវុធនៃភាគីជម្លោះដែលកំពុងប្រយុទ្ធនៅភាគខាងត្បូង និងខាងកើតនៃប្រទេសអ៊ុយក្រែន។

ក្នុងនោះដែរ ការចងក្រងសៀវភៅនេះក៏ផ្តោតការយកចិត្តទុកដាក់យ៉ាងពិសេសទៅលើរបាយការនៃទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការដើម្បីសន្តិសុខ និង សហប្រតិបត្តិការក្នុងទ្វីបអ៊ឺរ៉ុប (OSCE) និង ក្រុមប្រឹក្សានៃទ្វីបអ៊ឺរ៉ុប ព័ត៌មានដែលផ្តល់អោយដោយគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម និង អង្គការដែលទទួលស្គាល់ដោយអន្តរជាតិនានាដូចជា អង្គការឃ្លាំមើលសិទ្ធិមនុស្ស អង្គការលើកលែងទោសអន្តរជាតិ ជាដើម និង អង្គការសង្គមស៊ីវិលរុស្ស៊ីនានាដូចជា មូលនិធិសំរាប់ការស្រាវជ្រាវលទ្ធិប្រជាធិបតេយ្យ ក្រុមប្រឹក្សាសាធារណៈសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ និង កិច្ចការបរទេសរុស្ស៊ី នៃសភាសាធារណៈសហព័ន្ធរុស្ស៊ី ជាដើម។ ជាទូទៅ ផ្នែកនីមួយៗនៃសៀវភៅនេះ មានសម្រង់មូលដ្ឋានគ្រឹះនៃបទបញ្ញត្តិអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ។

ដូចការបោះពុម្ពលើកមុនដែរ «សៀវភៅស»នេះមានគោលបំណងដើម្បីទាក់ទាញការយកចិត្តទុកដាក់បន្ថែមទៀតពីសំណាក់សហគមន៍អន្តរជាតិ បណ្តាអង្គការសិទ្ធិមនុស្ស និង ស្ថាប័ននានា បណ្តាញផ្សព្វផ្សាយ និង អ្នកដែលចាប់អារម្មណ៍ជាមួយនឹងស្ថានភាពដ៏មហន្តរាយនៃការរំលោភសិទ្ធិមនុស្ស និង នីតិរដ្ឋ ដែលបានកំពុងកើតឡើង តាំងពីការធ្វើរដ្ឋប្រហារដោយខុសច្បាប់នៅក្នុងប្រទេសអ៊ុយក្រែនកន្លងមក។

រាល់គ្រប់បទល្មើសដែលបានប្រព្រឹត្តនៅក្នុងប្រទេសអ៊ុយក្រែន កំឡុងពេលនៃការរៀបរាប់ក្នុងការបោះពុម្ពទាំងបីលើក ត្រូវក្លាយជាកម្មវត្ថុនៃការស៊ើបអង្កេតប្រកបដោយប្រសិទ្ធិភាពក្រោមការត្រួតពិនិត្យជាអន្តរជាតិ ហើយជនប្រព្រឹត្តបទល្មើសទាំងនោះនឹងត្រូវបញ្ជូនទៅតុលាការ។ និទណ្ឌភាពនឹងមិនត្រូវអោយមានជាដាច់ខាត ។

## ១. ការរំលោភសិទ្ធិរស់រានមានជីវិត សេរីភាព និង សន្តិសុខ

### សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១០ ធ្នូ ១៩៤៨)

**មាត្រា ៣**

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

**មាត្រា ៥**

គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅ អមនុស្ស ធម៌ ឬបន្ថោកបន្ទាបបានឡើយ។

**មាត្រា ៩**
គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន តាមអំពើចិត្តឡើយ។

**កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ**
(ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦)
**មាត្រា៦**
១. ជនគ្រប់រូបមានសិទ្ធិមានជីវិតជាប់ពីកំណើត។ សិទ្ធិនេះត្រូវការពារដោយច្បាប់។ គ្មានជនណាម្នាក់ត្រូវគេប្រហារជីវិតាមអំពើចិត្តបានឡើយ។
៣. នៅពេលដែលការប្រហារជីវិតជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវយល់ថា គ្មានបទបញ្ញតិណាមួយនៃមាត្រានេះដែលអនុញ្ញាតឱ្យរដ្ឋភាគីនៃកតិកាសញ្ញានេះ ធ្វើបដិប្បញ្ញតិតាមបែបណាមួយពីកាតព្វកិច្ចណាដែលបានសន្មតស្របតាមបទបញ្ញត្តិនៃអនុសញ្ញាស្តីពីការបង្ការ និង ការផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍នោះបានឡើយ។
**មាត្រា ៧**
គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬ ការប្រព្រឹត្ត ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬ ធ្វើអោយថោកទាបឡើយ ឬ ដាក់ទណ្ឌកម្ម....។
**មាត្រា៩**
១. ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬ ឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និង ស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។

**កាតិកាការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន**
(ទីក្រុង រ៉ូម ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ១៩៥០)
**មាត្រាទី ២ សិទ្ធិរស់រានមានជីវិត**
សិទ្ធិរស់រានមានជីវិតរបស់មនុស្សគ្រប់រូបត្រូវបានទទួលការការពារដោយច្បាប់។ គ្មានជនណាម្នាក់ត្រូវបានដកហូតសិទ្ធិនេះឡើយ
**មាត្រាទី៣ ការហាមឃាត់ការធ្វើទណ្ឌកម្ម**
គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកបានឡើយ។
**មាត្រាទី៥ សិទ្ធិមានសេរីភាព និង សន្តិសុខ**
មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន។

**ពិធីសារពាក់ព័ន្ធទី ៦នៃកាតិកាសញ្ញាការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋានទាក់ទងទៅនឹងការលុបចោលនៃទោសប្រហារជីវិត**

**មាត្រាទី១.** ការលុបចោលទោសប្រហារជីវិតទោសប្រហារជីវិតត្រូវបានលុបចោល។ គ្មាននរណាគ្មានត្រូវទទួលការផ្តន្ទាទោសប្រហារជីវិត ឬ ប្រហារជីវិតឡើយ។

**ពិធីសារពាក់ព័ន្ធទី ១៣ កាតិសញ្ញាការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានទាក់ទងនឹងការលុបចោលនៃទោសប្រហារជីវិតក្នុងគ្រប់កាលៈទេសៈ**
( ទីក្រុង វីលនីស ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០២ )

**មាត្រាទី១. ការលុបចោលទោសប្រហារជីវិត**
ទោសប្រហារជីវិតត្រូវបានលុបចោល។ គ្មាននរណាគ្មានត្រូវទទួលការផ្តន្ទាទោសប្រហារជីវិត ឬ ប្រហារជីវិតឡើយ។

**កាតិកាសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងអំពីព្រៃផ្សៃ អមនុស្សធម៌ និង ការបន្ទាបបន្ថោក**
**(ថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៨៤)**
**មាត្រាទី ២**
១. ភាគីហត្ថលេខីនីមួយៗត្រូវចាត់វិធានការណ៍អោយមានប្រសិទ្ធិភាពតាមផ្លូវច្បាប់ រដ្ឋបាល តុលាការ ឬ វិធីដទៃទៀតដើម្បីការពារមិនអោយមានសកម្មភាពនៃការធ្វើទារុណកម្មនៅក្នុងដែនដីដែលស្ថិតក្នុងអធិបតេយ្យភាពរបស់ខ្លួន។
២. គ្មានករណីលើកលែងឡើយ ទោះជារដ្ឋនោះកំពុងធ្វើសង្គ្រាម ឬ ការគំរាមកំហែង អសន្តិសុខនយោបាយក្នុងស្រុក ឬ ស្ថានភាពបន្ទាន់សាធារណៈណាមួយមិនអាចត្រូវបានប្រើជាលេសក្នុងការធ្វើទារុណកម្មជនណាម្នាក់ឡើយ។
៣. ការបញ្ជាពីមន្ត្រីជាន់ខ្ពស់ ឬ អាជ្ញាធររដ្ឋមិនអាចជាលេសក្នុងការធ្វើទារុណកម្មលើជនណាម្នាក់ឡើយ។

**អនុសញ្ញាស្តីអំពីសិទ្ធិកុមារ (ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩)**
**មាត្រាទី ៦**
១. រដ្ឋជាភាគិទទួលស្គាល់ថា កុមារគ្រប់រូបសុទ្ធតែមានសិទ្ធិដើម្បីមានជីវិតដែលមិនអាចដកហូតបាន។

២. រដ្ឋជាភាគីត្រូវធានាការរស់នៅ ព្រមទាំងការរីកចំរើនលូតលាស់របស់កុមារអោយបានដល់កំរិតខ្ពស់បំផុត។

**មាត្រា ៣៧**

រដ្ឋជាភាគីត្រូវធានាថា:

១. គ្មានកុមារណាម្នាក់ត្រូវរងទារុណកម្មឬ ទទួលការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំអោយបាត់បង់តម្លៃជាមនុស្សឡើយ។

**មាត្រា ៣៨**

១. រដ្ឋជាភាគីសន្យាគោរពនិងធានាអោយមានការគោរពនូវបទបញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិដែលត្រូវអនុវត្តមកលើខ្លួននៅក្នុងជំលោះដោយអាវុធ ហើយដែលមានការទាក់ទិនដល់កុមារ។

៤. ស្របទៅតាមកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវការពារប្រជាជនស៊ីវិលនៅក្នុងជម្លោះដោយអាវុធដោយអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិនោះ ឬរដ្ឋជាភាគីនឹងប្រកាន់យកនូវរាល់វិធានការណ៏ដែលអាចធ្វើបានដើម្បីធានាគាំពារនិងការថែទាំដល់កុមារដែលត្រូវប៉ះពាល់ដោយជម្លោះអាវុធ។

**មាត្រា ៣៩**

រដ្ឋជាភាគិប្រកាន់យករាល់វិធានការសមស្របទាំងអស់ ដើម្បីជំរុញការស្តារផ្នែករាងកាយនិងផ្នែកចិត្តសាស្ត្រព្រមទាំងការបញ្ចូលក្នុងសង្គមវិញនូវកុមារដែលបានរងគ្រោះនូវការមិនថែទាំការជិះជាន់ ឬ ការបំពាន ទារុណកម្មបែបណាមួយ ឬដោយទំរង់ផ្សេងៗនៃការប្រព្រឹត្តឬការផ្តន្ទាទោសដែលឃោរឃៅអមនុស្សធម៌ និង ដែលនាំអោយបាត់បង់តម្លៃជាមនុស្ស ឬ ដោយសារជម្លោះដោយអាវុធ។ ការស្តារឡើងវិញ និង ការបញ្ចូលក្នុងសង្គមវិញនេះ ត្រូវប្រព្រឹត្តទៅក្នុងលក្ខណៈមួយដែលមានអំណោយផលដល់សុខភាព ដល់ស្មារតីស្វ័យគោរព ហើយនិងដល់ភាពថ្លៃថ្នូររបស់កុមារ។

**ពិធីសារពាក់ព័ន្ធបន្ថែម អនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និង ការការពារជនរងគ្រោះពីជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (ពិធីសារពាក់ព័ន្ធ២ ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧)**

**មាត្រាទី៤  ការធានាជាមូលដ្ឋាន**

១. មនុស្សគ្រប់រូបដែលពុំបានចូលរួមដោយផ្ទាល់ ឬ ជនដែលបានបញ្ចប់ការចូលរួមនៅក្នុងការប្រយុទ្ធមិនអាស្រ័យថា សេរីភាពរបស់ពួកគេត្រូវបានកម្រិតឬយ៉ាងណា នៅតែមានសិទ្ធិទទួលបានការគោរពផ្ទាល់ខ្លួន កិត្តិយស ជំនឿ និង ការប្រតិបត្តិសាសនា។ គ្រប់កាលៈទេសៈទាំងអស់ ពួកគេត្រូវបានចាត់ទុកជាមនុស្ស ដោយគ្មានការបែងចែកឡើយ។  ហាមដាច់ខាតនូវការបញ្ជាមិនអោយមានអ្នករស់រានមានជីវិត។

២. ដោយពុំមានការផ្ទុយទៅនឹងបទបញ្ញត្តិខាងលើ    យោងតាមវាក្យខណ្ឌទី១ គ្រប់សកម្មភាពខាងក្រោមដែលប្រឆាំងនឹងមនុស្ស ត្រូវបានហាមឃាត់គ្រប់ពេលវេលា និង គ្រប់ទីកន្លែង:

(ក) អំពើហឹង្សាប៉ះពាល់ដល់អាយុជីវិត សុខភាព និង ស្ថានភាពល្អប្រសើរនៃផ្លូវចិត្តនិងរាងកាយរបស់មនុស្ស ជាពិសេស អំពើមនុស្សឃាត ព្រមទាំងអំពើសាហាវព្រៃផ្សៃដូចជា ទារុណកម្ម (mutilation) ឬគ្រប់ទំរង់នៃការធ្វើទណ្ឌកម្ម។

(ខ) ការធ្វើទារុណកម្មដោយប្រមូលផ្តុំ

(គ) ការចាប់ធ្វើជាចំណាប់ខ្មាំង

(ឃ) អំពើភេរវកម្ម

(ង) សកម្មភាពប៉ះបាល់ដល់ភាពថ្លៃថ្នូរបុគ្គល ជាពិសេស ការធ្វើអោយអាម៉ាស់ និង ការបន្ទាបបន្ថោកភាពថ្លៃថ្នូរ ការចាប់រំលោភ ចាប់បង្ខំអោយធ្វើជាស្ត្រីពេស្យារ និង ការវាយធ្វើបាបគ្រប់រូបភាព។

(ច) ទាសភាព និង ការជួញដូរទាសករគ្រប់ទំរង់ ។

(ឆ) ការលួចឆក់ប្លន់

(ជ) ការគំរាមកំហែងប្រព្រឹត្តគ្រប់សកម្មភាពខាងលើ។

**មាត្រាទី ៩ ការការពារបុគ្គលិកសុខាភិបាល និង សាសនា**

១. បុគ្គលិកសុខាភិបាល និង សាសនទូតត្រូវបានគោរពនិងការពារ ហើយត្រូវបានផ្តល់ការជួយគ្រប់លទ្ធភាពក្នុងការបំពេញភារកិច្ចរបស់ពួកគេ។ បុគ្គលិកសុខាភិបាល និង សាសនទូត មិនត្រូវបានបង្ខំអោយបំពេញកិច្ចការដែលមិនស្របទៅនឹងបេសកកម្មមនុស្សធម៌របស់ពួកគេឡើយ។

**មាត្រាទី១១** ការការពារមធ្យោបាយដឹកជញ្ជូន និង គ្រឿងបរិក្ខារសុខាភិបាល

១. រាល់មធ្យោបាយដឹកជញ្ជូននិងគ្រឿងបរិក្ខារពេទ្យត្រូវបានគោរពនិងការពារគ្រប់ពេលវេលា និង មិនត្រូវក្លាយជាកម្មវត្ថុនៃការវាយប្រហារឡើយ។

**មាត្រាទី ១៣ ការការពារប្រជាជនស៊ីវិល**

១. ប្រជាជនស៊ីវិល និង ជនស៊ីវិលម្នាក់ៗត្រូវទទួលបានការការពារជាទូទៅប្រឆាំងទៅនឹងគ្រោះថ្នាក់នៃការកើតឡើងនៃប្រតិបត្តិការយោធា។ ដើម្បីផ្តល់នូវការការពារប្រកបដោយប្រសិទ្ធិភាព បទបញ្ញតិខាងក្រោមនេះត្រូវបានពិនិត្យក្នុងគ្រប់កាលៈទេសៈ។

២. ប្រជាជនស៊ីវិល ក៏ដូចជាជនស៊ីវិលម្នាក់ៗ មិនត្រូវជាកម្មវត្ថុនៃការវាយប្រហារឡើយ។ រាល់សកម្មភាព ឬការគំរាមកំហែងប្រើអំពើហឹង្សាក្នុងគោលបំណងធ្វើអោយភ័យខ្លាចដល់ប្រជាជនស៊ីវិលត្រូវបានហាមឃាត់។

៣. ជនស៊ីវិលទាំងអស់ត្រូវទទួលបានការការពារដោយបទបញ្ញតិនៃផ្នែកនេះ ប្រសិនបើក្នុងរយៈពេលនេះពួកគេមិនចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពយោធា។

**មាត្រាទី១៤** ការការពារវត្ថុផ្សេងៗដែលមានសារៈសំខាន់ដល់ការរស់នៅរបស់ប្រជាជនស៊ីវិលហាមដាច់ខាត ការប្រើប្រាស់យុទ្ធសាស្ត្រធ្វើអោយប្រជាជនស៊ីវិលអត់ឃ្លាននៅក្នុងការប្រយុទ្ធ។ អាស្រ័យដូចនេះហើយ ការវាយលុក ការបំផ្លិចបំផ្លាញ ការផ្លាស់ប្តូរកិល ឬ សកម្មភាពធ្វើអោយខូចខាតប្រើប្រាស់លែងកើតនូវវត្ថុដែលមានសារៈសំខាន់ដល់ការរស់នៅរបស់ប្រជាជនស៊ីវិល ដូចជាចំណីអាហារបម្រុង

តំបន់កសិកម្មសំរាប់ផលិត Foodstuffs ផលិតផលធញ្ញជាតិ កសិដ្ឋានចិញ្ចឹមសត្វ គ្រឿងឧបករណ៏សំរាប់ផលិតទឹកស្អាត និង គ្រឿងផ្គត់ផ្គង់ជាដើម។

**អនុសញ្ញា (៤) ពាក់ព័ន្ធនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម**
**(ទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩)**
**មាត្រាទី៣**

ក្នុងករណីជម្លោះប្រដាប់អាវុធ ដែលមិនមានលក្ខណៈជាអន្តរជាតិ កើតឡើងនៅលើទឹកដីនៃភាគីព្រមព្រៀងជាន់ខ្ពស់ណាមួយ ភាគីជម្លោះនីមួយៗមានកាតព្វកិច្ចត្រូវអនុវត្តនូវបទបញ្ញតិខាងក្រោម៖

១. បុគ្គលដែលមិនបានចូលរួមដោយផ្ទាល់ក្នុងជម្លោះ រួមបញ្ចូលទាំងកងកម្លាំងយោធាដែលបានទម្លាក់អាវុធចុះចាញ់ និង ជនដែលបានឈប់ចូលរួមប្រយុទ្ធដោយមូលហេតុ មានជំងឺ រងរបួស ការឃុំឃាំង ឬក្រោមហេតុផលដទៃទៀត គ្រប់កាលៈទេសៈ ត្រូវទទួលបានការយកចិត្តទុកដាក់ក្នុងនាម មនុស្សធម៌ ដោយគ្មានការរើសអើង ពណ៌សំបុរ ជនជាតិ សាសនា និង ជំនឿ ភេទ កំណើត និង ទ្រព្យសម្បត្តិ ឬលក្ខខណ្ឌប្រហាក់ប្រហែលដទៃទៀត។

ក្នុងគោលបំណងការពារបណ្តាជនដូចដែលបានរៀបរាប់ខាងលើ រាល់សកម្មភាពខាងក្រោមត្រូវបានហាមឃាត់ជាដាច់ខាតគ្រប់កាលៈទេសៈ

(ក) ការប្រព្រឹត្តអំពើហឹង្សាដែលប៉ះពាល់ដល់អាយុជីវិត និង បុគ្គល ជាពិសេស ការសម្លាប់គ្រប់រូបភាព ការធ្វើអោយរងរបួស និង ការធ្វើទារុណកម្មយ៉ាងឃោរឃៅ

(ខ) ការចាប់ធ្វើជាចំណាប់ខ្មាំង

(គ) ការធ្វើអោយប៉ះពាល់ភាពថ្លៃថ្នូរបុគ្គល ជាពិសេស ការធ្វើអោយអាម៉ាស់ និងការបន្ទាបបន្ថោកតម្លៃ

(ឃ) ការកាត់ទោស និង ការប្រហារជីវិតដោយគ្មានការកាត់ក្តីជាមុន

**អនុសញ្ញាស្តីអំពីការហាមឃាត់ ឬ រឹតបន្តឹងការប្រើប្រាស់អាវុធដែលអាចបង្កគ្រោះថ្នាក់លើសលប់ ឬ មានផលប៉ះពាល់ធ្ងន់ធ្ងរ (ទីក្រុងហ្សឺណែវ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៨០)**

**ពិធីសារ៣ ស្តីពីការហាមឃាត់ ឬ រឹតបន្តឹងការប្រើប្រាស់អាវុធដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ**
**មាត្រាទី២**

១. ហាមឃាត់ជាដាច់ខាតគ្រប់កាលៈទេសៈនូវការយកប្រជាជនស៊ីវិល ជនស៊ីវិលនីមួយៗ ជាកម្មវត្ថុនៃការវាយប្រហារដោយអាវុធដែលបង្កគ្រោះថ្នាក់លើសលប់។

២. ហាមឃាត់ជាដាច់ខាតគ្រប់កាលៈទេសៈ ការយកទីតាំងមូលដ្ឋានទ័ពស្ថិតនៅទីកន្លែងដែលមានប្រជាជនស៊ីវិលរស់នៅ និង ការទម្លាប់គ្រាប់ដែលបង្កគ្រោះថ្នាក់លើសលប់។

**អនុសញ្ញាស្តីអំពីគ្រាប់បែកចង្កោម (ឌុប្លាំង ថ្ងៃទី ១៩-៣០ ខែឧសភា ឆ្នាំ ២០០៨)**
**មាត្រាទី១ កាតព្វកិច្ចទូទៅ និង ការវិសាលភាពនៃការអនុវត្ត**
រដ្ឋភាគីនីមួយៗត្រូវប្រកាន់ខ្ជាប់ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយៈ
ក. មិនប្រើប្រាស់គ្រាប់បែកចង្កោម។

**អនុសញ្ញាស្តីអំពីការការពារនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍**
**(ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨)**
**មាត្រាទី១**
ភាគីជាហត្ថលេខីទាំងអស់ អះអាងបញ្ជាក់ថា អំពើប្រល័យពូជសាសន៍ ទោះត្រូវបានប្រព្រឹត្តក្នុងពេលសន្តិភាព ឬក្នុងពេលមានសង្គ្រាម គឺជាបទឧក្រិដ្ឋដែលប្រឆាំងទៅនឹងច្បាប់អន្តរជាតិហើយភាគីទាំងអស់មានកាតព្វកិច្ចចាត់វិធានការការពារ និង ផ្តន្ទាទោស។

**ថ្ងៃទី ១ ខែកក្កដា** នៅ ក្រាម៉ាតរស្គ៍ (Kramatorsk) មនុស្ស ១៤ នាក់ត្រូវបានសម្លាប់ និង ៥នាក់រងរបួសដោយសារការបាញ់ផ្លោក់ពីសំណាក់កងយោធាអ៊ុយក្រែន រួមទាំងការបាញ់ទៅលើរថយន្តដឹកអ្នកដំណើរធុនតូចក្នុងតំបន់ វិថី រ៉ូម៉ែនសេវ៉ា (Rumiantseva) និង វិថី កាឌីណូវ៉ា (Kadinova)។
**ថ្ងៃទី ១ ខែកក្កដា** កងយោធាអ៊ុយក្រែនបានបាញ់ផ្លោក់ទៅលើទីក្រុង ស្លាវ៉ែនស្គ៍ (Slavyansk) និង (Yampol)ព្រមទាំងភូមិ សេមេណូវកា (Semenovka)។ ក្នុងកំឡុងពេលបាញ់ផ្លោក់នេះ បានបណ្តាលអោយស្ត្រីជនជាតិរុស្ស៊ីម្នាក់បានស្លាប់បាត់បង់ជីវិត និង ៣ នាក់រងរបួស។
**ថ្ងៃទី១ ខែកក្កដា** មានការបាញ់ផ្លោក់ក្នុងទ្រង់ទ្រាយធំដោយប្រើប្រព័ន្ធរ៉ុក្កែត "Grad" កាំភ្លើងរថក្រោះ និង កាំភ្លើងត្បាល់ ទៅលើភូមិ នីកូឡាយ៉េវកា (Nikolaevka) ដែលមានចម្ងាយ ១៥គីឡូម៉ែត្រឆ្ងាយពីក្រុង ស្លាវ៉ែនស្គ៍ (Slavyansk)។
**ថ្ងៃទី ១ ខែកក្កដា** ក្នុងក្រុង ឡូហានស្គ៍ (Logansk) ប្រជាជនពីរនាក់បានរងរបួសដោយសារការបាញ់ផ្លោក់ទៅលើតំបន់ដែលមានប្រជាជនរស់នៅ។
**ថ្ងៃទី ១ ខែកក្កដា** នៅក្នុងតំបន់ ដូញៀតស្គ៍ ចំងាយ ២០គីឡូម៉ែត្រពីព្រំដែនប្រទេសរុស្ស៊ី រថយន្តក្រុងពីរគ្រឿងដែលដឹកជនភៀសខ្លួនសំដៅពី ក្រាម៉ាតរស្គ៍ (Kramatorsk) ទៅតំបន់ វ្ល៉ាឌីមៀរ (Vladimir) នៃប្រទេសរុស្ស៊ី រងការបាញ់ប្រហារពីសំណាក់កងយោធាអ៊ុយក្រែន។ ក្នុងរថយន្តក្រុងមានមនុស្សសរុបទាំងអស់ ៨៤នាក់។

**ថ្ងៃទី១ ខែកក្កដា** នៅទីក្រុងគៀវ ការវាយតប់ក្នុងទ្រង់ទ្រាយធំមួយបានកើតឡើងរវាងជនអន្ធពាលពីរក្រុមដែលមានឈ្មោះថា «ប៉ារស៊ើនស្តី១០០» និង «កូសាក់១០០ទី៤ម៉ែដាន់» ដោយមានការប្រើគ្រាប់បែកផងដែរ បានកើតឡើងនៅជិតអគារសភាជាន់ខ្ពស់រ៉ាដារាប់អ៊ុយក្រែន។ ក្នុងនោះដែរ មានមនុស្សពីរនាក់បានរងរបួស។

**ថ្ងៃទី ២ខែ កក្កដា** នៅពេលព្រឹក កងកម្លាំងយោធាអ៊ុយក្រែនបានបាញ់ទៅលើស្ថានីយ៍វារីអគ្គិសនី "Severskiy Donets — Donbass" បានបណ្តាលអោយបាត់បង់ជីវិតជាងអគ្គិសនីម្នាក់ និង កម្មករស្ត្រីម្នាក់រងរបួសធ្ងន់។

**ថ្ងៃទី ២ ខែកក្កដា** នៅពេលព្រឹក កងកម្លាំងយោធាអ៊ុយក្រែនបានបាញ់គ្រាប់រ៉ុក្កែតទៅលើភូមិ ស្តារ៉ាយ៉ាកុនដ្រាសូវកា (Staraya Kondrashovka) ដែលមានចំងាយ ២០គីឡូម៉ែត្រពីក្រុង ឡូហានស្គ៍ (Logansk) ដែលបានបណ្តាលអោយមនុស្ស ៧នាក់ស្លាប់ រួមបញ្ចូលកុមារអាយុ ៥ឆ្នាំ និង មនុស្ស៨នាក់ទៀតរងរបួស។

**ថ្ងៃទី ២ ខែកក្កដា** នៅពេលរសៀល កងទ័ពអាកាសអ៊ុយក្រែនបានបើកការវាយប្រហារទៅលើទីប្រជុំជនស្តានីតសា ឡូហានស្កាយ៉ា (Stanitsa Luganskaya) ចម្ងាយ ១០គីឡូម៉ែត្រពីក្រុង ឡូហានស្គ៍។ ផ្ទះសម្បែងជាច្រើន ជាពិសេសនៅតាមបណ្តោយវិថី អូស្ត្រូវស្គី(Ostrovsky)ត្រូវបានបំផ្លិចបំផ្លាញដោយសារគ្រាប់បែកធុនធ្ងន់ទម្លាក់ពីលើអាកាសយ៉ាងតិច ៣។ មនុស្សចំនួន ១២នាក់ ត្រូវបានសម្លាប់ ដោយរួមទាំងកុមារ និង ជនស៊ីវិលជាច្រើននាក់រងរបួស។

**ថ្ងៃទី ២ខែកក្កដា** តាមបណ្តោយវិថី ស្លាវៀនស្គ៍ (Slavyansk) ក្បែរស្ពានឆ្លងកាត់ទន្លេ Kazenny Torets កងទ័ពអ៊ុយក្រែនបានបាញ់ទៅលើរថយន្តស៊ីវិលដែលបានបណ្តាលអោយមនុស្សស្លាប់បាត់បង់ជីវិតចំនួនពីរនាក់ និង បីនាក់រងរបួស។

**ថ្ងៃទី ២ ខែកក្កដា** មនុស្ស២នាក់បានដើរជាន់មីននៅក្នុងបរិវេណនៃព្រលានយន្តហោះ ឡូហានស្គ៍។ មនុស្សម្នាក់បានស្លាប់នៅនឹងកន្លែង ហើយម្នាក់ទៀតរងរបស់ធ្ងន់និងត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ។

**ថ្ងៃទី ២-៣ ខែ កក្កដា** ពេលយប់ កងកម្លាំងយោធាអ៊ុយក្រែនបានបាញ់ផ្លោក់ដោយកាំភ្លើងធំនៅក្រាម៉ាតរស្គ៍ (Kramatorsk)។ ផ្ទះសម្បែងជាច្រើនខ្នងត្រូវបានបំផ្លាញ ហើយបានបណ្តាលអោយមានមនុស្សបាត់បង់ជីវិត និង រងរបួសផងដែរ។

**ថ្ងៃទី ៣ ខែ កក្កដា** អ្នកតំណាងនាយកដ្ឋានព្រំដែនសហព័ន្ធរុស្ស៊ីប្រចាំនៅតំបន់រ៉ូស្តូវ (Rostov) លោក វ.ម៉ាឡាយ៉វ បានអោយដឹងថា នៅវេលាម៉ោង ៤:៣០នាទីព្រឹកគ្រាប់កាំភ្លើងត្បាល់មួយចំនួនបានធ្លាក់នៅក្បែរច្រកត្រួតពិនិត្យ ណូវូសាទីនស្គ៍ (Novoshahtinsk) ក្នុងដែនដីរុស្ស៊ី ដោយសារប្រយុទ្ធគ្នាក្នុងប្រទេសអ៊ុយក្រែន។

**ថ្ងៃទី ៣ ខែកក្កដា** នៅតំបន់ដូញៀតស្គ៍ (Donetsk) កងទ័ពជើងអាកាសអ៊ុយក្រែនបានទម្លាក់គ្រាប់បែកនៅក្បែរស្ថានីយ៍ Kondrashevka-Novaya ដោយបានសម្លាប់កម្មកររថភ្លើង ២នាក់ និង កុមារអាយុ៥ឆ្នាំម្នាក់។

**ថ្ងៃទី ៣ ខែ កក្កដា** ការប្រយុទ្ធគ្នាដ៏ឃោរឃៅមួយបានកើតឡើងនៅ នីកូឡាយ៉េវកា (Nikolaevka) ចម្ងាយ១៥គីឡូម៉ែត្រពីស្លាវ៉ែនស្គ៍ (Slavyansk)។ កងកម្លាំងយោធាអ៊ុយក្រែនបាញ់សន្ធាប់ដោយប្រព័ន្ធរ៉ុក្កែត "Grad"និង"Smerch"។ រថក្រោះ និង រថពាសដែកអ៊ុយក្រែនបានចូលលុកលុយក្នុងទីក្រុង។ មនុស្ស៤នាក់បានបាត់បង់ជីវិត ហើយយ៉ាងហោចណាស់មនុស្ស ១០នាក់បានរងរបួស។

**ថ្ងៃទី ៣ ខែកក្កដា** នៅក្រាម៉ាតរស្គ៍ )Kramatorsk) កងកម្លាំងយោធារុស្ស៊ីបានបាញ់ផ្តក់កាំភ្លើងធំដែលបានបណ្តាលអោយមនុស្សម្នាក់ស្លាប់ និង ជាង ២០នាក់រងរបួស។

**ថ្ងៃទី ៣ ខែកក្កដា** នៅ ក្រាសនីយ៍ លីម៉ាន កងកម្លាំងយោធាអ៊ុយក្រែនបានបាញ់ចូលក្នុងមន្ទីរពេទ្យរថភ្លើងដែលបានបណ្តាលអោយអ្នកជម្ងឺ៣នាក់រងរបួស និង គ្រូពេទ្យវះកាត់ម្នាក់បានបាត់បង់ជីវិតដោយសាររងរបួសធ្ងន់។

**ថ្ងៃទី ៣-៤ខែកក្កដា** កងកម្លាំងយោធាអ៊ុយក្រែនបានបើកការបាញ់ប្រហារទៅលើតំបន់ Bolshaya Vergunka ជាយក្រុងឡូហានស្គ៍ ដែលបានបណ្តាលអោយស្ត្រីម្នាក់បាត់បង់ជីវិត និង ម្នាក់ទៀតរងរបួសក្រោយពីគ្រាប់បានធ្លាក់ចំផ្ទះមួយខ្នងក្បែរផ្លូវ មិនស្ស៊ីនស្គី (Menzhensky)។ នៅសង្កាត់ទី ២៧ នៃក្រុងឡូហានស្គ៍ បុរសម្នាក់បានស្លាប់ដោយសាររងរបួសដោយត្រូវគ្រាប់ និង ៧ នាក់ទៀតបានរងគ្រោះដោយសារគ្រាប់បានធ្លាក់ចំលំនៅដ្ឋានរបស់ពួកគេ។

**ថ្ងៃទី ៤ខែកក្កដា** នៅក្បែរតំបន់ត្រួតពិនិត្យព្រំដែន រុស្ស៊ី-អ៊ុយក្រែនក្នុងតំបន់ឡូហានស្គ៍ ក្រុម snipers អ៊ុយក្រែនបានធ្មក់បាញ់ប្រហារទៅលើរថយន្ត និង រថយន្តក្រុងដែលដឹកជនភៀសខ្លួនឆ្ពោះមកកាន់រុស្ស៊ី។ អ្នកស្រុកបានដាក់ឈ្មោះផ្លូវនោះថា «ផ្លូវមរណៈ»។

**ថ្ងៃទី ៤ ខែកក្កដា** នៅ រូស្តុស (Rostov) ក្បែរកន្លែងត្រួតពិនិត្យ ដូញៀតស្គ៍ «Donetsk» ផ្នាំព្រំដែនរុស្ស៊ី និង ក្រុមអង្កេតការបានក្លាយជាគោលដៅនៃការបាញ់ផ្តក់ពីទឹកដីអ៊ុយក្រែន។

**ថ្ងៃទី ៤ កក្កដា** នៅស្លាវ៉ែនស្គ៍ កងយោធាអ៊ុយក្រែនបានបើកការវាយប្រហារមកលើតំបន់អ្នកស្រុកដែលបានសំលាប់ជនស៊ីវិលចំនួន ៦នាក់ភាគច្រើនគឺជាមនុស្សចាស់ជរាដែលមិនអាចចាកចេញពីក្រុងបាន។

**ថ្ងៃទី ៥ ខែកក្កដា** កងទ័ពជើងអាកាសអ៊ុយក្រែនបានបាញ់ទៅលើព្រលានយន្តហោះដូញៀតស្គ៍។

**ថ្ងៃទី ៥ ខែកក្កដា** នៅឡូហានស្គ៍ កងយោធាអ៊ុយក្រែនបានបាញ់សម្លាប់មនុស្សម្នាក់ របួស ១៣នាក់។

**ថ្ងៃទី ៥ខែកក្កដា** នៅ រូស្តុស (Rostov) ក្បែរចំនុចត្រួតពិនិត្យដូញៀតស្គ៍ (Donetsk) បានទទួលរងការបាញ់ផ្តក់ពីខាងទឹកដីអ៊ុយក្រែន។

**ថ្ងៃទី ៦ខែកក្កដា** នៅនីកូឡាយ៉េវកា កងទ័ពអ៊ុយក្រែនជាថ្មីម្តងទៀតបានបើកការបាញ់មកលើជនស៊ីវិលដែលកំពុងជម្លៀសចាកចេញពីក្រុង។

**ថ្ងៃទី៦ ខែកក្កដា** យន្តហោះអ៊ុយក្រែន Su 25 បានបាញ់មកលើ Metallist និង Alexandrovka ដែលស្ថិតនៅជាយក្រុង ឡូហានស្គ៍ Lugansk។

**ថ្ងៃទី ៦ ខែកក្កដា** មានការបាញ់ផ្តក់មកចំភាគកណ្តាលនៃក្រុងឡូហានស្គ៍ដែលបានបណ្តាលអោយសន្តិសុខកន្លែងលក់រថយន្តម្នាក់ស្លាប់ និង ៤នាក់ទៀតរងរបួសធ្ងន់។ គ្រាប់បានធ្លាក់ចំរថយន្ត Niva នៅលើវិថី Kransnodonskaya ដែលបានសម្លាប់មនុស្សពីរនាក់។

**ថ្ងៃទី ៧ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានប្រើប្រាស់អាវុធផូស្វ័របាញ់មកលើ តំបន់ Lisichiansk។
**ថ្ងៃទី ៧ ខែកក្កដា** នៅឡូហានស្គ៍ យោងតាមរដ្ឋមន្ត្រីសុខាភិបាលនៃសាធារណរដ្ឋឡូហានស្គ៍ វិកទ័រ អាវ៉ាគៀន (Victor Avakian) បានអោយដឹងថា ក្នុងរយៈពេល ២៤ម៉ោងមានអ្នករងរបួស ៨០នាក់ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ។
**ថ្ងៃទី ៧ ខែ កក្កដា** នៅ Krasnodon នៃឡូហានស្គ៍ (Lugansk) កងប្រដាប់អាវុធអ៊ុយក្រែនបានបើកការបាញ់ប្រហារ ហើយ កងទ័ពអាកាសរបស់អ៊ុយក្រែនបានទម្លាក់គ្រាប់បែកផូស្វ័រមកលើរថយន្តក្រុងដែលកំពុងដឹកជនភៀសខ្លួន។
**ថ្ងៃទី ៨ ខែកក្កដា** (ពេលព្រឹក) នៅឡូហានស្គ៍ មនុស្សពីរនាក់បានបាត់បង់ជីវិត និង ៤នាក់ទៀតរងរបួសដោយសារការបាញ់ប្រហារមកលើរថយន្តដឹកអ្នកដំណើរធុនតូច។
**ថ្ងៃទី ៨ ខែកក្កដា** គណកម្មការអង្កេតរុស្ស៊ីបានចាប់ផ្តើមស៊ើបអង្កេតករណីចាប់ពង្រត់ និង ធ្វើទារុណកម្មលើពលរដ្ឋរុស្ស៊ី អា. មីខាអ៊ីលលិនកូ នៅលើទឹកដីអ៊ុយក្រែន (ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៤) អា. មីខាអ៊ីលលិនកូបានធ្វើដំណើរពីរូស្តុស ទៅភូមិភាគឡូហានស្គ៍។ ក្នុងពេលកំពុងឆែកឆេរ នៅចំនុចត្រួតពិនិត្យក្នុងប្រទេសអ៊ុយក្រែន ឆ្មាំព្រំដែនបានរកឃើញរូបថតមួយសន្លឹកនៅក្នុងទូរស័ព្ទដៃរបស់លោក មីខាអ៊ីលម៉ាលិនកូដែលបានថតដោយក្នុងដៃមានកាន់កាំភ្លើងនៅក្នុងពិព័ណ៌បច្ចេកវិទ្យាអាវុធយុទ្ធភណ្ឌក្រុងមូស្គូ ក្នុងទិវាជ័យជំនះ ថ្ងៃ ៩ ឧសភា។ កងយោធា នៃកងអាសាស្ម័គ្រ « Dnep» បានដកហូតរបស់របរដែលជាកម្មសិទ្ធរបស់លោក ។ ពួកគេបានសួរចម្លើយ វាយតប់ និងធ្វើទារុណកម្មគាត់អស់មួយសប្តាហ៏។ នៅពេលពួកគេប្រាកដថា លោក មីខាអ៊ីលលិនកូ មិនមែនជាទាហាន គាត់ត្រូវបានគេដឹកទៅបោះចោលនិងចងភ្ជាប់ទៅនឹងដើមឈើ។ លោកបានរួចផុតមានសេរីភាពនិងបានត្រលប់មក Rostov ក្នុងប្រទេសរុស្ស៊ី។
**ថ្ងៃទី៨ខែកក្កដា** តំបន់ឡូហានស្គ៍ ទទួលការបាញ់ផ្តក់ដោយកងទ័ពអ៊ុយក្រែនដោយបានបំផ្លិចបំផ្លាញលំនៅដ្ឋានដែលស្ថិតនៅវិថី Suhodolskaya។ ជាន់ទី ៨ និង ៩ នៃលំនៅដ្ឋានបានទទួលការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ហើយគ្រួសារចំនួនបីត្រូវបានគេជម្លៀសដើម្បីសុវត្ថិភាព។
**ថ្ងៃទី៨ ខែកក្កដា** (ម៉ោងប្រហែល ១៩:៣០) នៅក្នុងសង្កាត់ Kuibyshev នៃភូមិភាគ Rostov ៨០០ ម៉ែត្រពីព្រំដែនរុស្ស៊ី-អ៊ុយក្រែន មានការផ្ទុះគ្រាប់មីនមួយគ្រាប់ដែលត្រូវគេកប់នៅជិតដែនដីអ៊ុយក្រែន។ ការខូចខាតជាច្រើនប៉ះពាល់កម្មសិទ្ធអ្នកស្រុក រួមទាំងកសិដ្ឋានផងដែរ។
**ថ្ងៃទី ៩ ខែកក្កដា** កងកម្លាំងយោធាអ៊ុយក្រែនបានបើកកាបាញ់ផ្តក់ទៅលើលំនៅដ្ឋាននៃក្រុង Seversk (វិថី ពូស្គីន និង សង្កាត់ Chernogolovka) ។
**ថ្ងៃទី ៩ ខែកក្កដា** នៅឡូហានស្គ៍ ស្ត្រីចំណាស់បានស្លាប់ដោយសាររងរបួសនៅក្នុងផ្ទះរបស់ខ្លួន ហើយមនុស្ស៦នាក់ទៀតរងរបួសដោយសារការបាញ់ផ្តក់ពីកងទ័ពអ៊ុយក្រែន។
**ថ្ងៃទី ៩ ខែ កក្កដា** អគ្គព្រះរាជអាជ្ញាអ៊ុយក្រែន វ. យ៉ារេម៉ា បានបញ្ជាក់ថា តាំងពីខែកុម្ភៈ ឆ្នាំ ២០១៤ មានករណីឧក្រិដ្ឋកម្មចំនួន ១៥៨ ត្រូវបានគេប្រព្រឹត្តក្នុងទីលានម៉ៃដាន់។ យោងតាមការបញ្ជាក់របស់លោក ៤នាក់បានបាត់បង់ជីវិត ប្លន់១៤ករណី ចោរកម្មមានចំនួន ៧៣ករណី ការបង្ករបួសស្នាម១៨

ករណី  ករណីនៃការប្រើប្រាស់យានយន្តមិនត្រឹមត្រូវ ការបន្លំ ការផលិតគ្រឿងញៀន ការប្រើប្រាស់អាវុធនិងបាញ់បោះដោយខុសច្បាប់មិនត្រូវបានគេចាត់វិធានការណ៍ក្នុងកំឡុងពេលនេះ។
**ថ្ងៃទី ១០ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានប្រើប្រាស់កាំភ្លើងត្បាល់ ៨០ ម.ម. និង ១២២ ម.ម. បាញ់ផ្ដក់ទៅលើ
Severodonetsk ។ គ្រាប់បានធ្លាក់ត្រូវចំផ្ទះអ្នកស្រុក ហើយបានបណ្ដាលអោយស្រ្តីម្នាក់ដែលរស់នៅទីនោះត្រូវបញ្ជូនទៅមន្ទីរពេទ្យដោយសារគាំងបេះដូង។
**ថ្ងៃទី ១០ ខែកក្កដា** កងទ័ពអាកាសអ៊ុយក្រែនបានបើកការបាញ់ទៅលើទីប្រជុំជន Izvarino,Rovenki, Saur-Mogila (ភូមិភាគឡូហានស្គ៍) និង Karlovka (ភូមិភាគដូញៀតស្គ៍) ។
**ថ្ងៃទី ១០ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានបាញ់មកលើតំបន់ត្រួតពិនិត្យ «Gukovo» (ភាគ Rostov) ព្រំដែនរុស្ស៊ី-អ៊ុយក្រែន ដែលពេលនោះមានជនភៀសខ្លួនចំនួន ២៣០ នាក់កំពុងឆ្លងកាត់ពីដែនដីអ៊ុយក្រែនចូលក្នុងប្រទេសរុស្ស៊ី។
**ថ្ងៃទី ១០ ខែកក្កដា** នៅក្នុងតំបន់ Chervonopartisansk (ភូមិភាគ ឡូហានស្គ៍) ជនស៊ីវិលចំនួន ១២ នាក់ បានបាត់បង់ជីវិត និង ៣០នាក់រងរបួសដែលបណ្ដាលមកពីការផ្ទុះអាវុធដាក់គ្នារវាងក្រុមអ្នកតស៊ូ និង កងទ័ពអ៊ុយក្រែន។ ក្នុងចំនោមអ្នកបាត់បង់ជីវិត មានក្មេងជំទង់អាយុ ១៧ឆ្នាំ និង ស្ត្រី២នាក់ និងកម្មកររុករករ៉ែ៤នាក់ដែលកំពុងធ្វើដំណើរទៅធ្វើការដោយរថយន្តក្រុង។
**ថ្ងៃទី ១១ ខែ កក្កដា** នៅ ឡូហានស្គ៍ (Lugansk)  កងទ័ពអ៊ុយក្រែនបានបាញ់ផ្ដក់ទៅលើមន្ទីរព្យាបាលដែលបណ្ដាលអោយជនស្លូតត្រង់ ៤នាក់បានបាត់បង់ជីវិត។
**ថ្ងៃទី ១២ ខែ កក្កដា** មានមនុស្ស ៥នាក់បានបាត់បង់ជីវិត និង ២នាក់បានរងរបួសដោយសារការបាញ់ដោយកាំភ្លើងត្បាល់មកលើគ្លីនីកបង្ការរោគពីសំណាក់កងទ័ពអ៊ុយក្រែន នៅក្នុងទីប្រជុំជន Golmovskiy (ភូមិភាគដូញៀតស្គ៍)។
**ថ្ងៃទី ១២ ខែ កក្កដា** ដោយសារការបាញ់ប្រហារពីសំណាក់កងទ័ពអ៊ុយក្រែនមកលើទីប្រជុំជន « Trudovskaya » (ភូមិភាគដូញៀតស្គ៍) បានបណ្ដាលអោយស្លាប់មនុស្សចំនួន ១២នាក់។
**ថ្ងៃទី ១២ ខែ កក្កដា** នៅឡូហានស្គ៍ ក្នុងពេលប្រយុទ្ធគ្នា កងទ័ពអ៊ុយក្រែនបានសម្លាប់ប្រជាជនស្លូតត្រង់ចំនួន ៦ នាក់ ៨ នាក់រងរបួស។
**ថ្ងៃទី ១២ ខែ កក្កដា** នៅ Marinka ជាយក្រុងដូញៀតស្គ៍ ដោយសារការបាញ់កាំភ្លើងត្បាល់ពីសំណាក់កងទ័ពអ៊ុយក្រែនបានបណ្ដាលអោយមនុស្សចំនួន ៦នាក់ស្លាប់បាត់បង់ជីវិត។ គ្រាប់បានធ្លាក់ចំផ្ទះមួយខ្នងដែលបានសម្លាប់គ្រួសារមួយដែលមានសមាជិក ៣នាក់។
**ថ្ងៃទី ១៣ ខែ កក្កដា** កងទ័ពអ៊ុយក្រែនបានបាញ់ប្រហារមកលើភូមិភាគ Rostov ដោយអាវុធមានរំសេវផ្ទុះកំរិតខ្ពស់ ហើយដែលបណ្ដាលអោយជនជាតិរុស្ស៊ីអាយុ ៤៦ ឆ្នាំ ដែលមានកូនតូចអាយុ ៤ឆ្នាំបានស្លាប់បាត់បង់ជីវិត។ ស្ត្រីម្នាក់ផ្សេងទៀត អាយុ ៥៥ឆ្នាំ បានរងរបួសនៅត្រង់ជើងដោយបំនែកគ្រាប់។ ផ្ទះពីរខ្នង ត្រូវបានបំផ្លាញ់ និង បំពង់បង្ហូរឧស្ម័នត្រូវបានបំផ្លាញ ហើយខ្សែបណ្ដាញអគ្គិសនីខូចខាតមិនអាចប្រើប្រាស់បាន។

**ថ្ងៃទី ១៣ ខែ កក្កដា** ក្នុងសកម្មភាពទម្លាក់គ្រាប់បែកដោយកងទ័ពអាកាសអ៊ុយក្រែននៅសង្កាត់ ពេត្រូវ Petrovsky នៃភូមិភាគ ដូញៀតស្គ័ បានសម្លាប់ប្រជាជនស្លូតត្រង់ ៦នាក់ និង ៨នាក់រងរបួសដែលក្នុងនោះមានក្មេងជំទង់ម្នាក់។
**ថ្ងៃទី ១៣ ខែកក្កដា** នៅ Krasnogorovka (ភូមិភាគដូញៀតស្គ័) គ្រាប់កាំភ្លើងត្បាល់របស់កងទ័ពអ៊ុយក្រែនបានបំផ្លិចបំផ្លាញផ្ទះសំបែង និង អ្នករស់នៅទីនោះ ២នាក់បានស្លាប់បាត់បង់ជីវិត។
**ថ្ងៃទី ១៣ ខែ កក្កដា** នៅ ឡូហានស្គ័ ដោយសារការបាញ់ផ្គត់ពីសំណាក់កងទ័ពអ៊ុយក្រែនបានបណ្តាលដោយប្រជាជនស្លូតត្រង់៣នាក់ស្លាប់បាត់បង់ជីវិត និង ១៤នាក់ទៀតរងរបួស។
**ថ្ងៃទី ១៥ ខែកក្កដា** នៅឡូហានស្គ័ ដោយសារការបាញ់ប្រហារពីសំណាក់កងទ័ពអ៊ុយក្រែនបានសម្លាប់ប្រជាជនស្លូតត្រង់ ៨នាក់ ដែលក្នុងនោះទារកតូចម្នាក់ផងដែរ ហើយ មនុស្ស ៥២ នាក់បានរងរបួសដែលមានក្មេងតូច ៤នាក់។
**ថ្ងៃទី ១៥ ខែកក្កដា** យន្តហោះ Su 25 នៃកងទ័ពអាកាសអ៊ុយក្រែនបានបាញ់គ្រាប់រ៉ុក្កែតមកលើភាគកណ្តាលនៃទីក្រុង Snezhnoe (ភូមិភាគ ដូញៀតស្គ័)។ ជាលទ្ធផល បានបណ្តាលអោយអគារត្រួតពិនិត្យពន្ធគយត្រូវខូចខាតយ៉ាងដំណំ និង ផ្ទះសម្បែងនៅតាមបណ្តោយវិថី លេនីនស្គី ត្រូវបំផ្លាញហើយ មនុស្ស ៥ នាក់បានបាត់បង់អាយុជីវិត និង មិនតិចជាង ១០នាក់រងរបួសពីការបាញ់នេះ។
**ថ្ងៃទី ១៥ ខែកក្កដា** នៅឡូហានស្គ័ កងទ័ពអ៊ុយក្រែនបានបាញ់ផ្តល់មកលើទីក្រុង ដែលបានបណ្តាលអោយប្រជាជនស្លូតត្រង់ ម្នាក់ និង រងរបួសធ្ងន់ ៩នាក់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ។
**ថ្ងៃទី ១៥ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានប្រើប្រាស់ប្រព័ន្ធបាញ់រ៉ុក្កែត «Grad» សំដៅទៅលើភូមិ Dmitrovka (ភូមិភាគ ដូញៀតស្គ័) ដោយបានសម្លាប់ប្រជាជនស្លូតត្រង់ ៩នាក់។
**ថ្ងៃទី ១៦ ខែកក្កដា** គ្រាប់កាំភ្លើងត្បាល់ពីរគ្រាប់ដែលបានបាញ់ពីដែនដីអ៊ុយក្រែនបានធ្លាក់មកលើតំបន់ Rostov នៃប្រទេសរុស្ស៊ី ក្នុងទីប្រជុំជនក្បែរតំបន់ត្រួតពិនិត្យ "Kuibishevo" ។
**ថ្ងៃទី ១៦ខែកក្កដា** កងទ័ពអ៊ុយក្រែននៅតែបន្តការបាញ់ផ្គត់ក្នុងទ្រង់ទ្រាយធំមកលើផ្ទះសម្បែង និងតំបន់ទីប្រជុំជននៃភូមិភាគ ឡូហានស្គ័ ដែលបានបំផ្លិចបំផ្លាញផ្ទះ ២២ ខ្នងដែលបណ្តាលមកពីអគ្គីភ័យ និង មនុស្ស ៨នាក់ផ្សេងទៀតបានទទួលរងរបួស។
**ថ្ងៃទី ១៧ ខែកក្កដា** ជនស៊ីវិលពីរនាក់បានស្លាប់ និង ៤នាក់ទៀតរងរបួសដែលបណ្តាលមកពីការបាញ់ប្រហារដោយកងយោធាអ៊ុយក្រែននៅឡូហានស្គ័។
**ថ្ងៃទី ១៧ ខែកក្កដា** នៅក្បែរភូមិ Grabovo ចំងាយ ៨០គីឡូម៉ែត្រពីភូមិភាគ ដូញៀតស្គ័ យន្តហោះប៊ូអ៊ីងម៉ាឡេស៊ី ៧៧៧ ជើងហោះហើរលេខ MH 17 ដែលធ្វើដំណើរពីអាមស្ទើរដាម ទៅកូឡាឡាំពួរបានធ្លាក់។ អ្នកជិះនៅក្នុងយន្តហោះទាំងអស់ ២៩៨ (២៨៣ ជាអ្នកដំណើរ និង ១៥នាក់ជាបុគ្គលិកយន្តហោះ)បានស្លាប់ថ្ងៃទី ១៨ ខែកក្កដា នៅជាយក្រុង Severodonetsk កងទ័ពអ៊ុយក្រែនបានសំលាប់អ្នកស្រុកចំនួន ៤នាក់។

**ថ្ងៃទី ១៨ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានវាយប្រហារមកលើភូមិភាគឡូហានស្គ៍សារជាថ្មីម្តងទៀត។ ការបាញ់ផ្តក់ជាច្រើនត្រូវបានធ្វើឡើងនៅក្នុងស្រុកជាច្រើននៃទីក្រុង ដែលបានសម្លាប់ជនស៊ីវិល ១៩ នាក់ និង ១០១នាក់ទៀតរងរបួស។

**ថ្ងៃទី ១៨ ខែកក្កដា** មានការប្រយុទ្ធគ្នានៅក្បែរព្រលានយន្តហោះដូញៀតស្គ៍ ដែលបានបណ្តាលអោយផ្ទះសម្បែងមួយខ្នងនៅក្បែរវិថី Nezhinskaya ត្រូវរងគ្រាប់កាំភ្លើងធំ។ មនុស្សម្នាក់បានបាត់បង់ជីវិតនៅក្នុងព្រឹត្តិការណ៍នេះ។

**ថ្ងៃទី ១៨ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានបាញ់ផ្តក់មកលើភូមិភាគឡូហានស្គ៍ ដែលបានបណ្តាលអោយមានជនរងគ្រោះចំនួន ១៣នាក់។

**ថ្ងៃទី ១៩ ខែកក្កដា** យោងតាមរបាយការដែលបោះពុម្ពផ្សាយដោយបេសកម្មពិនិត្យរបស់អង្គការសន្តិសុខ និង សហប្រតិបត្តិការអ៊ឺរ៉ុប (OSCE) បានអោយដឹងថា មនុស្ស ២៥០ នាក់ត្រូវបានសម្លាប់ និង ៨៥០នាក់រងរបួសក្នុងចំណោមប្រជាជនស៊ីវិលនៅភូមិភាគឡូហានស្គ៍ ចាប់ពីដើមខែមិថុនា ២០១៤ ដោយពុំបានរាប់បញ្ចូលអ្នកដែលបានស្លាប់នៅក្នុងតំបន់នៃការប្រយុទ្ធគ្នានៅជាយក្រុងនិងអ្នកចូលរួមប្រយុទ្ធ។ ក្នុងនោះដែរ ជនរងគ្រោះដោយសារជាន់មីនក៏ត្រូវបានរាយការណ៍អោយដឹងផងដែរ។

**ថ្ងៃទី ១៩ ខែកក្កដា** គ្រាប់កាំភ្លើងត្បាល់បានធ្លាក់លើភូមិភាគ ដូញៀតស្គ៍ដោយបានបំផ្លាញផ្ទះចំនួនពីរខ្នង និងមានជនស៊ីវិល៤នាក់រងរបួស។

**ថ្ងៃទី ២០ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានបាញ់ផ្តក់គ្រាប់បែកក្នុងទ្រង់ទ្រាយធំមកលើភាគកណ្តាលនៃតំបន់ឡូហានស្គ៍ ដោយកាំភ្លើងត្បាល់ និង កាំភ្លើងធំ។ ជនស៊ីវិល២នាក់បានបាត់បង់ជីវិត និង ១២នាក់រងរបួស។

**ថ្ងៃទី ២១ ខែកក្កដា** ទាហានអ៊ុយក្រែនបានបើកការវាយប្រហារមកលើភូមិភាគ ដូញៀតស្គ៍ ដោយប្រើប្រាស់កាំភ្លើងធំធុនធ្ងន់ និង រថក្រោះ។ ជនស៊ីវិល ៥នាក់បានបាត់បង់ជីវិត និង ១៦នាក់ផ្សេងទៀតបានរងរបួស។

**ថ្ងៃទី ២១ ខែកក្កដា** ប្រតិភូអ្នកជំនាញម៉ាឡេស៊ី ១២នាក់ និង មន្ត្រីមួយចំនួនបានព្យាយាមចូលពីភូមិភាគដូញៀតស្គ៍ទៅដល់កន្លែងដែលយន្តហោះប៊ូអ៊ីង ៧៧៧ ធ្លាក់ ប៉ុន្តែបេសកកម្មនេះត្រូវបានបោះបង់ និងត្រូវបង្ខំចិត្តវិលត្រលប់មកភូមិភាគដូញៀតស្គ៍វិញដោយសារទីនោះជាតំបន់ដែលកងទ័ពអាកាសអ៊ុយក្រែនតែងបាញ់និង ទម្លាក់គ្រាប់បែក។

**ថ្ងៃទី ២១ ខែកក្កដា** ក្រសួងការពារជាតិរុស្ស៊ីបានផ្តល់នូវភស្តុតាងដែលបានបង្ហាញអោយដឹងថា ក្នុងកំឡុងពេលធ្លាក់យន្តហោះម៉ាឡេស៊ី MH ១៧ គេឃើញមានរថយន្តផ្ទុកមីស៊ីលប្រឆាំងនឹងយន្តហោះ "Buk" ដែលជារបស់កងទ័ពអ៊ុយក្រែនមានជាប់ពាក់ព័ន្ធក្នុងឧបទ្ទវហេតុធ្លាក់យន្តហោះនេះ។ ក្នុងនោះដែរ គេក៏សង្កេតឃើញផងដែរយន្តហោះប្រដេញ Su-២៥ អ៊ុយក្រែនក៏មានវត្តមានប៉ុន្មានគីឡូម៉ែត្រពីយន្តហោះប៊ូអ៊ីង។ព័ត៌មានពិស្តារ រួមទាំងរូបថតដែលថតបានពីផ្កាយរណប អាចរកបាននៅលើគេហទំព័រនៃក្រសួងការពារជាតិសហព័ន្ធរុស្ស៊ី ដូចខាងក្រោម ៖
http://function.mil.ru/news_page/country/more.htm?id=11970654@egNews.

**ថ្ងៃទី ២១-២២ កក្កដា (ពេលយប់)** កងទ័ពអ៊ុយក្រែនបានបាញ់ផ្គត់មកលើ Lisichiansk (ភូមិភាគឡូហានស្ក៍)
ដោយប្រើប្រាស់នូវកាំភ្លើងធុនធំបាញ់គ្រាប់រ៉ុក្កែត និង កាំភ្លើងត្បាល់ ដែលរួមទាំង ប្រព័ន្ធបាញ់គ្រាប់រ៉ុក្កែត "Grad" ។ ជនស៊ីវិល ៣នាក់បានបាត់បង់ជីវិត និង ១០នាក់បានរងរបួស។
**ថ្ងៃទី ២២ ខែកក្កដា** នៅ Gorlovka (ភូមិភាគ ដូញៀតស្ក៍) កងទ័ពអ៊ុយក្រែនបានបាញ់មកលើ Michurinskaya ដោយកាំភ្លើងត្បាល់ដែលបានបណ្តាលអោយមនុស្សពីរនាក់បានស្លាប់ និង ៣នាក់បានរងរបួស។
**ថ្ងៃទី ២២ ខែកក្កដា** នៅ Krasnogorovka (ភូមិភាគដូញៀតស្ក៍) ក្មេងស្រីអាយុ ៩ឆ្នាំម្នាក់បានស្លាប់ដោយសារការបាញ់ផ្គត់មកលើផ្ទះសម្បែង។
**ថ្ងៃទី ២៣ ខែកក្កដា** កងទ័ពអាកាសអ៊ុយក្រែនបានបើកការបាញ់ប្រហារមកលើភូមិភាគ ដូញៀតស្ក៍ ដោយប្រើគ្រាប់បែកផូស្វ័រ ដែលបណ្តាលអោយខូចខាតទាំងស្រុងផូស្វ័រ។
**ថ្ងៃទី ២៤ ខែកក្កដា** ប្រធាននាយកដ្ឋានស៊ើបអង្កេតបទឧក្រិដ្ឋពាក់ព័ន្ធនឹងការហាមឃាត់ការប្រើប្រាស់អាវុធនិងយុទ្ធសាស្ត្រនានាក្នុងសង្គ្រាម នៃគណកម្មាធិការស៊ើបអង្កេតនៃសហព័ន្ធរុស្ស៊ី លោក A.A. Drymanov បានអោយដឹងថា ភស្តុតាងនៃការប្រើគ្រាប់ផូស្វ័រ ដែលត្រូវបានហាមឃាត់ដោយច្បាប់មនុស្សធម៌អន្តរជាតិ ប្រឆាំងទៅនឹងប្រជាជនស៊ីវិលដោយរដ្ឋអំណាចអ៊ុយក្រែនក្នុងភាគខាងត្បូង-កើតអ៊ុយក្រែន។
**ថ្ងៃទី ២៤ ខែកក្កដា** ក្នុងភូមិភាគ ឡូហានស្ក៍ កងទ័ពអ៊ុយក្រែនបានសម្លាប់ជនស៊ីវិលម្នាក់ និង រងរបួស ៨នាក់ផ្ទះចំនួន ១២ខ្នង ត្រូវបានបំផ្លិចបំផ្លាញ ដោយគ្រាប់កាំភ្លើងធំ។
**ថ្ងៃទី ២៥ ខែកក្កដា** ក្នុងភូមិភាគឡូហានស្ក៍ កងទ័ពអ៊ុយក្រែនបានសម្លាប់ជនស៊ីវិល ១២នាក់ និងរងរបួស ៧នាក់។
**ថ្ងៃទី ២៥ ខែកក្កដា** នៅភូមិភាគដូញៀតស្ក៍ ជនស៊ីវិលម្នាក់បានស្លាប់ និង ២នាក់រងរបួសដោយសារការបាញ់ប្រហារពីសំណាក់ទាហានអ៊ុយក្រែន។
**ថ្ងៃទី ២៥ ខែកក្កដា** សកម្មជនមកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្សបានអោយដឹងថា យោងតាមការស្ទង់មតិ ជាការពិតណាស់ដែលកងទ័ពអ៊ុយក្រែនកំពុងប្រើប្រាស់ប្រព័ន្ធបាញ់គ្រាប់រ៉ុក្កែត "Grad" ប្រឆាំងនឹងសង្កាត់នានា និង តំបន់ជាយក្រុងនៃភូមិភាគដូញៀតស្ក៍ដែលគ្រប់គ្រងដោយកម្លាំងអ្នកប្រយុទ្ធ។
**ថ្ងៃទី ២៦ ខែកក្កដា** ក្រសួងការពារជាតិរុស្ស៊ីបានផ្សព្វផ្សាយទិន្នន័យជាសាធារណៈករណីនៃការប្រើប្រាស់គ្រាប់បែកចង្កោមនិងគ្រាប់ផូស្វ័រនៅដែនដីខាងត្បូង-កើតអ៊ុយក្រែន និង រួមទាំងករណីនៃប្រើប្រាស់ប្រឆាំងនឹងជនស៊ីវិល។
**ថ្ងៃទី ២៥ កក្កដា** គ្រាប់កាំភ្លើងត្បាល់ជាច្រើនបានធ្លាក់ចូលក្នុងទឹកដីរុស្ស៊ីដែលបានបាញ់ពីខាងទឹកដីអ៊ុយក្រែន។នៅ Khutor Primiussky (Kuibishevsky សង្កាត់របស់ភូមិភាគ Rostov) គ្រាប់ត្បាល់

ប្រហែល ៥០គ្រាប់បានផ្ទុះ។ ក្រុមអ្នកផលិតភាពយន្ត នៃប៉ុស្តិ៍«ទូរទស្សន៍ ២៤» និង សមាជិកគណកម្មាការអង្កេតរុស្ស៊ីត្រូវទទួលរងការបាញ់ប្រហារពីសំណាក់កងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ២៥ ខែកក្កដា** អនុប្រធាននៃអគ្គបញ្ជាការដ្ឋានគ្រប់គ្រងប្រតិបត្តិការពិសេសនៃកងប្រដាប់អាវុធរុស្ស៊ី ឧត្តមសេនីយ៍ V. Poznihir បានផ្តល់នូវព័ត៌មានអំពីការប្រើប្រាស់អាវុធហាមប្រាម គ្រាប់បែកចង្កោម និង គ្រាប់ផូស្វ័រដោយកងកាំភ្លើងធំនិងកងអាកាសរបស់អ៊ុយក្រែនប្រឆាំងនឹងប្រជាពលរដ្ឋដែលរស់នៅភាគខាងត្បូង-កើតអ៊ុយក្រែន។ ជាពិសេស នៅថ្ងៃទី ១២ ខែ មិថុនា ក្នុងភូមិភាគ Slavyansk (មានការប្រើអាវុធផូស្វ័រ) ។ នៅថ្ងៃទី ២១ ក្នុងភូមិភាគ Slavyansk និង Kramatorsk (មានការប្រើអាវុធផូស្វ័រ)។ នៅថ្ងៃទី ២៤ មិថុនា នៅ Semenovka (មានការប្រើអាវុធផូស្វ័រ និង គ្រាប់បែកចង្កោម) ។ ថ្ងៃទី ២៩ ខែមិថុនា Semenovka (មានការប្រើអាវុធផូស្វ័រ) នៅថ្ងៃទី ៧ ខែ កក្កដា នៅ Lisichiansk (មានការប្រើអាវុធផូស្វ័រ)។ នៅថ្ងៃទី ២៣ ខែកក្កដា នៅភូមិភាគដូញៀតស្គ៍ (មានការប្រើអាវុធផូស្វ័រ) ។ការពិតដែលបានរៀបរាប់ខាងលើ ត្រូវបានបញ្ជាក់អះអាងដោយភស្តុតាងនៃសាក្សីដែលបានឃើញព្រឹត្តិការណ៍នេះផ្ទាល់ភ្នែកក្នុងចំណោមជនភៀសខ្លួន ពីតំបន់ទាំងនេះ រួមទាំងវីដេអូ និង រូបថតរបស់អ្នកសារព័ត៌មានដែលធ្វើការនៅភូមិភាគឡូហានស្គ៍ និង ដូញៀតស្គ៍។

**ថ្ងៃទី ២៦ ខែ កក្កដា** នៅភូមិភាគឡូហានស្គ៍ ជនស៊ីវិល ៩នាក់បានស្លាប់បាត់បង់ជីវិត និង ៤១នាក់បានរងរបួសដោយសារការបាញ់ប្រហាររបស់កងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ២៧ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានបាញ់មកលើ Gorlovka (ភូមិភាគដូញៀតស្គ៍) ដោយប្រើប្រាស់ប្រព័ន្ធបាញ់គ្រាប់រ៉ុក្កែត "Grad" ដែលបានធ្វើអោយមនុស្សស្លាប់ចំនួន ១៣ នាក់ ក្នុងនោះក៏មានកុមារពីរនាក់ផងដែរ (ម្នាក់អាយុ ១ ឆ្នាំ និង ម្នាក់ទៀត អាយុ ៥ឆ្នាំ) ហើយជនស៊ីវិលប្រហែល ៣០ នាក់បានរងរបួស។

**ថ្ងៃទី ២៧ កក្កដា** Avdeevka (ភូមិភាគ ដូញៀតស្គ៍) កងទ័ពអ៊ុយក្រែនបានបាញ់ផ្គក់ដែលបានបណ្តាលអោយអ្នកស្រុក ៥នាក់ស្លាប់បាត់បង់ជីវិត និង ប្រហែល ៥០នាក់ទៀតរងរបួស។

**ថ្ងៃទី ២៧-២៨ កក្កដា (ពេលយប់)** នៅដូញៀតស្គ៍ កងទ័ពអ៊ុយក្រែនបានសំលាប់ជនស៊ីវិល ៣នាក់ និង ១៥នាក់ផ្សេងទៀតរងរបួស។

ថ្ងៃទី ២៨ ខែកក្កដា នៅឡូហានស្គ៍ កងទ័ពអ៊ុយក្រែនបានបើកការវាយប្រហារដែលបានបណ្តាលអោយបាត់បង់ជីវិតមនុស្សចំនួន ៥នាក់ និង ១៥នាក់រងរបួស។

**ថ្ងៃទី ២៨ ខែកក្កដា** របាយការណ៍ផ្សេងទៀតរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សលោក N. Pillay បានគូសបញ្ជាក់ថា ការកើនឡើងនូវការស្លាប់បាត់បង់ជីវិតរបស់ជនស៊ីវិលស្លូតត្រង់ និង ការខូចខាតខ្ទេចខ្ទីផ្នែកហេដ្ឋារចនាសម្ព័ន្ធស៊ីវិលដែលបណ្តាលមកពីការប្រយុទ្ធនៅភាគខាងត្បូង-កើតប្រទេសអ៊ុយក្រែន អាចចាត់ទុកថាជាការរំលោភបំពានទៅលើច្បាប់មនុស្សធម៌អន្តរជាតិ។ យើងតាមអង្គការ OUNHCHR បានធ្វើការប៉ាន់ស្មានថា តាំងពីការចាប់ផ្តួលមនៃការប្រយុទ្ធដោយអាវុធអ៊ុយក្រែនចំនួនអ្នកស្លាប់មានរហូតដល់ ១១២៩ នាក់ និង រងរបួសជិត ៣.៥ ពាន់នាក់។

**ថ្ងៃទី ២៨ ខែកក្កដា** ដោយសារការបាញ់ផ្គត់ដោយកងទ័ពអ៊ុយក្រែនបានបណ្តាលអោយជនស៊ីវិល ១៧ នាក់ ដែលក្នុងនោះមានកុមារចំនួន ៣នាក់ត្រូវបានសម្លាប់ និង ៤៣នាក់រងរបួស។ គ្រាប់កាំភ្លើងធំបានធ្លាក់និងបានបំផ្លិចបំផ្លាញអគារសាលាមួយខ្នង។ គ្រាប់ដទៃទៀតបានធ្លាក់នៅលើបរិវេណមន្ទីរពេទ្យក្រុង នាយកដ្ឋានការងារបានទទួលការខូចខាតទាំងស្រុង។ ការកាន់ទុក្ខត្រូវបានគេប្រកាសធ្វើទូទាំងទីក្រុង។

**ថ្ងៃទី ២៩ កក្កដា** ដោយសារការទម្លាក់គ្រាប់បែកមកលើភូមិភាគឡូហានស្គ៍ ដោយកងទ័ពអ៊ុយក្រែនបានបណ្តាលអោយស្លាប់ជនស៊ីវិល ៥នាក់ និង ៨ នាក់រងរបួស។

**ថ្ងៃទី ២៩ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានចាប់ផ្តើមបើកការវាយលុកមកលើភាគកណ្តាលដូញៀតស្គ៍។ គ្រាប់ផ្លោងបានធ្លាក់ចំ courtyard និងលំនៅដ្ឋានជាច្រើន។ ក្នុងនោះដែរ គ្រាប់ផ្លោងបីគ្រាប់បានធ្លាក់ចំសួនឧទ្យានវប្បធម៌។ ប្រជាពលរដ្ឋបានរួចទៅលាក់ខ្លួននៅក្នុងជម្រកការពារគ្រាប់បែករួម ។យ៉ាងហោចណាស់ ជនស៊ីវិល ៣នាក់បានស្លាប់បាត់បង់ជីវិត និង ១៥នាក់រងរបួស។

**ថ្ងៃទី ២៩ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានបើកការវាយលុកទៅលើឡានក្រុងដែលដឹកជនភៀសខ្លួនពី Gorlovka ក្នុងភូមិ Rassypnoe (ភូមិភាគដូញៀតស្គ៍)។ កុមារអាយុ ៣ឆ្នាំបានស្លាប់បាត់បង់ជីវិត និង អ្នកដំណើរ ១២នាក់បានរងរបួស ដែលក្នុងចំណោមនោះមានកុមារអាយុ ៥ឆ្នាំ និង ១១ ឆ្នាំផង។

**នៅថ្ងៃទី ២៩ ខែ កក្កដា** ក្នុងភូមិ Berestovoe (ភូមិភាគដូញៀតស្គ៍)មានការផ្ទុះគ្រាប់មីនមួយគ្រាប់បានបណ្តាលអោយមនុស្ស ៩នាក់ (មានកុមារ ៣នាក់ ក្នុងនោះម្នាក់មានអាយុ ១ឆ្នាំ២ខែ) រងរបួសយ៉ាងធ្ងន់ធ្ងរ។ មនុស្សចាស់ពីរនាក់បានស្លាប់បាត់បង់ជីវិតក្នុងមន្ទីរពេទ្យ។

**ថ្ងៃទី ២៩ កក្កដា** កងទ័ពអ៊ុយក្រែនបានបើកការវាយប្រហារមកលើក្នុងភូមិ Novosvetlanovka ដោយប្រើប្រព័ន្ធបាញ់រ៉ុក្កែត «Grad»។

**ថ្ងៃទី ២៩ កក្កដា** នៅត្រង់កន្លែងត្រួតពិនិត្យព្រំដែនរុស្ស៊ី Gukovo បានទទួលការវាយប្រហារពីអ៊ុយក្រែនចំនួនពីរដង។ គ្រាប់កាំភ្លើងធំបានធ្លាក់ចំលើអគារកន្លែងត្រួតពិនិត្យនោះ។ នៅពេលរសៀល កងទ័ពអ៊ុយក្រែនបានបើកការបាញ់ប្រហារសំដៅសម្លាប់ប្រធានការិយាល័យរដ្ឋបាលពន្ធគយភាគខាងត្បូង លោក R.N. Faroukshin និង ប្រធានតំបន់ត្រួតពិនិត្យ A.V. Pleskunov ដោយប្រើប្រាស់នៅកាំភ្លើងផ្គត់ grenade launchers ។

**ថ្ងៃទី ២៩ ខែកក្កដា** ប៉ុស្តិ៍ទូរទស្សន៍ ស៊ីអិនអិន បានរាយការណ៍អោយដឹងថា កងទ័ពអ៊ុយក្រែនបានប្រើប្រាស់គ្រាប់រ៉ុក្កែត បាលីស្ទិកចម្ងាយខ្លីបាញ់ប្រហារទៅលើក្រុមជីវពលអ៊ុយក្រែនភាគខាងត្បូង-កើត។ ព័ត៌មាននេះត្រូវបានផ្តល់អោយដោយអ្នកផ្សព្វផ្សាយទូរទស្សន៍ដែលបញ្ជាក់អះអាងដោយរដ្ឋការអាមេរិក។ អ្នកកាសែតអាមេរិកបានកំណត់យ៉ាងច្បាស់ថា ប្រភេទគ្រាប់រ៉ុក្កែតនេះអាចបាញ់ចំគោលដៅក្នុងចំងាយ ៨០ គីឡូម៉ែត្រ និង អាចពាំក្បាលគ្រាប់ទំងន់ ៤៥៤គីឡូក្រាមឡើងទៅ។

ថ្ងៃទី ៣០ ខែកក្កដា មានមនុស្ស ១៩នាក់ និង ៣១នាក់បានរងរបួសដែលបណ្តាលមកពីការវាយប្រហាររបស់កងទ័ពអ៊ុយក្រែនមកលើភូមិភាគ ដូញៀតស្គ៍។ ជនស៊ីវិល ម្នាក់បានស្លាប់បាត់បង់ជីវិត និង ១០នាក់ទៀតបានរងរបួសនៅភូមិភាគ ឡូហានស្គ៍។

**ថ្ងៃទី ៣០ ខែកក្កដា** នៅក្នុង Gorlovka ក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីការបាញ់ផ្គត់ដោយគ្រាប់រ៉ុក្កែត និង កាំភ្លើងត្បាល់ពីសំណាក់កងទ័ពអ៊ុយក្រែន មានជនស៊ីវិលចំនួន ២៧នាក់ត្រូវបានសម្លាប់ (ក្នុងនោះ មាន កុមារ ៤នាក់ផងដែរ) និង ជាង ១០០នាក់រងរបួស។

**នៅថ្ងៃទី ៣១ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានទម្លាក់គ្រាប់បែកនៅភូមិភាគឡូហានស្គ៍ដោយបាន សម្លាប់ជនស៊ីវិលចំនួន ៣នាក់ (ក្មេងជំទង់អាយុ ១៥ឆ្នាំម្នាក់) និង ៧នាក់រងរបួស។

**ថ្ងៃទី ២ ខែសីហា** នៅភូមិភាគឡូហានស្គ៍ កងទ័ពអ៊ុយក្រែនបានបើកការវាយប្រហារដោយកាំភ្លើងធំមក លើទីក្រុង Pervomaysk និង សាលាមួយខ្នងនៅ ដូញៀតស្គ៍ (បុរសនិងស្ត្រីពីរនាក់បានស្លាប់)។

**ថ្ងៃទី ២ ខែកក្កដា** នៅ Donbass មានការដោះដូរអ្នកទោស និង សាកសពរវាងកងទ័ពអ៊ុយក្រែន និង ពួកជីវពលយោងតាមអ្នកតំណាងសាធារណរដ្ឋដូញៀតស្គ៍បានអោយដឹងថា មានស្លាកស្នាមធ្វើ ទារុណកម្មនៅលើសាកសពចំនួន ៣ ក្នុងចំនោម ១២សាកសពនៃប្រជាការពារសាធារណរដ្ឋដូញៀត ស្គ៍។ លើសពីនេះទៅទៀត ភាគច្រើននៃកងជីវពលដែលត្រូវគេចាប់បាន បាក់ឆ្អឹង និង ត្រូវគេវាយ បំបាក់ផ្នែកខាងក្នុងនៃរាងកាយ។

**ថ្ងៃទី ៣ ខែ សីហា** មានការប្រយុទ្ធគ្នានៅ ជាយក្រុង ដូញៀតស្គ៍ Marynka និង Aleksandrovka ពេញមួយយប់។ប្រព័ន្ធបាញ់រ៉ុក្កែត «Grad»និង Howitzers ត្រូវបានគេប្រើប្រាស់។

**ថ្ងៃទី ៣ ខែសីហា** ជនស៊ីវិល ៣នាក់បានស្លាប់ នឹង ៨នាក់ទៀតបានរងរបួសដោយសារការទម្លាក់គ្រាប់ បែកនៅឡូហានស្គ៍។

**ថ្ងៃទី៣ ខែសីហា** គ្រាប់មីនមួយគ្រាប់ពីទឹកដីអ៊ុយក្រែនបានផ្ទុះនៅក្បែរ «Gukovo» តំបន់ត្រួតពិនិត្យព្រំ ដែនក្នុងតំបន់ Rostov នៃប្រទេសរុស្ស៊ី ទីកន្លែងដែលសមាជិកគណកម្មាការអង្កេត OSCE កំពុងធ្វើ ការពិនិត្យ។

**ថ្ងៃទី ៥ ខែសីហា** នៅភាគខាងលិចនៃភូមិភាគដូញៀតស្គ៍ ក្នុងកំឡុងពេលប្រយុទ្ធគ្នាបានបណ្តាលអោ យខូចខាតហេដ្ឋារចនាសម្ព័ន្ធ និង ជនស៊ីវិលបីនាក់បានស្លាប់បាត់បង់ជីវិត។

**ថ្ងៃទី ៥ ខែសីហា** កងទ័ពអ៊ុយក្រែនបានបើកការបាញ់សន្ធប់មកលើតំបន់ Gorlovka ដែលបានបណ្តា លអោយជនស៊ីវិលម្នាក់បានស្លាប់ និង ៤នាក់រងរបួស។

**ថ្ងៃទី ៦ ខែសីហា** គ្រួសារមួយដែលមានសមាជិក ៥នាក់ត្រូវបានសម្លាប់ដោយសារការបាញ់ផ្គត់កាំភ្លើង ធំមកលើសង្កាត់ Pervomaysk (ភូមិភាគឡូហានស្គ៍) ហើយមនុស្សជាច្រើននាក់ទៀតបានស្លាប់ បាត់បង់ជីវិតដោយសារគ្រាប់បានធ្លាក់ចំផ្សារមួយកន្លែងក្នុងក្រុង។

**ថ្ងៃទី ៦ ខែសីហា** កងទ័ពអ៊ុយក្រែនបានបាញ់ផ្គត់មកលើតំបន់ Gorlovka ដែលបានធ្វើអោយជនស៊ីវិល ៣៣នាក់ បានស្លាប់និង ១២៩នាក់បានរងរបួស។

**ថ្ងៃទី ៧ខែសីហា** កងទ័ពអ៊ុយក្រែនបានបាញសន្ធប់មកលើភូមិភាគដូញៀតស្គ៍មួយយប់ពេញដោយបាន បំផ្លិចបំផ្លាញមន្ទីរពេទ្យនៅសង្កាត់ Kalininsky នៃទីក្រុងដែលបានសម្លាប់មនុស្សម្នាក់ និង ៥នាក់ រងរបួស។

**ថ្ងៃទី ៧ សីហា** ជនស៊ីវិល ៥នាក់ត្រូវបានសម្លាប់ នៅ Gorlovka កំឡុងនៃការវាយប្រហារដោយកាំភ្លើងធំមកលើក្រុង ដែលបានបណ្តាលអោយមនុស្ស ១០នាក់រងរបួស។
**ថ្ងៃទី ៧ សីហា** ក្នុងកំឡុងពេលបាញ់ប្រហារមកលើភូមិភាគ ដូញៀតស្គ៍ គ្រាប់កាំភ្លើងធំមួយគ្រាប់បានធ្លាក់ចំទីលានទាត់បាល់របស់សាលាមួយ ដែលបណ្តាលអោយមនុស្ស ៣នាក់ រងរបួសជាទម្ងន់។ មុននេះកន្លែងទទួលអ្នកជម្ងឺរបស់មន្ទីរពេទ្យមួយ និង ផ្ទះជាច្រើនប្លុក ព្រមទាំងរថយន្តក្រុងត្រូវបានបាញ់ប្រហារ។ ជនស៊ីវិល ៤នាក់បានស្លាប់បាត់បង់ជីវិត និង ១៨នាក់រងរបួស។
**ថ្ងៃទី ៧ ខែសីហា** ដោយសារការបាញ់ផ្គត់គ្រាប់កាំភ្លើងធំមកលើភូមិភាគដូញៀតស្គ៍ និង Mospino ដែលបង្កឡើងដោយកងទ័ពអ៊ុយក្រែន ជនស៊ីវិល២នាក់បានស្លាប់បាត់បង់ជីវិត និង ៣នាក់ទៀតរងរបួស។
**ថ្ងៃទី៩ ខែសីហា** កងទ័ពអ៊ុយក្រែនបានបើកការបាញ់សន្ធប់មកលើភូមិភាគឡូហានស្គ៍ ដែលបានបណ្តាលអោយកុមារអាយុ ៦ឆ្នាំម្នាក់ស្លាប់បាត់បង់ជីវិតដោយសាររងរបួសក្បាលធ្ងន់ធ្ងរ ហើយ ជនស៊ីវិល ៥នាក់ទៀតរួមបញ្ចូលស្ត្រីមានផ្ទៃពោះម្នាក់រងរបួសនិងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ។
**ថ្ងៃទី ១១ ខែ សីហា** កងទ័ពអ៊ុយក្រែនបានបន្តការបាញ់ផ្គត់មកលើភូមីភាគដូញៀតស្គ៍ និង តំបន់ជាយក្រុង។ គ្រាប់កាំភ្លើងធំបានធ្លាក់ចំ បរិវេណគុក។ អ្នកទោសមួយចំនួនរងរបួសដោយសារកំទេចគ្រាប់ និង ជាច្រើនរយនាក់ទៀតបានរត់គេចខ្លួន។
**ថ្ងៃទី ១២ ខែសីហា** គ្រាប់កាំភ្លើងធំពីរគ្រាប់របស់កងទ័ពអ៊ុយក្រែនបានធ្លាក់មកលើដែនដីរុស្ស៊ី។ ផ្ទះសម្បែងមួយខ្នងត្រូវបំផ្លាញនៅ Rostov ។ ចំណែកគ្រាប់មួយផ្សេងទៀតបានកំទេចយ៉ាងធ្ងន់ធ្ងរផ្ទះមួយខ្នង និង អគារមួយនៅភូមិ Kuybishevo ក្នុងសង្កាត់ Kuybishevsky នៃភូមិភាគ Rostov ។
**ថ្ងៃទី ១៣ ខែសីហា** ជនស៊ីវិល ៥នាក់នៅសង្កាត់ Petrovsky  បានរងរបួសពីការប្រយុទ្ធគ្នានៅពេលយប់ក្នុងភូមិភាគ ដូញៀតស្គ៍។
**ថ្ងៃទី ១៣ ខែសីហា** អង្គការសហប្រជាជាតិបានបោះពុម្ពផ្សាយព័ត៌មានតាំងពីថ្ងៃដំបូងនៃជម្លោះក្នុងប្រទេសអ៊ុយក្រែនមានអ្នកស្លាប់រហូតដល់ ២០៨៦ នាក់។
**ថ្ងៃទី ១៣ ខែសីហា** ជនស៊ីវិលជាង ២០នាក់បានស្លាប់បាត់បង់ជីវិតដោយសារការបាញ់កាំភ្លើងធំមកលើភូមិភាគឡូហានស្គ៍។
**ថ្ងៃទី ១៤ ខែសីហា** គ្រាប់កាំភ្លើងធំដែលបានបាញ់ដោយកងទ័ពអ៊ុយក្រែនបានធ្លាក់ចំផ្សារទំនើប « មូស្គូ»ដោយបានបណ្តាលអោយជនស៊ីវិល ៤នាក់ស្លាប់បាត់បង់ជីវិតក្នុងឧបទ្ទវហេតុនេះ។
ថ្ងៃទី ១៤ ខែសីហា នៅ Zugres  (ភូមិភាគ ដូញៀតស្គ៍) មនុស្សចំនួន ១៥នាក់បានស្លាប់បាត់បង់ជីវិតដោយសារគ្រាប់កាំភ្លើងធំរបស់កងទ័ពអ៊ុយក្រែន។
**ថ្ងៃទី ១៦ ខែសីហា** កងទ័ពអ៊ុយក្រែនបានប្រើប្រាស់គ្រាប់មីស៊ីលបាលីស្ទីក « Tochka-U »  ដែលជាអាវុធមានសមត្ថភាពអាចបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ប្រឆាំងនឹងជនស៊ីវិលស្លូតត្រង់ និង រចនាសម្ព័ន្ធសង្គមនៃឡូហានស្គ៍។

**ថ្ងៃទី ១៨ ខែសីហា** កងទ័ពអ៊ុយក្រែនបានបាញ់ផ្លោងកាំភ្លើងត្បាល់នៅក្រៅ Gorlovka ដោយបានសម្លាប់ជនស៊ីវិលម្នាក់។
**ថ្ងៃទី ១៨ ខែសីហា** រថយន្តក្រុងដឹកអ្នកដំណើរមួយបានទទួលការបាញ់ប្រហារនៅភូមិភាគដូញៀតស្គ៍ ហើយជាផលបានបណ្តាលអោយមនុស្សម្នាក់ស្លាប់បាត់បង់ជីវិត ហើយ ៩នាក់រងរបួសបញ្ជូនទៅមន្ទីរពេទ្យ។
**ថ្ងៃទី ១៨ ខែ សីហា** ដោយសារការទម្លាក់គ្រាប់បែកនៅ Starobeshevo ក្នុងភូមិភាគ ដូញៀតស្គ៍ បានបណ្តាលអោយជនស៊ីវិលចំនួន ៧នាក់រងរបួស និង បញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ។
**ថ្ងៃទី ១៩ ខែសីហា** ភាគកណ្តាលនៃសង្កាត់មួយចំនួន នៃភូមិភាគដូញៀតស្គ៍ បានទទួលការបាញ់ផ្តក់យ៉ាងខ្លាំងពីសំណាក់កងទ័ពអ៊ុយក្រែន ដែលជាលទ្ធផលបានសម្លាប់ជនស៊ីវិលជាច្រើននាក់។
**ថ្ងៃទី ២០ ខែសីហា** ការប្រយុទ្ធគ្នានៅភូមិភាគ ដូញៀតស្គ៍ បានបណ្តាលអោយជនស៊ីវិល ៣៤ នាក់បានបាត់បង់ជីវិត និង ២៩នាក់រងរបួស។
**ថ្ងៃទី ២០ ខែ សីហា** តំបន់កណ្តាលនៃភូមិភាគ ដូញៀតស្គ៍ បានទទួលរងនៅការបាញ់ផ្តក់យ៉ាងខ្លាំងពីកាំភ្លើងត្បាល់កងទ័ពអ៊ុយក្រែនដែលបណ្តាលអោយស្លាប់ជនស៊ីវិល ៩នាក់ និង ១៣នាក់ផ្សេងទៀតរងរបួស។ លើសនេះទៀត ការទម្លាក់គ្រាប់បែកលើភូមិ Olenovka បានសម្លាប់ជនស៊ីវិលម្នាក់ និង ៥ នាក់ទៀតរងរបួស។
**ថ្ងៃទី ២១ ខែ សីហា** ជនស៊ីវិល២នាក់បានស្លាប់បាត់បង់ជីវិតដោយសារការទម្លាក់គ្រាប់បែកមកលើ Mospino (ភូមិភាគដូញៀតស្គ៍)។
**ថ្ងៃទី ២១ ខែសីហា** ភូមិភាគដូញៀតស្គ៍ទទួលរងនូវការបាញ់ផ្តក់ដែលបានបំផ្លិចបំផ្លាញ សង្កាត់ Mospino និង Goluboy ។ មានជនស៊ីវិល ៣នាក់បានរងរបួសដោយសារការបាញ់ផ្តក់នេះ។
**នៅថ្ងៃទី ២២ ខែសីហា** រថយន្ត EMERCOM មួយគ្រឿងបានទទួលការបាញ់ប្រហារនៅភូមិភាគដូញៀតស្គ៍ដោយបានបណ្តាលអោយក្រុមអ្នកជួយសង្គ្រោះទទួលរងរបួស។
**ថ្ងៃទៅ ២៣ ខែ សីហា** រដ្ឋមន្ត្រីការបរទេស លីទុយអានី លោក Linkevicius បានអោយដឹងថា កុងស៊ុលកិត្តិយសប្រទេសលីទុយអានី M. Zelenets ត្រូវបានគេចាប់ពង្រត់ និង ធ្វើឃាតនៅភូមិភាគឡូហានស្គ៍។
**ថ្ងៃទី ២៣ ខែ សីហា** កងទ័ពអ៊ុយក្រែនបានទម្លាក់គ្រាប់បែកមកលើភូមិភាគដូញៀតស្គ៍ដោយបណ្តាលអោយជនស៊ីវិល ៣នាក់បានស្លាប់បាត់បង់ជីវិត។
**ថ្ងៃទី ២៣ ខែ សីហា** សង្កាត់ Petrovsky នៃភូមិភាគដូញៀតស្គ៍បានទទួលការបាញ់ផ្តក់ពីសំណាក់កងទាហានអ៊ុយក្រែនដែលបានបណ្តាលអោយអគារផ្ទះសម្បែងមួយចំនួនត្រូវខូចខាត ហើយជនស៊ីវិលម្នាក់បានស្លាប់បាត់បង់ជីវិត។ ភូមិ Zolotarevka នៃសង្កាត់ Shahtersky ក៏ទទួលរងនូវការបាញ់ប្រហារផងដែរ។

**ថ្ងៃទី ២៣ ខែសីហា** តាមរបាយការរបស់ក្រុមបេសកកម្មអង្កេត OSCE ក្នុងប្រទេសអ៊ុយក្រែនបានបោះពុម្ពផ្សាយនូវរបាយការណ៍មួយដែលបានលើកឡើងថា ប្រតិបត្តិការកងអាសាស្ម័គ្រ «Aidar» បានរំលោភបំពានច្បាប់ស្តីអំពីមូលដ្ឋានជាទៀងទាត់ Aidar។

ជាក់ស្តែង ក្រុមអាសាស្ម័គ្រនេះបានចាប់អ្នកស្រុកម្នាក់នៅភូមិ Polovinkino ។ អ្នកភូមិរូបនោះត្រូវបានគេចោទប្រកាន់ថាជាក្រុមបំបែកទឹកដី ហើយត្រូវបានគេវាយតប់ និង គំរាមសម្លាប់ ជាថ្នូរនឹងប្រាក់រំលោះ ១០០០០ដុល្លារ។ នៅពេលប្រាក់លោះត្រូវបានគេប្រគល់អោយ ចំនាប់ខ្មាំងត្រូវបានគេដោះលែងអោយមានសេរីភាព។

**ថ្ងៃទី ២៦ ខែ សីហា** កងទ័ពអ៊ុយក្រែនបានបើកការបាញ់ផ្គត់នៅពេលយប់មកលើភូមិភាគដូញៀតស្គ័ដោយបានសម្លាប់ជនស៊ីវិល ចំនួន ៣នាក់។

**ថ្ងៃទី ២៦ ខែ សីហា** ការិយាល័យអង្គការសហប្រជាជាតិដើម្បីការសម្របសម្រួលផ្នែកកិច្ចការមនុស្សធម៌បានចេញផ្សាយនូវចំនួនជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធនៅភាគខាងត្បូង-កើតអ៊ុយក្រែន។ ជាក់ស្តែងមនុស្សចំនួន ២២៤៩នាក់ស្លាប់បាត់បង់ជីវិត និង ៦០៣៣ បានរងរបួស។

**ថ្ងៃទី ២៨ ខែសីហា** នៅភូមិភាគដូញៀតស្គ័ កងទ័ពអ៊ុយក្រែនបានបើកការបាញ់ផ្គត់ដោយបានសម្លាប់ជីវិតមនុស្សចំនួន ១១នាក់ និង ២២នាក់ទៀតរងរបួស។

**ថ្ងៃទី ២៩ ខែសីហា** កងទ័ពអ៊ុយក្រែនបានបើកការវាយប្រហារទៅលើទីលាន Privokzalnaya នៃតំបន់ ដូញៀតស្គ័។ គ្រាប់កាំភ្លើងធំមួយបានធ្លាក់ចំរថយន្តក្រុង។ ជាសំណាងល្អ ពុំមានអ្នករងរបួសឡើយ។

**ថ្ងៃទី ២៩ ខែសីហា** យោងតាមរបាយការណ៍អង្គការ OUNHCHR បានរាយការណ៍អោយដឹងថា មានករណីនៃការចាប់ឃុំឃាំង ការចាប់ពង្រត់ និង ការធ្វើទារុណកម្មដែលប្រព្រឹត្តដោយកងកម្លាំងយោធា និង កងទ័ពពិសេសអ៊ុយក្រែន។ ចំនួននៃជនរងគ្រោះមានសរុបយ៉ាងហោចណាស់ ១០០០នាក់ យោងតាមលោក I. Šimonović ជំនួយការអគ្គលេខានៃអង្គការសិទ្ធិមនុស្ស។

**ថ្ងៃទី ៣០ ខែ សីហា** នាយករងនៃ division អាស៊ីកណ្តាលនិងអឺរ៉ុបនៃអង្គការសិទ្ធិមនុស្សអន្តរជាតិក្រុមឃ្លាំមើលសិទ្ធិមនុស្ស លោកស្រី R. Denber បានលើកឡើងអំពីការពិតនៃការរំលោភបំពានច្បាប់អន្តរជាតិដោយកងទ័ពអ៊ុយក្រែន។ យោងតាមលោកស្រី កងទ័ពអ៊ុយក្រែនបានបើកការវាយប្រហារដោយអាវុធធុនធ្ងន់ទៅលើសង្កាត់ដែលមានប្រជាជនស៊ីវិលរស់នៅក្នុងភាគខាងកើតនៃប្រទេសដោយប្រើប្រព័ន្ធបាញ់រ៉ុក្កែត «Grad» ដែលផ្ទុយអំពីច្បាប់អន្តរជាតិ។ លោកស្រីមានប្រសាសន៍នៅក្នុងបទសម្ភាសន៍ជាមួយប៉ុស្តិ៍វិទ្យុ ប្រទេសឡាទ្វា« Baltkom» ថា«យើងបានរកឃើញការពិតនៃការប្រើប្រាស់កាំភ្លើងធំបាញ់ផ្គត់ទៅលើសង្កាត់អ្នកស្រុកដោយកងទ័ពអ៊ុយក្រែន។ ពួកគេក៏បានប្រើប្រាស់ប្រព័ន្ធបាញ់រ៉ុក្កែត «Grad»ដែលត្រូវបានហាមឃាត់ប្រើប្រាស់ ត្បិតទីនោះជាកន្លែងដែលមានប្រជាជនស៊ីវិលរស់នៅ។»

**ថ្ងៃទី ៣០ ខែ សីហា** កងទ័ពអ៊ុយក្រែនបន្តការវាយប្រហារទៅលើ ភូមិភាគ ឡូហានស្គ័ និង ដូញៀតស្គ័។ អគារស្ថានីយ៍រថភ្លើងចាស់និងបរិវេណស្ថានីយ៍ត្រូវបានខូចខាតយ៉ាងដំណំ។ ផ្នែកខាងមុខនៃសណ្ឋាគារ

ដែលនៅជិតនោះក៏ត្រូវបានបំផ្លាញ។ មនុស្សពីរនាក់បានទទួលរងរបួស ដែលជនរងគ្រោះម្នាក់ដោយសារការភ័យតក់ស្លុត។

**ថ្ងៃ ២ ខែកញ្ញា** Enakievo (ភូមិភាគដូញៀតស្គ៍) ទទួលរងការបាញ់ប្រហារយ៉ាងខ្លាំងពីកងទ័ពអ៊ុយក្រែន។ គ្រាប់កាំភ្លើងធំបានធ្លាក់នៅកណ្តាលទីក្រុង និង ភូមិ Razdolovka ។យ៉ាងហោចណាស់មនុស្ស ៤នាក់បានស្លាប់បាត់បង់ជីវិត។

**ថ្ងៃទី ២ ខែកញ្ញា** អង្គការសិទ្ធិមនុស្សអន្តរជាតិ ក្រុមឃ្លាំមើលសិទ្ធិមនុស្សបានបោះពុម្ពផ្សាយរបាយការណ៍អំពីស្ថានភាពនៅភូមិភាគឡូហានស្គ៍នៃប្រទេសអ៊ុយក្រែនដែលបានលើកឡើងអំពីការកើនឡើងនៃ «អ្នកស្លាប់បាត់បង់ជីវិតក្នុងចំណោមជនស៊ីវិល»។ ក្រុមសកម្មជនសិទ្ធិមនុស្សបានផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការប្រើប្រាស់គ្រាប់បែកចង្កោមដោយទាហានអ៊ុយក្រែនក្នុងពេលធ្វើប្រតិបត្តិការបាញ់ផ្តក់នៅភូមិភាគឡូហានស្គ៍។អ្នកជំនាញនៃអង្គការក្រៅរដ្ឋាភិបាលបានគូសបញ្ជាក់ថា គេបានរកឃើញមិនត្រឹមតែបំណែកនៃគ្រាប់នោះទេ ប៉ុន្តែថែមទាំងភស្តុតាងដែលរកឃើញនៅក្នុងបរិវេញមន្ទីរសុខភាពនូវការប្រើប្រាស់គ្រាប់បែកចង្កោមទៀតផង។

**ថ្ងៃទី ៤ ខែកញ្ញា** ជាលទ្ធផលនៃការបាញ់ផ្តក់ពីសំនាក់កងទ័ពអ៊ុយក្រែនមកលើសង្កាត់នានាក្នុងភូមិភាគដូញៀតស្គ៍បានបណ្តាលអោយជនស៊ីវិលស្លាប់បាត់បង់ជីវិត ៥នាក់ និង ៩នាក់រងរបួស។

**ថ្ងៃទី ៥ ខែ កញ្ញា** តាមទិន្នន័យដែលបោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិ យ៉ាងហោចណាស់មានមនុស្សចំនួន ២៩០៥ នាក់ (ក្នុងនោះយ៉ាងតិចបំផុត មានកុមារ ២៨នាក់) បានស្លាប់បាត់បង់ជីវិត និង ៧៦៤០នាក់(ក្នុងនោះយ៉ាងតិចបំផុត មានកុមារ ៥៨) បានរងរបួស។

**ថ្ងៃទី ៥ ខែកញ្ញា** កងទ័ពអ៊ុយក្រែនបានបន្តបើកការវាយប្រហារមកលើតំបន់នានាក្នុងភូមិភាគដូញៀតស្គ៍ បើទោះបីជាកិច្ចព្រមព្រៀងឈប់បាញ់គ្នាត្រូវបានប្រកាសដោយប្រធានាធិបតី P. Poroshenko ក៏ដោយ។ ជាលទ្ធផលនៃការវាយប្រហារមកលើភូមិ Elenovka ក្នុងសង្កាត់ Volnovakhovsky ធ្វើឡើងដោយកងទ័ពអ៊ុយក្រែន បានបណ្តាលអោយជនស៊ីវិល៤នាក់ស្លាប់បាត់បង់ជិវិត។

**ថ្ងៃទី ៦ ខែកញ្ញា** កងទ័ពអ៊ុយក្រែនបានបន្តបើកការវាយប្រហារមកលើភូមិភាគដូញៀតស្គ៍ និង តំបន់ជាយក្រុង រួមទាំង Mariupol ។

**ថ្ងៃទី ៨ ខែកញ្ញា** យោងតាមអ្នកស្រុកបានអោយដឹងថា សម្លេងនៃការបាញ់ផ្លោងត្រូវបានគេលឺយ៉ាងច្បាស់ចេញពីតំបន់ Marynka (ភូមិភាគដូញៀតស្គ៍) ដែលគ្រប់គ្រងដោយកងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ៩ ខែកញ្ញា** ក្នុងកំឡុងពេលនៃការប្រយុទ្ធគ្នានៅ Makeevka ភូមិភាគដូញៀតស្គ៍ បានបណ្តាលអោយជនស៊ីវិល ៣៥នាក់ស្លាប់បាត់បង់ជីវិត និង ជាង ៣៥០នាក់រងរបួស ហើយ ៧០ប្លុកនៃផ្ទះល្វែង និង ផ្ទះជាង ១០០ ត្រូវបានខូចខាតស្ទើរតែទាំងស្រុង។

**ថ្ងៃទី ៨ ខែកញ្ញា** អង្គការសិទ្ធិមនុស្ស «លើកលែងទោសអន្តរជាតិ» បានបញ្ជាក់នៅក្នុងរបាយការណ៍របស់ខ្លួនបទឧក្រិដ្ឋដ៏ឃោរឃៅប្រព្រឹត្តឡើងដោយកងពិសេស « Aidar » (រួមទាំងក្នុងជួរកងទ័ពផងដែរ) នៅក្នុងតំបន់ឡូហានស្គ៍។ របាយការណ៍បានផ្តល់នូវភស្តុតាងនៃការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបង្កឡើងដោយសកម្មជននៃអង្គភាពនេះ រួមមានការចាប់ពង្រត់ ការឃុំឃាំងខុសច្បាប់ ការធ្វើ

ទារុណកម្មដ៏ឃោរឃៅ អំពើលួចប្លន់ ការបំភិតបំភ័យ ហើយអាចថែមទាំងការសម្លាប់ប្រហារជីវិតទៀតផង។ យោងតាមរបាយការណ៍អ្នកជំនាញការនៃ អង្គការលើកលែងទោសអន្តរជាតិបានអោយដឹងថា មាន«១០ករណី»នៃអំពើឧក្រិដ្ឋដែលប្រព្រឹត្តដោយកងអាសាស្មគ្រ « Aidar »នៅក្នុងសង្កាត់ Novoaidarsky Starobelsk, Severodonetsk, Lisichansk និង Schastye ចាប់ពីដើមខែ មិថុនា រហូតដល់ចុងខែសីហា ២០១៤។

**ថ្ងៃទី ១២ ខែ កញ្ញា** ជាលទ្ធផលនៃការបាញ់ប្រហារពីសំណាក់កងទ័ពអ៊ុយក្រែនមកលើ តំបន់ Makeevka (ភូមិភាគដូញៀតស្គ៍) មានជនស៊ីវិល ៦នាក់បានរងរបួស។

**ថ្ងៃទី ១៤ ខែកញ្ញា** សកម្មជនសិទ្ធិមនុស្សបានអោយដឹងថា មានការបាញ់ផ្គក់ដោយប្រើកាំភ្លើងត្បាល់ជាច្រើនគ្រាប់មកលើសង្កាត់មួយចំនួនក្នុង Kievsky នៃភូមិភាគ ដូញៀតស្គ៍ដែលបង្កឡើងដោយកងទ័ពអ៊ុយក្រែន។មន្ត្រីប៉ូលីសដែលអមសកម្មជនសិទ្ធិមនុស្សបានស្លាប់បាត់បង់ជីវិតជាមួយនឹងជនស៊ីវិល ៤ ឬ ៥នាក់នោះដែរ។

**ថ្ងៃទី ១៤ ខែកញ្ញា** ជាលទ្ធផលនៃការប្រយុទ្ធគ្នា នៅ Panteleymonovka (ក្នុងភូមិភាគដូញៀតស្គ៍) មានជនស៊ីវិល៣នាក់ត្រូវបានសម្លាប់ និង ៨នាក់ទៀតរងរបួស។

**ថ្ងៃទី ១៤ ខែកញ្ញា** យោងតាមប្រធាននៃបេសកកម្មអង្កេតពិសេស OSCE នៅក្នុងប្រទេសអ៊ុយក្រែន លោក Apakan បានអោយដឹងថា បំណែកគ្រាប់បានធ្លាក់មកលើអ្នកអង្កេតដែលកំពុងដើរល្បាតនៅក្នុងតំបន់ភាគខាងកើតដូញៀតស្គ៍។

**ថ្ងៃទី ១៥ ខែ កញ្ញា** នៅដូញៀតស្គ៍ ក្រុមអ្នកអង្កេតការស្ទើរស្លាប់បាត់បង់ជីវិតដោយសារការបាញ់ផ្គក់នៃកាំភ្លើងត្បាល់ពីកងទាហានអ៊ុយក្រែន។ គ្រាប់បានធ្លាក់ទៅលើផ្សារមួយនៅក្នុងក្រុងដែលមានចំងាយប៉ុន្មានរយម៉ែត្រពីកន្លែងអ្នកតំណាងអង្គការប្រចាំនៅតំបន់ Kirovskoe ដែលមានភារកិច្ចតាមដានការអនុវត្តកិច្ចព្រមព្រៀងឈប់បាញ់។

**ថ្ងៃទី ១៥ ខែកញ្ញា** កងទ័ពអ៊ុយក្រែនបានរំលោភលើកិច្ចព្រមព្រៀងឈប់បាញ់សរុបចំនួន ៧ដង តាំងពីការចុះកិច្ចព្រមព្រៀងលើបទឈប់បាញ់។ ក្នុងនោះមានជនស៊ីវិល ២០នាក់បានស្លាប់បាត់បង់ជីវិត និង ២៤នាក់រងរបួស។

**ថ្ងៃទី ១៦ ខែកញ្ញា** នៅដូញៀតស្គ៍ គ្រាប់កាំភ្លើងធំអ៊ុយក្រែនបានធ្លាក់លើរថយន្តក្រុងកំពុងបើកបរលើផ្លូវលេខ ៤២ ដែលមានអ្នកដំណើរប្រហែល ១០នាក់។ ស្ត្រីម្នាក់បានស្លាប់ និង មនុស្សម្នាក់ទៀតរងរបួស។

**ថ្ងៃទី ១៦ ខែកញ្ញា** នៅឡូហានស្គ៍ និវត្តន៍ជនអាយុ ៧៥ឆ្នាំម្នាក់ត្រូវបានកងទ័ពអ៊ុយក្រែនវាយធ្វើបាប។ សាក្សីដែលឃើញហេតុការណ៍បាននិយាយថា ពួកគេបានគំរាមដុតផ្ទះនិងវាយតប់លើរាងកាយយ៉ាងព្រៃផ្សៃ។

**ថ្ងៃទី ១៦ ខែកញ្ញា** ជាលទ្ធផលនៃការទម្លាក់គ្រាប់បែក នៅដូញៀតស្គ៍ ជនស៊ីវិល ៣នាក់បានស្លាប់ និង ៥នាក់បានរងរបួស។

**ថ្ងៃទី ១៧ ខែ កញ្ញា** កងទ័ពអ៊ុយក្រែនបានបើកការវាយប្រហារមកលើភូមិភាគដូញៀតស្គ៏ដោយបានសំលាប់ជនស៊ីវិលចំនួនពីរនាក់។
**ថ្ងៃទី ១៨ ខែ កញ្ញា** អ្នករស់នៅ Selidovo ក្រុងស្ថិតនៅភូមិភាគដូញៀតស្គ៏ ដែលបានរួចខ្លួនពីក្រុមកងពិសេសអ៊ុយក្រែន« Aidar» បាននិយាយថា ចំណាប់ខ្មាំងត្រូវបានគេវាយដំយ៉ាងខ្លាំង វាយបំបាក់ឆ្អឹងពួកគេ ជនរងគ្រោះត្រូវបានគេដាក់ក្នុងស្ថានភាពអាក្រក់បំផុត។ ក្នុងមួយថ្ងៃពួកគេទទួលបានទឹកតែម្តងប៉ុននោះដាក់ស្តែង ពួកគេមិនត្រូវបានផ្តល់ចំណីអាហារឡើយ។ នៅពេលយប់ជនរងគ្រោះត្រូវបានគេសួរចម្លើយដោយនៅលើក្បាលមានបង្វិចដ៏ធ្ងន់ថែមទៀត។ បន្ទាប់ពី ក្រុម « Aidar» ប្រគល់ចំណាប់ខ្មាំងទៅការិយាល័យភ្នាក់ងារសន្តិសុខអ៊ុយក្រែន នៅ Kharkov ស្ថានភាពអាក្រក់មិនមានការផ្លាស់ប្តូរច្រើននោះទេ។ ចំណាប់ខ្មាំងត្រូវបានគេទុកនៅក្នុងបន្ទាយ ។ ជនរងគ្រោះ ១៧នាក់ បានទទួលនំប៉័ងត្រឹមតែ ១២ ចំនិតកប៉ុននោះក្នុងពេលមួយថ្ងៃ ហើយក្នុងមួយថ្ងៃម្តង ចំណាប់ខ្មាំងបានទទួលទឹកតិចតួចបំផុត។ រំពាត់ និង ឧបករណ៏ឆក់ត្រូវបានគេប្រើប្រាស់ក្នុងពេលសួរចម្លើយ។
**ថ្ងៃទី ២២ ខែ កញ្ញា** កងកម្លាំង« Aidar» បានបាញ់សម្លាប់ទាហានជើងទឹកពីរនាក់នៃកងប្រតិបត្តិការពិសេសនៃកងទ័ពជើងទឹកអ៊ុយក្រែនក្នុងគោលបំណងបំភិតបំភ័យដែលនេះធ្វើអោយអង្គភាពនេះមិនអាចដកពីទីតាំងប្រចាំការរបស់ខ្លួន បន្ទាប់ពីការប្រកាសបទឈប់បាញ់។
**ថ្ងៃទី ២៤ ខែ កញ្ញា** នៅក្នុងភូមិ Zhdanovka, Communar,Khartsizk និង Nizhnyaya Krynka ដែលស្ថិតនៅក្នុងភូមិភាគដូញៀតស្គ៏ ទីតាំងដែលកងទ័ពអ៊ុយក្រែនបានដកចេញ មានការរកឃើញកន្លែងកប់សាកសពរួមជាច្រើនកន្លែងដែលត្រូវសាកសពទាំងនោះត្រូវបានគេធ្វើទារុណកម្ម រំលោភបំពាន និង សម្លាប់យ៉ាងព្រៃផ្សៃបំផុត។
**ថ្ងៃទី ២៦ ខែ កញ្ញា** ប្រតិភូនៃអង្គការ«លើកលែងទោសអន្តរជាតិ» បានចុះពិនិត្យមើលកន្លែងកប់សាកសពរួមនៅក្បែរ ភូមិ Nizhnyaya Krynka និង Communar ក្នុងភូមិភាគដូញៀតស្គ៏។ ក្រុមសកម្មជនសិទ្ធិមនុស្សបានរកឃើញភស្តុតាងជាច្រើនដែលបញ្ជាក់ថា កងទ័ពអ៊ុយក្រែនបានសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ នៅក្នុងភូមិ Communar ។
**ថ្ងៃទី ២៩ ខែ កញ្ញា** យោងតាមព័ត៌មានដែលបានផ្សព្វផ្សាយដោយគេហទំព័រផ្លូវការនៃគណៈកម្មាធិការស៊ើបអង្កេតសហព័ន្ធរុស្ស៊ីបានអោយដឹងថា «នាយកដ្ឋានស៊ើបអង្កេតនៃគណៈកម្មាធិការអង្កេតនៃប្រទេសរុស្ស៊ីបានចាប់ផ្តើមពិនិត្យករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៏នៅតំបន់ដែលមានប្រជាជននិយាយភាសារុស្ស៊ីក្នុងភូមិភាគឡូហានស្គ៏ និង ដូញៀតស្គ៏ (មាត្រាទី ៣៥៧ នៃក្រមព្រហ្មទណ្ឌរុស្ស៊ី) ។ ការស៊ើបអង្កេតបានបង្ហាញថា ក្នុងកំឡុងពេលពីថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៤ រហូតមកដល់ពេលបច្ចុប្បន្ន ក្រុមមនុស្សអនាមិកចេញពីថ្នាក់ដឹកនាំខ្ពស់បំផុតយោធា និង នយោបាយរបស់ប្រទេសអ៊ុយក្រែន កងប្រដាប់អាវុធជាតិអ៊ុយក្រែន កងសន្តិសុខជាតិអ៊ុយក្រែន និង ក្រុម « Right Sector » បានចេញបញ្ជាអោយសម្លាប់ផុតពូជបណ្តាជនដែលនិយាយភាសារុស្ស៊ីនៅលើទឹកដីនៃសាធារណរដ្ឋដូញៀតស្គ៏ និង ឡូហានស្គ៏ ដែលទង្វើនេះរំលោភទៅលើកតិកាសញ្ញាស្តីអំពីការការពារ និង ការធ្វើ

ទារុណកម្មនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ ព្រមទាំងបទដ្ឋានគតិយុត្តិអន្តរជាតិដទៃទៀតនៃអំពើប្រល័យពូជសាសន៍។»

**ថ្ងៃទី ១ ខែតុលា** ជនស៊ីវិលចំនួន ៩នាក់បានស្លាប់បាត់បង់ជីវិតដោយសារការប្រយុទ្ធគ្នានៅដូញៀតស្គ៍ ហើយ៣០នាក់ផ្សេងទៀតបានរងរបួស។ មនុស្ស ៦នាក់បានស្លាប់នៅពេលដែលគ្រាប់កាំភ្លើងត្បាល់ធ្លាក់ចំរថយន្តដឹកអ្នកដំណើរដែលកំពុងបើកលើផ្លូវលេខ ១៧ នៃវិថី គៀវ ជិតចំណតរថយន្ត Ulitsa Poligraficheskaya ។ អ្នកដំណើរជិះលើរថយន្ត ៧នាក់រងរបួស។ អនុវិទ្យាល័យលេខ ៥៧ ដែលស្ថិតនៅវិថី Novoyasinovatskaya ត្រូវបានបំផ្លិចបំផ្លាញដោយគ្រាប់កាំភ្លើងធំ។ លោកគ្រូជីវវិទ្យាម្នាក់បានស្លាប់ និង មនុស្ស ៥នាក់ផ្សេងទៀតរងរបួស។

**ថ្ងៃទី ២ ខែតុលា** លោក killed Laurent Etienne du Pasquier អ្នកតំណាងនៃគណៈកម្មាធិការកាកបាទក្រហមបានស្លាប់បាត់បង់ជិវិតដោយសារការបាញ់ផ្គក់មលើភូមិភាគដូញៀតស្គ៍ដោយកងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ៤ ខែតុលា** ស្ត្រីចំណាស់អាយុ ៥៤ម្នាក់ បានស្លាប់បាត់បង់ជីវិត និង ស្ត្រីម្នាក់បានរងរបួសដោយការបាញ់ផ្គក់មកលើភូមិភាគដូញៀតស្គ៍។

**ថ្ងៃទី ៧-៨ ខែតុលា (ពេលយប់)** មានមនុស្សយ៉ាងហោចណាស់៨នាក់បានរងរបួសដោយសារគ្រាប់ប្លោងរបស់កងទ័ពអ៊ុយក្រែននៅដូញៀតស្គ៍។ តំបន់រោងចក្រ « The Tochmash plant» បានទទួលរងការខូចខាតជាដំណំដោយគ្រាប់។ ក្នុងនោះដែរ ក៏មានព័ត៌មានផងដែរ អំពីការបាញ់ផ្គក់ទៅលើ Makeyevka និង Yasinovataya ។

**ថ្ងៃទី ៨ ខែតុលា** អ្នកតំណាងឧត្តមប្រឹក្សាជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សលោក Zeid Raad al-Hussein បាននិយាយថា យ៉ាងហោចណាស់មានមនុស្ស ៣៣១នាក់ត្រូវបានសម្លាប់បន្ទាប់ពីការចុះកិច្ចព្រមព្រៀងលើបទឈប់បាញ់ នៅភាគខាងកើតអ៊ុយក្រែនកាលពីថ្ងៃទី ៥ កញ្ញា។

**ថ្ងៃទី ៩ តុលា** តាមរបាយការនៃបេសកកម្មអង្កេតពិសេស OSCE បានអោយដឹងថា តាំងពីខែ មីនា ឆ្នាំ ២០១៤ មានមនុស្សចំនួន ១៥០០នាក់ រួមមានកុមារ ២១នាក់ត្រូវបានសម្លាប់នៅ Donbass ។

ថ្ងៃទៅ ១១ ខែ តុលា កងទ័ពអ៊ុយក្រែនបានបន្តការបាញ់ប្រហារមកលើទីក្រុងនៃភូមិភាគដូញៀតស្គ៍។ មនុស្ស៤នាក់ត្រូវបានសម្លាប់ និង ១១នាក់ផ្សេងទៀតបានរងរបួស។

ថ្ងៃទី ១២ ខែតុលា ជនស៊ីវិល ១២នាក់បានរងរបួស ដោយក្នុងនោះមានស្ត្រី ៦នាក់ និង កុមារតូចម្នាក់ក្រោមការបាញ់ផ្គក់កាំភ្លើងធំមកលើភូមិភាគដូញៀតស្គ៍ពីសំណាក់កងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ១៧ ខែតុលា** ការិល័យអង្គការសហប្រជាជាតិទទួលបន្ទុកសម្របសម្រួលកិច្ចការមនុស្សធម៌ (OCHA)បានផ្តល់របាយការណ៏ថា ពេញមួយសប្តាហ៏មុន ចំនួននៃអ្នកស្លាប់បាត់បង់ជីវិតនៅភាគខាងត្បូង-កើតអ៊ុយក្រែនបានកើនឡើងរហូតដល់ ៣៧០៧នាក់ និង រងរបួសមានចំនួន ៩០៧៥នាក់។ OCHA បានគូសបញ្ជាក់ថា របាយការណ៏ដែលចេញផ្សាយដោយបេសកកម្មអង្កេតសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅអ៊ុយក្រែន និង អង្គការសុខភាពពិភពលោក គឺនៅ «មិនទាន់ពេញលេញ» នៅឡើយ។ ចំនួនអ្នកស្លាប់អាចមានចំនួនច្រើនជាងនេះ។

ថ្ងៃទី ១៨ខែ តុលា ការបាញ់ផ្តក់ពីសំណាក់កងទ័ពអ៊ុយក្រែនមកលើដូញៀតស្គ័បានបណ្តាលអោយជនស៊ីវិលស្លាប់ចំនួន ៤នាក់ និង ៩នាក់ទៀតរងរបួស។
ថ្ងៃទី ២១ ខែតុលា អង្គការសិទ្ធមនុស្សអន្តរជាតិ ក្រុមឃ្លាំមើលសិទ្ធិមនុស្សបានចេញរបាយការណ៏អោយដឹងថាក្នុងដើមខែតុលា ២០១៤នេះ រដ្ឋាភិបាលអ៊ុយក្រែនបានប្រើប្រាស់គ្រាប់បែកចង្កោមក្នុងកំឡុងនៃការបាញ់ផ្តក់មកលើតំបន់នានានៅដូនញៀតស្គ័។ ក្រុមសកម្មជនសិទ្ធិមនុស្សបាននិយាយថា « សកម្មភាពនេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សង្គ្រាម និង អាចរាប់បញ្ចូលក្នុងបទឧក្រិដ្ឋកម្មសង្គ្រាមដោយហេតុការពិតដែលថាការបាញ់ផ្តក់នេះមិនសំដៅតែគូប្រយុទ្ធប៉ុននោះទេ តែបានសម្លាប់ជនស៊ីវិលថែមទៀត»។ អង្គការនេះបានធ្វើការអង្កេតក្នុងរយៈពេលមួយសប្តាហ៏ហើយបានរកឃើញភស្តុតាងដែលបង្ហាញថាកងទ័ពអ៊ុយក្រែនបានប្រើប្រាស់គ្រាប់បែកចង្កោមនៅក្នុងតំបន់លើសពី ១២។ យោងតាមព័ត៌មានដែលបានអោយដឹងថា កាលពីថ្ងៃទី ២ ខែតុលា ឆ្នាំ ២០១៤ លោក L.E. du Pasquier មន្ត្រីគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិត្រូវបានគេសម្លាប់នៅដូញៀតស្គ័។ ក្នុងរបាយការណ៏នោះភស្តុតាងនៃការជាប់ពាក់ព័ន្ធរបស់កងទ័ពអ៊ុយក្រែន «មានភាពគួរអោយជឿជាក់ជាពិសេស»។ រដ្ឋាភិបាលអ៊ុយក្រែនពុំបានឆ្លើយតបទៅនឹងការស្នើសុំរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សពាក់ព័ន្ធនឹងការប្រើប្រាស់គ្រាប់បែកចង្កោម។
**ថ្ងៃទី ២៥ ខែតុលា** កងទ័ពអ៊ុយក្រែនបានបង្កើនប្រតិបត្តិការវាយលុកនៅតំបន់ខ្សែទាក់ទង។ ក្នុងពេលយប់ថ្ងៃទី ២៤-២៥ ខែតុលា មានការរំលោភលើបទឈប់បាញ់ដោយភាគីអ៊ុយក្រែនចំនួន ២០ដង។ ជាពិសេស មានការបាញ់ផ្លោងដោយកាំភ្លើងធំ ៨ ករណីមកលើសង្កាត់ Yasinovataya ស្ថិតក្នុងភូមិភាគដូញៀតស្គ័ពីសំណាក់កងទ័ពអ៊ុយក្រែន ដែលបានបណ្តាលអោយផ្ទះ២ខ្នងខូចខាតទាំងស្រុង ចំណែកប្រព័ន្ធចែកចាយទឹក ភ្លើងត្រូវបានកាត់ផ្តាច់។ ក្នុងនោះជនស៊ីវិល ៤នាក់បានរងរបួស ។ លើសនេះទៀត ទីក្រុងដទៃទៀតក្នុងភូមិភាគដូញៀតស្គ័បានទទួលការបាញ់ផ្តក់ផងដែរពីសំណាក់កងទ័ពអ៊ុយក្រែន(ជនស៊ីវិលម្នាក់បានស្លាប់ និង ៥នាក់ទៀតរងរបួស)។
**ថ្ងៃទី ២៩ ខែតុលា** រដ្ឋមន្ត្រីសុខាភិបាលសាធារណរដ្ឋ ឡូហានស្គ័ លោក , L. Ayrapetyan បានអោយដឹងថាចាប់តាំងពីខែឧសភា ឆ្នាំ ២០១៤ នៅក្នុងសាធារណរដ្ឋមានជនរងគ្រោះសរុប ២៩៧៣ នាក់ ដែលក្នុងនោះ ២៦១៤នាក់បានរងរបួស។  ការប្រយុទ្ធគ្នាបានសម្លាប់ជីវិតមនុស្សចំនួន ៤៥៦ នាក់។ ថ្ងៃទី២ ខែវិច្ឆិកា យោងតាមការិយាល័យសម្របសម្រួលកិច្ចការមនុស្សធម៌អង្គការសហប្រជាជាតិ ចំនួនអ្នកបាត់បង់ជីវិតនៅក្នុងការប្រយុទ្ធគ្នានៅភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែនបានកើនឡើងរហូតដល់ ៤ ០០០នាក់ ខណៈដែល ១០ ០០០នាក់រងរបួស។ ក្នុងកំឡុងពេលពីចុងខែសីហារហូតដល់ថ្ងៃទី ៤ វិច្ឆិកា អ្នកជំនាញនៃមូលនិធីដើម្បីការសិក្សាលទ្ធិប្រជាធិបតេយ្យ បានធ្វើការសម្ភាសន៏អ្នករស់នៅក្នុងភាគខាងត្បូង-កើតដែលរងគ្រោះពីសកម្មភាពបាញ់ផ្តក់ដោយប្រើកាំភ្លើងធំ ពីសំណាក់កងកម្លាំងសន្តិសុខជាតិអ៊ុយក្រែន និង កម្លាំងអ្នកជាតិនិយមដែលមានបំពាក់ដោយអាវុធ។ ខាងក្រោមនេះគឺជាការដកស្រង់ពីការសម្ភាសជនគ្រោះ លោក ដ. ជាជនរងគ្រោះដែលត្រូវបានឃុំឃាំងដោយសន្តិសុខជាតិអ៊ុយក្រែនកាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ នៅត្រង់តំបន់ត្រួតពិនិត្យហើយត្រូវបានប្រគល់ទៅ

អោយកងកម្លាំងភូមិភាគ« Azov»។ ពួកគេបានយកខ្ញុំទៅកាន់ព្រលានយន្តហោះMariupol និងចាក់សោរឃុំឃាំងខ្ញុំនៅក្នុងទូទឹកកកមិនដំណើរការមួយ។ គ្មានភ្លើងនៅទីនោះទេ មនុស្សគ្រប់គ្នាសំរាកនៅផ្ទាល់នឹងកំរាលឥដ្ឋ។ ទ្វារត្រូវបានគេឃ្លុំបិទជិត មានខ្យល់តែបន្តិចបន្តួចប៉ុននោះ ខ្យល់មានក្លិនមិនល្អស្ទើរតែមិនអាចទ្រាំបាន។ ពួកគេសួរចម្លើយយើងម្តងក្នុងរយៈពេល ២-៣ម៉ោងម្តង។ ពួកគេបានធ្វើអ្វីជាច្រើនមកលើយើង។ ពួកគេបានធ្វើទារុណកម្មខ្ញុំដោយឃ្លុំមុខ និង ចាក់ទឹកពីលើ។ ពួកគេបានចងភ្នែកខ្ញុំនិងដាក់កន្សែងឬបំណែកក្រណាត់នៅលើមុខហើយចាក់ទឹកពីលើវា។ ខ្ញុំមិនច្បាស់ថាពួកគេបានប្រើប្រាស់ជបឬក៏កំសៀវដើម្បីធ្វើវានោះទេ។ ខ្ញុំមិនអាចមើលឃើញអ្វីទាំងអស់។ ខ្ញុំមានអារម្មណ៏ដូចជាលង់ទឹកដូច្នោះដែរ។ បន្ទាប់មកពួកគេបានធ្វើអោយខ្ញុំដឹងខ្លួនសារជាថ្មី ហើយអ្វីៗនៅតែបន្ថែមទៀត។ ខ្ញុំបានបាក់ជង្គង់ ហើយពាក់ប្រដាប់អបជើង។ ពួកគេឃើញ ហើយក៏បំបាក់ជង្គង់ខ្ញុំសារជាថ្មី។ ពួកគេធ្វើទារុណកម្មដាក់ខ្ញុំនៅថ្ងៃទីមួយនៅទីនោះ។ បន្ទាប់មកពួកគេក៏ចាក់ដោតម្ជុលចូលទៅក្នុងក្រចកជើង។ វាមានអារម្មណ៏ហាក់ដូចជាមាននរណាម្នាក់កំពុងហូតសរសៃឈាមចេញពី-ករបស់ខ្ញុំបែបនោះដែរ។ ខ្លួនខ្ញុំទាំងមូលឈឺចាប់យ៉ាងខ្លាំង ខ្ញុំត្រូវបានគេធ្វើអោយឈឺខ្លាំងណាស់។ ពួកគេបានបោះអ្នកចំណាប់ខ្មាំងទៅក្នុងរណ្តៅដែលពោរពេញដោយសាកសព។ ខ្ញុំស្គាល់ក្មេងម្នាក់ដែលត្រូវបានគេដកធ្មេញវាទអស់ ៤ដោយប្រើដណ្កាប់។លោក វ. ជាជនរងគ្រោះម្នាក់ទៀតដែលត្រូវបានគេចាប់ឃុំឃាំងកាលពីថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០១៤ដោយក្រុមមនុស្សឯកសណ្ឋានស៊ីវិល និង ពាក់ម៉ាស់បិទមុខ។ ខ្ញុំត្រូវបានគេនាំទៅព្រលានយន្តហោះ Mariupol ។ នៅពេលយើងត្រូវបានគេនាំទៅដល់ទីនោះ ពួកគេចាប់ផ្តើមធ្វើទារុណកម្មខ្ញុំ ឆក់ខ្ញុំជាមួយឧបករណ៏ឆក់អគ្គិសនីនៅជិតបេះដូង និង នៅលើដើមដៃខ្ញុំ។ ពួកគេព្យាយាមពន្លេខ្ញុំក្នុងទឹក ដើម្បីធ្វើអោយឈ្លក់។ ពួកគេបានដាក់កញ្ចប់មួយនៅលើក្បាលខ្ញុំ និង ផ្កាប់មុខខ្ញុំចូលក្នុងទឹករហូតដល់ខ្ញុំសន្លប់។ ថ្ងៃបន្ទាប់ពួកគេបានប្រាប់ខ្ញុំអោយចុះហត្ថលេខាលើក្រដាស។ ខ្ញុំបានបដិសេធ។ ពួកគេបាននាំខ្ញុំទៅក្នុងបន្ទប់ចម្រឹង ហើយថ្ងៃបន្ទាប់បាននាំខ្ញុំទៅធ្វើទារុណកម្មម្តងទៀត។ ពួកគបានបានយកក្រណាត់ខោអាវកមដាក់នៅលើមុខ និង ចាក់ទឹកលើវា។ នៅពេលខ្ញុំចាប់ផ្តើមឈ្លក់ ពួកគេរឹតតែចាក់បន្ថែមទៀតដើម្បីអោយខ្ញុំឈ្លក់កាន់តែខ្លាំង។ ពួកគេក៏បានឆក់ខ្ញុំនឹងឧបករណ៏អគ្គិសនី។ពួកគេធ្លាប់វាយខ្នងខ្ញុំយ៉ាងខ្លាំង បន្ទាប់ពីនោះមក ក្រលៀនរបស់ខ្ញុំចាប់ផ្តើមឈឺយ៉ាងយូរ។ បន្ទាប់ពីពួកគេបានបញ្ជូនខ្ញុំទៅ « Dnepr-1» ទីលានបាញ់ប្រហារដែលនៅក្នុងតំបន់ Dnepropetrovsk ។ ពួកគេបានធ្វើទារុណកម្មយើងដោយបោះចូលក្នុងសំបុកពស់ ដែលហាក់បីជាធ្វើអោយចំណាប់ខ្មាំងកំពុងជីករណ្តៅកប់ខ្លួនឯង។ ពួកគេធ្វើទារុណកម្មយើងសាហាវព្រៃផ្សៃរកនឹងបរិយាយមិនបាន។

**ថ្ងៃទី ៥ ខែ វិច្ឆិកា** នៅដូញៀតស្គ៏ កន្លែងលេងកីឡានៅក្នុងសាលារៀនលេខ ៦៣ ដែលស្ថិតនៅជិតព្រលានយន្តហោះបានទទួលរងនូវការបាញ់ផ្គក់ដែលបានបណ្តាលអោយក្មេងជំទង់ពីរនាក់ និង មនុស្សបួននាក់រងរបួស។

**ថ្ងៃទី ៥ ខែ វិច្ឆិកា** អង្គការសិទ្ធិមនុស្ស «លើកលែងទោសអន្តរជាតិ» បានលើកឡើងអំពីភាពចាំបាច់នៃការស៊ើបអង្កេតជាបន្ទាន់ ម៉ត់ចត់ និង ដោយឯករាជ្យនៅក្នុងករណីស្លាប់របស់កុមារពីរនាក់ដែលបណ្ដាលមកពីការបាញ់ប្លោងនៅដូញៀតស្ក៏។

**ថ្ងៃទី ៦ ខែ វិច្ឆិកា** កងសន្តិសុខជាតិអ៊ុយក្រែនបានបន្ថែមការបាញ់ផ្គក់មកលើដូញៀតស្ក៏ បើទោះជាពេលធ្វើបុណ្យសពរបស់កុមារដែលត្រូវបានសម្លាប់ ក្នុងកំឡុងពេលប្រយុទ្ធក៏ដោយ។ ការទម្លាក់គ្រាប់បែកនេះបានបណ្ដាលអោយមនុស្សយ៉ាងហោចណាស់ ៥នាក់បានស្លាប់ និង ជាង ១០នាក់រងរបួស។ កាំភ្លើងធំត្រូវបានគេបាញ់ផ្គក់ទៅលើសង្កាត់ Kiev, Kuibyshev និង Petrovsky។

**ថ្ងៃទី ៧ ខែវិច្ឆិកា** កងទ័ពអ៊ុយក្រែនបានបាញ់ផ្គក់មកដូញៀតស្ក។ មជ្ឈមណ្ឌលថែទាំសុខភាពពីរថ្ងៃជាប់គ្នាស្ថិតក្រោមការបាញ់ផ្គក់។

**ថ្ងៃទី ១៥ ខែវិច្ឆិកា** កងសន្តិសុខអ៊ុយក្រែនបានបើកការបាញ់ផ្គក់ទៅលើ Gorlovka (ភូមិភាគដូញៀតស្ក៏)។ផ្ទះប្រាំបួនជាន់មួយខ្នងត្រូវបានរងការខូចខាតយ៉ាងដំណំដោយសារការបាញ់ផ្គក់នេះ ហើយគ្រួសារមួយដែលមានសមាជិក ៤នាក់ (ឪពុកម្ដាយ កូនប្រុសអាយុ ៩ឆ្នាំ និង កូនស្រីអាយុ ៥ឆ្នាំ) បានស្លាប់បាត់បង់ជីវិត។

**ថ្ងៃទី ១៨ ខែវិច្ឆិកា** ពលរដ្ឋអ៊ុយក្រែនម្នាក់ឈ្មោះ A. Agafonov ត្រូវបានប៉ូលីសចាប់ឃុំខ្លួននៅ Kharkov ហើយបញ្ជូនទៅទីឆ្ងាយដោយកងសន្តិសុខអ៊ុយក្រែនដោយពុំមានអ្នកណាដឹង ក្រោយមកសាកសពត្រូវបានរកឃើញដោយមានស្លាកស្នាមនៃការធ្វើទារុណកម្ម។

**ថ្ងៃទី ២៧ ខែវិច្ឆិកា** ក្មេងជំទង់អាយុ ១២ឆ្នាំម្នាក់ និង ស្ត្រីម្នាក់ត្រូវបានសម្លាប់ដោយសារការបាញ់ផ្គក់កាំភ្លើងធំទៅលើភូមិមួយឈ្មោះ« Azotniy» ក្នុងសង្កាត់ Kuybyshevskiy (ភូមិភាគដូញៀតស្ក៏)។

**ការរឹតបន្តឹងសេរីភាពនៃប្រព័ន្ធផ្សព្វផ្សាយ និង សកម្មភាពអ្នកសារព័ត៌មាន**
**( ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨)**

**មាត្រាទី ៣**

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

**មាត្រាទី ៥**

គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅ អមនុស្ស ធម៌ ឬបន្ថោកបន្ទាបបានឡើយ។

**មាត្រាទី ៩**

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន តាមអំពើចិត្តឡើយ។

**មាត្រាទី ១៩**

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្ដែងមតិ។ សិទ្ធិនេះ រាប់បញ្ចូល ទាំងសេរីភាពក្នុងការប្រកាន់មតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការ

ផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទឹកដី ទោះតាមរយៈមធ្យោបាយសម្តែង មតិណាមួយក៏ដោយ។

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ**

(ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦)

**មាត្រា ៦**
១. មនុស្សគ្រប់រូបមានសិទ្ធរស់រានមានជីវិត។ សិទ្ធិនេះត្រូវបានការពារដោយច្បាប់។ គ្មានជនណាម្នាក់ត្រូវបានត្រូវគេដកហូតសិទ្ធិនេះឡើយ។
**មាត្រា ៩**
១. មនុស្សគ្រប់គ្នាមានសិទ្ធិមានសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ជាកម្មវត្ថុនៃការចាប់ខ្លួន ឬ ឃុំខ្លួនឡើយ។ គ្មានជនណាម្នាក់ត្រូវបានគេដកយកសេរីភាពលើកលែងតែក្នុងករណីដែលស្របជាមួយនីតិវិធីដូចដែលមានចែងនៅក្នុងច្បាប់។
**មាត្រាទី ១៩**
១.មនុស្សគ្រប់រូបមានសិទ្ធិប្រកាន់ខ្ជាប់នូវគំនិត ដោយគ្មានការរំខានណាមួយ។
២.មនុស្សគ្រប់រូបមានសិទ្ធិមានសេរីភាពបញ្ចេញមតិ ហើយសិទ្ធិនេះរួមមានសេរីភាពក្នុងការស្វែងរកទទួល និងចែករំលែកព័ត៌មាននិងគំនិតគ្រប់ប្រភេទដោយគ្មាព្រំដែន ទោះតាមរយៈផ្ទាល់មាត់ ជាសំណៅសរសេរ ឬ ជាការបោះពុម្ពក្នុងទម្រង់ជាសិល្បៈ ឬ តាមរយៈប្រព័ន្ធផ្សព្វផ្សាយតាមជម្រើសរបស់បុគ្គលនោះ។

**កតិកាសញ្ញាការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន**
**(ទីក្រុងរ៉ូម ថ្ងៃទី ៤ ខែ វិច្ឆិកា ១៩៥០)**
**មាត្រាទី ២ សិទ្ធិរស់រានមានជីវិត**
មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិតដែលការពារដោយច្បាប់។ គ្មានបុគ្គលណាម្នាក់នឹងត្រូវដកហូតជីវិតរបស់គាត់មានចេតនារក្សាទុកនៅក្នុងការប្រតិបត្តិនៃការកាត់ទោសរបស់តុលាការសម្រាប់បទល្មើសដែលការពិន័យនេះត្រូវបានផ្តល់ដោយច្បាប់។
**មាត្រាទី ៣ ការហាមប្រាមការធ្វើទារុណកម្ម**
គ្មានជនណាម្នាក់ជាកម្មវត្ថុនៃការធ្វើទារុណកម្មឬ ដោយការបន្ទាបបន្ថោកភាពថ្លៃថ្នូរ ឬ ដោយភាពគ្មានមនុស្សធម៌ ឬ ការធ្វើទណ្ឌកម្មឡើយ។
**មាត្រាទី ៥ សិទ្ធិមានសេរីភាព និង សន្តិសុខ**
មនុស្សគ្រប់រូបមានសិទ្ធិមានសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន។

**មាត្រាទី ១០ សេរីភាពនៃការបញ្ចេញមតិ**
១. មនុស្សគ្រប់រូបមានសិទ្ធិមានសេរីភាពក្នុងការបញ្ចេញ។ សិទ្ធិនេះរួមមានសេរីភាពក្នុងការប្រកាន់ខ្ជាប់នៅមតិយល់ឃើញ និង ទទួលបាននូវព័ត៌មាន និង គំនិតផ្សេងៗដោយគ្មានការរំខានដោយអាជ្ញាធររដ្ឋ ឬដោយគ្មានការកំណត់ព្រំដែន។ មាត្រានេះនឹងមិនការពាររដ្ឋពីការចាំបាច់នៃអាជ្ញាប័ណ្ណក្នុងការផ្សព្វផ្សាយ ទូរទស្សន៍ ឬ សហគ្រាសរោងកុន។

**កាតិកាសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងអំពើសាហាវព្រៃផ្សៃយ៉ងឃ្លង អមនុស្សធម៌ និង ការបន្ទាបបន្ថោកឬ ការធ្វើទុក្ខបុកម្នេញ (ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨៤)**
**មាត្រាទី២**
១. គ្រប់រដ្ឋភាគីត្រូវអនុវត្តអោយមានប្រសិទ្ធភាពតាមផ្លូវច្បាប់ រដ្ឋបាល តុលាការ ឬតាមនីតិវិធីដទៃទៀតដើម្បីការពារសកម្មភាពនៃការធ្វើទារុណកម្មកើតឡើងនៅគ្រប់ដែនដីក្រោមគតិយុត្តិរបស់ខ្លួន។
២. គ្មានការលើកលែងក្នុងកាលៈទេសៈណាមួយទោះរដ្ឋស្ថិតក្នុងសង្គ្រាម ឬ ទទួលការគំរាមកំហែងដោយសង្គ្រាម អសន្តិសុខនយោបាយផ្ទៃក្នុង ឬ ដោយសារករណីបន្ទាន់សាធារណៈណាមួយអាចត្រូវបានគេប្រើប្រាស់ដើម្បីធ្វើទារុណកម្មនោះឡើយ។
៣. គ្មានការបញ្ជាពីមន្ត្រីថ្នាក់លើឬអាជ្ញាធរសាធារណៈណាមួយអាចត្រូវបានគេប្រើប្រាស់ដើម្បីធ្វើទារុណកម្មនោះឡើយ។

**ថ្ងៃទី ១ ខែកក្កដា** នៅភូមិភាគឡូហានស្គ៍ ជិតកន្លែងត្រួតពិនិត្យពន្ធគយ « Izvarino» កងទ័ពអ៊ុយក្រែនបានបើកការបាញ់ប្រហារដោយកាំភ្លើងត្បាល់មកលើក្រុមអ្នកផលិតទូរទស្សន៍ Russian TVនិង REN TV។ជាលទ្ធផលនៃការបាញ់ផ្គក់នេះ អ្នកយកសារព័ត៌មាន D. Kulaga និង អ្នកកាន់កាមេរ៉ា V. Yudin បានរងរបួស។
**ថ្ងៃទី ១ ខែ កក្កដា** អ្នកថតរូប S. Kochetov ដែលសហការក្នុងការបោះពុម្ពផ្សាយប្រឆាំងនឹងរដ្ឋាភិបាលគៀវបានបាត់ខ្លួននៅ Kharkov ។ គាត់បានផ្ដិតយករូបថតអំពីរឿង «ឧទ្ទាមនៅឡូហានស្គ៍ក្នុងរូបថតផ្ដិតដោយអ្នកថតរូបKharkov ម្នាក់»។
**ថ្ងៃទី ៣ ខែ កក្កដា** ក្រុមទូរទស្សន៍ប៉ុស្ដិ៍លេខមួយ រងការបាញ់ប្រហារនៅ Slavyansk ។
**ថ្ងៃទី ៤ ខែកក្កដា** ក្រុមទូរទស្សន៍ប៉ុស្ដិ៍លេខប្រាំបានទទួលរងការបាញ់ប្រហារពីភាគីអ៊ុយក្រែនមិនឆ្ងាយពីព្រំដែន Rostov ។
**ថ្ងៃទី ៥ កក្កដា** នៅគៀវ អង្គការជាតិនិយមជ្រុល «ពាក្យសច្ចៈ» (Chestnoe Slovo) បានបំផ្លិចបំផ្លាញការិយាល័យបោះពុម្ព កាសែត « Vesti» ដែលតែងតែព្យាយាមផ្សព្វផ្សាយព័ត៌មានស្ដីពីការវិវត្តនៃការប្រយុទ្ធគ្នានៅភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែន។ អ្នកកាសែតម្នាក់បានរងរបួស និង សន្តិសុខម្នាក់បានបាក់ចង្ការ។

**ថ្ងៃទី ៩ ខែកក្កដា** ជាលទ្ធផលនៃការបាញ់ផ្លោក់ដោយកងទ័ពអ៊ុយក្រែននៅតំបន់ក្បែរ ឡូហានស្គ៍ អ្នកកាសែតRoman Bochkala បំរើការនៅប៉ុស្តិ៍ទូរទស្សន៍ អ៊ុយក្រែនអន្តរជាតិ បានទទួលរងរបួសជាទម្ងន់។
**ថ្ងៃទី ៩ ខែកក្កដា** សកម្មជន « EuroMaidan »បានទាមទារអោយបិទកាសែតអ៊ុយក្រែន « Vesti » ដែលនាំមុខគេដោយសារកាសែតនេះបានបោះពុម្ពផ្សាយព័ត៌មានស្តីពីព្រឹត្តិការណ៏នៅ ម៉ៃដាន និង អំពីការវិវត្តនៃការប្រយុទ្ធគ្នានៅភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែន។
**ថ្ងៃទី ១១ ខែ កក្កដា** អ្នកសារព័ត៌មានរុស្ស៊ី រួមទាំងអ្នកកាសែតមកពីទីភ្នាក់ងារការសែត«Rossiyskaya Gazeta»បានរងការបាញ់ប្រហារនៅឡូហានស្គ៍។
**នៅថ្ងៃទី ១១ ខែ កក្កដា** នៅក្នុងទីប្រជុំជន និង ទីក្រុងនានា ក្នុងភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែនដែលគ្រប់គ្រងដោយកងទ័ពអ៊ុយក្រែន ការផ្សព្វផ្សាយទូរទស្សន៏រុស្ស៊ី ( Russian TV ) ត្រូវបានកាត់ផ្តាច់។ បណ្តាញទូរទស្សន៏ត្រូវបានគេផ្លាស់ប្តូរនៅ Artemovsk, Konstantinovka, Dimitrov និង Druzhkovka ។ មុននេះបន្តិច ប៉ុស្តិ៍ទូរទស្សន៏រុស្ស៊ីនៅ Slavyansk, Mariupol និង ភូមិភាគ Odessa ត្រូវបានកាត់ផ្តាច់។
**ថ្ងៃទី ១២ កក្កដា** អ្នកកាសែតឈ្មោះ V. Moroz មកពីប៉ុស្តិ៍ទូរទស្សន៏ LifeNews បានរងរបួសដៃដែលជាលទ្ធផលនៃការបាញ់ផ្លោក់ដោយកាំភ្លើងត្បាល់ពីសំណាក់កងទ័ពអ៊ុយក្រែននៅឡូហានស្គ៍។
**ថ្ងៃទី ១៣ ខែកក្កដា** អ្នកកាសែត និង ជានាយកបោះពុម្ពកាសែត «ខ្ញុំចង់រស់នៅសហភាពសូវៀត» លោក S. Dolgov ត្រូវបានគេសម្លាប់នៅ Dnepropetrovsk ។ នៅថ្ងៃទី ១៨ មិថុនា គាត់ត្រូវបានគេចាប់ពង្រត់ដោយកងទ័ពអ៊ុយក្រែនក្នុងអង្គភាព « Dnepr-១» ហើយធ្វើទារុណកម្ម។
**ថ្ងៃទី ១៤ កក្កដា** អ្នកសារព័ត៌មានប៉ុស្តិ៍ «រុស្ស៊ី១» មិនត្រូវបានគេអនុញ្ញាតអោយចូលក្នុងប្រទេសអ៊ុយក្រែនបើទោះជាគាត់មានឯកសារគ្រប់គ្រាន់ និង សំបុត្រត្រលប់ទៅវិញក៏ដោយ។
**ថ្ងៃទី ១៤ ខែកក្កដា** ក្រសួងមហាផ្ទៃអ៊ុយក្រែនអំពាវនាវដោយហាមប្រាមលោក K. Ernst អគ្គនាយកប៉ុស្តិ៍លេខ១ លោកG. Krichevsky អគ្គនាយកប៉ុស្តិ៍ទូរទស្សន៏«ផ្កាយ» លោក A. Gabrelyanov អគ្គនាយកប៉ុស្តិ៍ *LifeNews* លោកA. Zlatopolsky អគ្គនាយកប៉ុស្តិ៍«រុស្ស៊ី១» លោកស្រី U. Bystritskaya អគ្គនាយកប៉ុស្តិ៍ « *TV Center* » ព្រមទាំងអ្នកសារព័ត៌មាន៣០០នាក់ទៀត មិនអោយឆ្លងដែនចូលទឹកដីអ៊ុយក្រែន និង បណ្តាប្រទេសអ៊ឺរ៉ុប។ ក្រសួងមហាផ្ទៃបានជូនដំណឹងដល់ក្រសួងការបរទេសអ៊ុយក្រែនអោយដាក់សុំសំនើទៅសហភាពអ៊ឺរ៉ុបដើម្បី«ត្រួតពិនិត្យអ្នកសារព័ត៌មានទាំងអស់នេះ និង បដិសេធពួកគេមិនអោយឆ្លងកាត់»។
**ថ្ងៃទី ២១ ខែកក្កដា** វិទ្យាស្ថានសន្តិសុខសារព័ត៌មានអន្តរជាតិបានដាក់ចំណាត់ថ្នាក់អ៊ុយក្រែនជាប្រទេសដែលមានគ្រោះថ្នាក់ជាងគេបំផុតក្នុងលោកសម្រាប់អ្នកសារព័ត៌មាន។ ចំណែកប្រទេសអ៊ីរ៉ាក់បានប្តូរទៅចំណាត់ថ្នាក់លេខពីរវិញ ជាប្រទេសដែលគ្រោះថ្នាក់បំផុត។
**ថ្ងៃទី ២២-២៣( យប់ )** អ្នកសារព័ត៌មាន៤នាក់ដែលម្នាក់មានសញ្ជាតិអង់គ្លេស លោក G.Phillips ជាអ្នកសរសេរព័ត៌មាន និង ឆ្លើយឆ្លងព័ត៌មានអោយប៉ុស្តិ៍ «រុស្ស៊ីថ្ងៃនេះ» និង លោក V. Aksenov មកពីទី

ភ្នាក់ងារសារព័ត៌មាន Anna-News ត្រូវបានគេអោយដឹងថា បានបាត់ខ្លួនក្នុងកំឡុងពេលនៃការប្រយុទ្ធគ្នានៅភាគអាគ្នេយ៍អ៊ុយក្រែន។

**ថ្ងៃទី ២៣ ខែកក្កដា** ដោយសារការបន្តគំរាមកំហែងអ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសអ៊ុយក្រែនដោយរួមទាំងការចាប់ពង្រត់អ្នកសារព័ត៌មានក្នុងពេលថ្មីៗខណៈដែលពួកគេកំពុងធ្វើបទយកការណ៍ស្តីអំពីការប្រយុទ្ធគ្នានៅភាគខាងកើតប្រទេស។ អ្នកតំណាង OSCE ទទួលបន្ទុកសេរីភាពប្រព័ន្ធផ្សព្វផ្សាយ លោក D. Mijatović បានបញ្ជាក់ជាថ្មីដែលថា ការរំលោភបំពានលើអ្នកសារព័ត៌មានត្រូវតែឈប់។

**ថ្ងៃទី ២៥ កក្កដា** ក្រុមប្រឹក្សាជាតិអ៊ុយក្រែនសម្រាប់ការផ្សព្វផ្សាយទូរទស្សន៍ និង វិទ្យុបានដាក់កំហិតដល់ក្រុមហ៊ុនផ្គត់ផ្គង់បណ្តាញអោយបញ្ឈប់ការផ្សាយទូរទស្សន៍រុស្ស៊ីចំនួន៤ គឺ RTR-Planet Russia 24 NTV-World និង TV Center International ។

**ថ្ងៃទី ២៥ ខែកក្កដា** កងទ័ពអ៊ុយក្រែនបានបើកការបាញ់ប្រហារមកលើក្រុមអ្នកថតកាមេរ៉ានៃប៉ុស្តិ៍ទូរទស្សន៍រុស្ស៊ី២៤ ដែលកំពុងចុះយកព័ត៌មានក្នុងសង្កាត់ Primiussky khutor នៃភូមិភាគ Rostov ។ ថ្ងៃទី ២៧ ខែកក្កដា ពលរដ្ឋសញ្ជាតិប៉ូឡូញ លោក B. Zalevskaya អ្នកឆ្លើយឆ្លងព័ត៌មានពីអ៊ុយក្រែនអោយប៉ុស្តិ៍ទូរទស្សន៍ « Espresso » បានទទួលការបាញ់ប្រហារក្នុងកំឡុងពេលប្រតិបត្តិការនៅភាគខាងត្បូង-កើត។

**ថ្ងៃទី ២៨ ខែកក្កដា** ការិយាល័យព្រះរាជអាជ្ញា នៅ Melitopol បានចាប់ផ្តើមការកាត់ក្តីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកជំនួញ I. Raysky ដែលទទួលខុសត្រូវក្នុងការចាក់ផ្សាយប៉ុស្តិ៍ទូរទស្សន៍រុស្ស៊ីដែលត្រូវបានអាជ្ញាធរហាមប្រាមចាក់ផ្សាយក្នុងប្រទេសអ៊ុយក្រែន។

**ថ្ងៃទី ២៩ ខែកក្កដា** ទីភ្នាក់ងាររោងភាពយន្តរដ្ឋរបស់អ៊ុយក្រែនបានបដិសេធមិនផ្តល់អាជ្ញាប័ណ្ណដល់ការចែកចាយភាពយន្តរុស្ស៊ី «ឆ្នាំពណ៌ស» និង « Poddubny» ។ យោងតាមអ្នកជំនាញ រឿងទាំងពីរបានឆ្លុះបញ្ចាំងអំពីការមើលងាយភាសាអ៊ុយក្រែន ប្រជាជន និង ភាពជារដ្ឋរបស់ប្រទេសអ៊ុយក្រែន។ ការពិតមួយចំនួនត្រូវបានគេបំភ្លៃ និង សរសេរឡើងវិញចំណោញដល់ប្រទេសរុស្ស៊ី។

**ថ្ងៃទី ៣១ ខែកក្កដា** គណៈកម្មាធិការជាតិអ៊ុយក្រែនទទួលបន្ទុកការផ្សព្វផ្សាយវិទ្យុ និង ទូរទស្សន៍បានចាប់ផ្តើមសិក្សាលើលទ្ធភាពនៃការហាមប្រាមការបោះពុម្ពដែលគាំទ្ររុស្ស៊ី។ ភ្នាក់ងារសន្តិសុខជាតិអ៊ុយក្រែនបានចាប់ផ្តើមពិនិត្យលើករណីព្រហ្មទណ្ឌប្រឆាំងទៅនឹងសារព័ត៌មានក្នុងស្រុកមួយចំនួន។

**ថ្ងៃទី ១ សីហា** កងកម្លាំងពិសេសអ៊ុយក្រែនបានឃុំឃាំងអ្នកស្រី A. Eprimyan ដែលជាបុគ្គលិកបំរើការអោយទីភ្នាក់ងារ *RT Ruptly* ។ បន្ទាប់ពីការសួរចម្លើយ នាងត្រូវបានគេតម្រូវអោយចាកចេញពីប្រទេសក្នុងរយៈពេលពីរថ្ងៃ។

**ថ្ងៃទី៣ ខែ សីហា** អ្នកសារព័ត៌មាន ទូរទស្សន៍«ផ្កាយ»បានទទួលរងការបាញ់ប្រហារដោយកងទ័ពអ៊ុយក្រែននៅជិតកន្លែងត្រួតពិនិត្យ «Gukovo» ក្នុងភូមិភាគ Rostov ជាប់ព្រំដែនជាមួយអ៊ុយក្រែន។

**ថ្ងៃទី ៤ ខែសីហា** អ្នករៀបចំកម្មវិធី និង អ្នកបើករថយន្តមកពីទីភ្នាក់ងារ Anna news រងរបួសនៅឡូហានស្គ័។ ក្រុមអ្នកថតកាមេរ៉ាកំពុងធ្វើដំណើរទៅកាន់តំបន់បាញ់ផ្តក់ដោយកងសន្តិសុខជាតិអ៊ុយក្រែន

នៅពេលដែលគ្រាប់បានផ្ទុះនៅចំងាយប៉ុន្មានម៉ែត្រពីឡានរបស់ពួកគេ។ អ្នកបើកបរបានរងរបួសខ្នង ផ្នែកខាងលើ ចំណែកអ្នករៀបចំកម្មវិធីទូរទស្សន៍ M.Andreev បានរងរបួសដៃខាងស្តាំ។
**ថ្ងៃទី ៥ ខែ សីហា** អ្នកសារព័ត៌មានឈ្មោះ A. Stenin ដែលរាយការណ៍អំពីស្ថានភាពនៅភាគខាងកើត អ៊ុយក្រែនបានបាត់ការទំនាក់ទំនងជាមួយនឹងការិយាល័យនិពន្ធ។
**ថ្ងៃទី ៧ ខែ សីហា** ក្រុមប្រឹក្សាជាតិអ៊ុយក្រែនទទួលបន្ទុកការផ្សព្វផ្សាយទូរទស្សន៍ និង វិទ្យុបានហាមប្រាមមិនអោយប៉ុស្តិ៍ *RBC TV ។*
**ថ្ងៃទី ១៣ ខែសីហា** ជនអនាមិកមួយក្រុមបានប្រើប្រាស់ដបស្រាក្រឡុកម៉ាក Molotov វាយទៅលើរោងកុនBommer នៅ Kharkov ជាទីកន្លែងដែលរឿង«ម៉ៃដាន់»ដែលដឹកនាំការសំដែងដោយ S. Loznitsa កំពុងចាក់បញ្ចាំង។
**ថ្ងៃទី ១៥ ខែសីហា** ជនអនាមិកបានវាយទៅលើបុគ្គលិកប៉ុស្តិ៍ទូរទស្សន៍ Spilno នៅ Maidan Nezalezhnosti ( ទីលានឯករាជ្យម៉ៃដាន់ ) នៅទីក្រុងគៀវ ។
**ថ្ងៃទី ២១ ខែ សីហា** ទីភ្នាក់ងារសន្តិសុខជាតិអ៊ុយក្រែនបានរឹបអូសកាសែត «វណ្ណៈពលករ» ដែលបានចុះបញ្ជីក្រោមច្បាប់អ៊ុយក្រែន នៅរោងពុម្ពក្នុងក្រុងគៀវ។
**ថ្ងៃទី ២២ ខែ សីហា** អ្នកសារព័ត៌មានមកពីទីភ្នាក់ងារព័ត៌មានអន្តរជាតិ «រុស្ស៊ីថ្ងៃនេះ» «អ៊ីតារ តាស្ស» «ប៉ុស្តិ៍លេខ១» «NTV» និង ប្រព័ន្ធផ្សព្វផ្សាយរុស្ស៊ីមួយចំនួនទៀតបានទទួលការបាញ់ផ្តក់ដោយទ័ពអ៊ុយក្រែនក្នុងខណៈបំពេញការងាររបស់ពួកគេនៅឡូហានស្គ៍។
**ថ្ងៃទី ២៤ ខែសីហា** អ្នកនាង A. Mokhova ដែលជាអ្នកឆ្លើយឆ្លងព័ត៌មានពីក្រុមហ៊ុនផ្សព្វផ្សាយទូរទស្សន៍និងវិទ្យុដ្វេគ្រីម៉េ និង សហការីរបស់នាង លោក A. Shapovalov ត្រូវបានឃុំឃាំងដោយសន្តិសុខជាតិអ៊ុយក្រែនខណៈដែលធ្វើដំណើរលើផ្លូវចន្លោះ ដូញៀតស្គ៍ និង ម៉ាកេយ៉េវកា ( Makeevka ) ។ ពួកគេត្រូវបានដោះលែងអោយមានសេរីភាពក្នុងពេលដែលមានការដោះដូរអ្នកទោសរវាងកងទ័ពអ៊ុយក្រែន និង ក្រុមអ្នកប្រយុទ្ធការពារខ្លួននៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៤។
**ថ្ងៃទី ២៥ ខែ សីហា** អ្នកសារព័ត៌មានមកពី Crimean telegraph មានឈ្មោះ M. Vasilenko ជាអ្នកថតរូប និងឈ្មោះ E. Koroleva អ្នកឆ្លើយឆ្លងព័ត៌មានត្រូវបានឃុំខ្លួនដោយក្រុម « Right Sector » នៅត្រង់ចំណុចត្រួតពិនិត្យក្នុងភូមិភាគដូញៀតស្គ៍។
**ថ្ងៃទី ២៨ ខែ សីហា** ក្រុមប្រឹក្សាជាតិអ៊ុយក្រែនទទួលបន្ទុកការផ្សពផ្សាយទូរទស្សន៍ និង វិទ្យុ បានចេញផ្សាយនូវបញ្ជីឈ្មោះអ្នកសារព័ត៌មាន និង នាយកប៉ុស្តិ៍ទូរទស្សន៍រុស្ស៊ីដែលមិនអនុញ្ញាតិអោយចូលទៅក្នុងប្រទេសអ៊ុយក្រែន។ បញ្ជីនេះមានឈ្មោះ ៤៩ នាក់ដែលត្រូវបានគេបញ្ជូនអោយភ្នាក់ងារសន្តិសុខជាតិអ៊ុយក្រែន ។
**ថ្ងៃទី ៣០ ខែ សីហា** បុគ្គលិកអ៊ុយក្រែន៣នាក់មកពីប៉ុស្តិ៍ទូរទស្សន៍អ៊ុយក្រែន Espresso TV ( R.Shapovnikov )នាយកគម្រោង « Highway patrol» អ្នកសារព័ត៌មាន E. Vorobiev និង M. Chkan ត្រូវបានគេរាយការណ៍ថាបានបាត់ខ្លួននៅជិតតំបន់ Ilovaisk ភូមិភាគដូញៀតស្គ៍។

**ថ្ងៃទី ១ ខែ កញ្ញា** អ្នកកាសែតរុស្ស៊ីពីរនាក់ លោក T. Olevsky និង O. Jema ត្រូវបានគេរាយការណ៍ថាបានបាត់ខ្លួននៅជិតតំបន់ Mariupol ។ ក្រោយមកមានលេចព័ត៌មានថា ពួកគេត្រូវបានឃុំខ្លួនដោយក្រុមប្រយុទ្ធនៃអង្គភាព «Azov»។

**ថ្ងៃទី ២ ខែកញ្ញា** សាកសពរបស់លោក A. Stenin អ្នកកាសែតបំរើការនៅទូរទស្សន៍ «រុស្ស៊ីថ្ងៃនេះ» ត្រូវបានគេរកឃើញនៅក្នុងឡានមួយក្បែរក្រុង Snezhnoe ។ គាត់ត្រូវបានគេរាយការណ៍ថាបានបាត់ខ្លួននៅដើមខែកក្កដាក្នុងភាគខាងកើតអ៊ុយក្រែនក្នុងតំបន់ដែលកាន់កាប់ដោយកងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ៤ ខែកញ្ញា** គណៈកម្មាធិការអន្តរជាតិទទួលបន្ទុកការការពារអ្នកសារព័ត៌មានបានផ្តន្ទាទោសករណីឃាតកម្មលើអ្នកកាសែត A. Stenin ដែលបំរើការអោយទូរទស្សន៍ «រុស្ស៊ីថ្ងៃនេះ»។ A. Stenin គឺជាអ្នកកាសែតទី៧ហើយដែលត្រូវបានគេសម្លាប់នៅក្នុងប្រទេសអ៊ុយក្រែនចាប់តាំងពីដើមឆ្នាំ ២០១៤។

**ថ្ងៃទី ៥ ខែកញ្ញា** ក្រុមអ្នកយកការណ៍មកពីទូរទស្សន៍ REN TV ទទួលរងការបាញ់ផ្គត់ពីកាំភ្លើងធំអ៊ុយក្រែនខណៈបំពេញការងារនៅភាគកណ្តាលដូញៀតស្ក៍។

**ថ្ងៃទី ៥ ខែកញ្ញា** នាយកដ្ឋាននៃក្រសួងមហាផ្ទៃនៃតំបន់ Poltava បានអោយដឹងថា នាយកដ្ឋានមានគោលបំណងចាប់ផ្តើមពិនិត្យនិងគ្រប់គ្រងលើ«ការផ្សព្វផ្សាយនិងការមើល»នៃបណ្តាប៉ុស្តិ៍ទូរទស្សន៍រុស្ស៊ីដែលបានហាមឃាត់។

**ថ្ងៃទី ១១ ខែកញ្ញា** ប្រធានការិយាល័យនិពន្ធនៃការសែត *Vesti* អ៊ុយក្រែនត្រូវបានគេតាមស្រាវជ្រាវរកចាប់ខ្លួននៅក្នុងក្រុងគៀវ។ នេះជាលើកទី២នៃការស្រាវជ្រាវតាំងពីដើមឆ្នាំនេះ។

ថ្ងៃទី ១១ លោក U. Artemenko នាយកនៃក្រុមប្រឹក្សាជាតិអ៊ុយក្រែនទទួលបន្ទុកការផ្សព្វផ្សាយទូរទស្សន៍និងវិទ្យុបានប្រកាសថា អ្នកតំណាងប្រព័ន្ធរុស្ស៊ីចំនួន ៣៥នាក់ត្រូវបានហាមប្រាមមិនអោយចូលអ៊ុយក្រែនឡើយ។

**ថ្ងៃទី ១១ ខែ កញ្ញា** ប្រធានការិយាល័យនិពន្ធនៃកាសែត *Vesti* ត្រូវបានគេតាមចាប់ខ្លួន។ ភ្នាក់ងារសន្តិសុខជាតិបានរឹបអូសឯកសារបោះពុម្ពនានា។

**ថ្ងៃទី ១២ ខែកញ្ញា** ដោយសារការវាយឆ្មក់ចូលទៅក្នុងការិយាល័យកាសែត *Vesti* នៅក្នុងក្រុងគៀវ លោកD. Mijatović អ្នកតំណាងនៃ OSCE ដែលទទួលបន្ទុកសេរីភាពប្រព័ន្ធផ្សព្វផ្សាយ បានស្នើអោយអាជ្ញាធរអ៊ុយក្រែនគោរពសិទ្ធិប្រព័ន្ធផ្សព្វផ្សាយ។

**ថ្ងៃទី ១៣ ខែកញ្ញា** កងទ័ពអ៊ុយក្រែនបានឃុំខ្លួនអ្នកស្រី I. Guzhva ដែលជានិពន្ធនាយកនៃកាសែត *Vesti* ។

**ថ្ងៃទី២៩ ខែកញ្ញា** អ្នកសារព័ត៌មាន REN TV បានទទួលការបាញ់ប្រហារនៅជិតព្រលានយន្តហោះដូញៀតស្ក៍។

**ថ្ងៃទី ១ ខែតុលា** លោក M. Musin អ្នកវិទ្យាសាស្ត្ររុស្ស៊ី និង ជានាយកគម្រោងសារព័ត៌មាន Novorossia Anna-news រួមទាំងសហការីត្រូវបានចាប់ខ្លួនដោយកងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ២ ខែតុលា** បុគ្គលិកនៃប៉ុស្តិ៍សាធារណរដ្ឋលេខ២ នៃសាធារណរដ្ឋដូញៀតស្កិ៍បានប្រកាសអោយដឹងថាកងទ័ពអ៊ុយក្រែនបានបាញ់ផ្គត់មកលើការិយាល័យកណ្តាលរបស់ខ្លួន។
**ថ្ងៃទី ១៤ ខែតុលា**ក្រុមអ្នកយកព័ត៌មាន LifeNews បានទទួលការបាញ់ផ្គត់នៅជិតព្រលានយន្តហោះដូញៀតស្កិ៍។
**ថ្ងៃទី ១៥ ខែតុលា** លោក A. Dotsenko ជាអ្នកកាសែតមកពីប៉ុស្តិ៍ទូរទស្សន៍លេខ ៧ បានទទួលការបាញ់ប្រហារនៅ Odessa ដោយសារគាត់បានជួយសហការីជនជាតិរុស្ស៊ីរៀបចំរបាយការណ៍អំពីស្តូបរំលឹកដល់អ្នកដែលបានកសាងទីក្រុង។
**ថ្ងៃទី ៦ ខែតុលា** គណៈកម្មាធិការជាតិទទួលបន្ទុកការផ្សព្វផ្សាយវិទ្យុ និងទូរទស្សន៍បានចាត់វិធានការណ៍ក្នុងក្របខណ្ឌ «លុបបំបាត់ចោលនូវព័ត៌មានជាតិពីសារព័ត៌មានរបស់ពួកបំបែករដ្ឋ»ដែលបានបណ្តាលអោយមានការលុបចោលនៃអាជ្ញាប័ណ្ណមួយចំនួនពីទីភ្នាក់ងារព័ត៌មាននៅអ៊ុយក្រែន។
**ថ្ងៃទី ២២ ខែតុលា** លោក E. Anokhin ប្រធាននិពន្ធនាយកនៃគេហទំព័រ «មជ្ឈមណ្ឌលព័ត៌មាន» ត្រូវបានគេចាប់ខ្លួននៅ អូដេសា។ ការិយាល័យនិពន្ធបានហៅការចាប់ខ្លួននេះគឺជាប់ទាក់ទងសុទ្ធសាធទៅនឹងសម្ពាធនយោបាយដែលធ្វើឡើងដោយអាជ្ញាធរគៀវ។
**ថ្ងៃទី ២២ ខែតុលា** អ្នកឆ្លើយឆ្លងពីភ្នាក់ងារសារព័ត៌មានស៊ីវិល *Ridus* ត្រូវបានគេវាយតបនៅជិតការិយាល័យនៃគណបក្ស *Parnas* ដែលមិនទាន់ចុះបញ្ជី ជាទីកន្លែងដែលមានការបញ្ចាំងរឿងអំពីអាកាសយានិកអ៊ុយក្រែនN. Savchenko ។
**ថ្ងៃទី ២៣ ខែតុលា** ពិធីករទូរទស្សន៍លោក E. Kiselev មិនត្រូវបានគេអនុញ្ញាតិអោយឆ្លងកាត់ព្រំដែននៅព្រលានលានយន្តហោះ បូរីប៉ូល និងត្រូវបានគេប្រគល់នូវបញ្ជាអោយបញ្ជូនខ្លួន។ ក្រោយមកទើបគេដឹងថានេះជាកំហុសពីព្រោះមានការភ័ន្តច្រលំជាមួយនឹងពិធីករទូរទស្សន៍រុស្ស៊ីដែលមានឈ្មោះដូចគ្នា។
**ថ្ងៃទី ២៤តុលា** ប្រធានការិយាល័យក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍នៅអ៊ុយក្រែន «សមាគមប៉ុស្តិ៍ទូរទស្សន៍រុស្ស៊ី» *Torsat* និង *Sattelecom* ត្រូវបានចាប់ខ្លួន។
**ថ្ងៃទី ២៦ ខែតុលា** កងអង្គរក្សនៃមេបក្ស Radical Party លោក O. Lyashko បានវាយតប់ទៅលើក្រុមអ្នកយកការណ៍មកពីទូរទស្សន៍ «សេវាកម្មសារព័ត៌មាន» នៃប៉ុស្តិ៍អ៊ុយក្រែន ១+១ ។
**ថ្ងៃទី ៣០ ខែតុលា** ក្រុមអ្នកយកព័ត៌មានជាភាសាអារ៉ាប់នៃប៉ុស្តិ៍«រុស្ស៊ីថ្ងៃនេះ» ត្រូវបានគេបាញ់ប្រហារក្នុងតំបន់ឡូហានស្កិ៍។ មិនមានអ្នករងរបួសនោះឡើយ។ ប៉ុស្តិ៍ទូរទស្សន៍បានអោយដឹងថា ការបាញ់ប្រហារនេះកើតឡើងនៅពេលដែលអ្នកឆ្លើយឆ្លងព័ត៌មានA. Knishenko និងអ្នករៀបចំកម្មវិធីទូរទស្សន៍ A. Zhukov ព្រមទាំងជំនួយការលោក N. Bocharov ដែលពាក់អាវពណ៌ខៀវខ្ចីដោយមានដាក់ពាក្យសំគាល់ «សារព័ត៌មាន» ចាប់ផ្តើមធ្វើបទយកការណ៍នៅត្រង់កន្លែងត្រួតពិនិត្យក្នុងជួរខ្សែត្រៀមខាងមុខ។
**ថ្ងៃទី ៤ ខែ វិច្ឆិកា** កងទ័ពដែលមកពីម៉ៃដានក្នុងក្រុងគៀវបានបញ្ឈប់និងបញ្ជូនអ្នកកាសែតស្ត្រីម្នាក់មកពីទីភ្នាក់ងារសារព័ត៌មានា « LifeNews» ។ អ្នកសារព័ត៌មានអ៊ុយក្រែនជាច្រើនបានចោមរោមអ្នកយក

ព័ត៌មានរុស្ស៊ីE. Zmanovskaya ដោយបានចោទសួរសំណួរថា តើនាងសំអាងលើអ្វីទើបមកធ្វើការនៅប្រទេសអ៊ុយក្រែនដោយមិនមានការអនុញ្ញាតិ។ អ្នកនាង E. Zmanovskaya នៅជាប់ខ្លួនមានតែប័ណ្ណសំគាល់ខ្លួន ចំណែកលិខិតឆ្លងដែននាងមិនបានយកនោះទេ ពីព្រោះជាច្រើនសារមកហើយវាត្រូវបានគេព្យាយាមហែកចោល។ អ្នកសារព័ត៌មានអ៊ុយក្រែនជិត ៤០ នាក់បានចោទសួរសំនួរជាច្រើនមកលើអ្នកកាសែតរុស្ស៊ីរូបនេះ ហើយថែមទាំងស្រែកជេរជៀលថែមទៀតផង រហូតមានការបញ្ជូនអ្នកកាសែតទៅប៉ុស្តិ៍ប៉ូលីស។ នាងត្រូវបានសហការីដែលធ្វើការជាមួយយកលិខិតឆ្លងដែនអោយ។ យោងតាមច្បាប់អ៊ុយក្រែន អ្នកសារព័ត៌មាននឹងអាចត្រូវបានគេបញ្ជូនត្រលប់វិញ។

**ការរំលោភបំពានសិទ្ធិមានសេរីភាពជួបប្រជុំ និង សមាគម ការបោះឆ្នោតដោយសេរី ការភ័យខ្លាច និង ការចាប់ពង្រត់គូប្រជែងនយោបាយ**

**សេចក្តីប្រកាសសិទ្ធិមនុស្សជាសកល**

**(ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨)**

**មាត្រាទី ៥**

គ្មានជនណាម្នាក់ជាកម្មវត្ថុនៃការធ្វើទារុណកម្មឬ អំពើឃោរឃៅគ្មានមនុស្សធម៌ ឬបន្ទាបបន្ថោកឡើយ

**មាត្រាទី ៧**

មនុស្សគ្រប់រូបសុទ្ធតែស្មើគ្នានៅចំពោះមុខច្បាប់ ហើយនិងទទួលបានការការពារពីច្បាប់។ មនុស្សគ្រប់រូបសុទ្ធតែបានទទួលការការពារពីការរើសអើង និង ការញុះញង់អោយមានការរើសអើង។

**មាត្រាទី ៩**

គ្មានជនណាម្នាក់ជាកម្មវត្ថុនៃការចាប់ខ្លួន ការឃុំខ្លួន និង និរទេសឡើយ។

**មាត្រាទី ១២**

គ្មានជនណាម្នាក់ជាកម្មវត្ថុនៃការឃាយីភាពសំងាត់របស់ខ្លួន គ្រួសារ ផ្ទះ ឬ ប៉ះពាល់ដល់កិត្តិយស និង កិត្តិនាមឡើយ។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារដោយច្បាប់ប្រឆាំងនឹងការឃាយី និង វាយប្រហារណាមួយ។

**មាត្រាទី ២០**

១. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេរីភាពជួបប្រជុំ និង ធ្វើជាសមាគមដោយសន្តិវិធី។

**ថ្ងៃទី ៣ ខែ កក្កដា** នៅជិតអគារសភាអ៊ុយក្រែនមានស្រ្តីមួយក្រុមហៅខ្លួនថាជា «មាតានៃ Donbass» បានព្យាយាមធ្វើបាតុកម្ម។អ្នកចូលរួមបានច្រៀង «យើងប្រឆាំងនឹងសហភាពអឺរ៉ុប និង អាមេរិក យើងចង់បានសន្តិភាព» ។ ប៉ូលីសបានបង្ខំស្រ្តីទាំងនោះអោយចាកចេញពីអគារសភាដោយចោទប្រកាន់ថាស្រ្តីទាំងនោះ«បានវាយប្រហារមកលើប៉ូលីស»។

**ថ្ងៃទី ៧ ខែកក្កដា** អ្នកគាំទ្រ «ម៉ៃដាន់អឺរ៉ុប» បានគម្រាមលោក V. Klichko អភិបាលក្រុងគៀវ ដោយការដុតកំទេចអគារសាលាក្រុង។ អភិបាលក្រុងបានទទួលស្គាល់ថា រស់នៅកណ្ដាលក្រុងគៀវប្រកបដោយគ្រោះថ្នាក់។

**ថ្ងៃទី ៨ ខែ កក្កដា** នៅ Slavyansk លោក O. Lyashko ប្រធានសភាវងអ៊ុយក្រែនអមដោយមនុស្សដែលប្រដាប់ដោយអាវុធបានមកដល់ប្រឹក្សាក្រុង និង បានបង្ខំអោយលោក  A. Samsonov លេខាធិការនៃក្រុមប្រឹក្សាក្រុងចុះហត្ថលេខាសុំលាលែងពីតំណែងជាអ្វីដែលលោក A. Samsonov សារភាពថា លោកគឺជា«មនុស្សកំសាក និង ជាជនក្បត់»។ បន្ទាប់ពីបង្ខំអោយចាកចេញដោយកម្លាំងប្រដាប់អាវុធ លោកនៅបន្តរស់នៅក្នុង Slavyansk។

**ថ្ងៃទី ៨ ខែកក្កដា** ក្រុម «ស្លាបខាងស្ដាំ» បានចាប់លោក S. Sazhko ដែលជាអភិបាលក្រុង Kurakhovo (ភូមិភាគដូញៀតស្ក៏) ហើយនាំទៅកាន់កន្លែងមិនស្គាល់ដើម្បីអោយលោកធ្វើសហប្រតិបត្តិការជាមួយកងកម្លាំងនៅ Donbass ។

**ថ្ងៃទី៨ខែកក្កដា** ក្រសួងយុត្តិធម៌អ៊ុយក្រែនបានបញ្ជាអោយហាមប្រាមសកម្មភាពគណបក្សកុម្មុយនិស្តអ៊ុយក្រែនពាក្យបណ្ដឹងត្រូវបានគេបញ្ជូនទៅអោយតុលាការរដ្ឋបាលតំបន់នៃទីក្រុងគៀវ។ ក្នុងពេលថ្មីៗនេះ សមាជិកគណបក្សបានរិះគន់ជាញឹកញាប់អាជ្ញាធរអ៊ុយក្រែនចំពោះការបើកប្រតិបត្តិការប្រយុទ្ធនៅតំបន់ភាគខាងកើតប្រទេស

**ថ្ងៃទី ១១ ខែ កក្កដា** ក្រសួងមហាផ្ទៃអ៊ុយក្រែនបានប្រកាសអំពីការឃុំខ្លួនលោក Nelli Shtepa  អតីតអភិបាល

ក្រុង Slavyansk ដោយជាប់សង្ស័យការប្រព្រឹត្តល្មើសទៅលើមាត្រាទី ១០ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌនៃប្រទេសអ៊ុយក្រែន (ការរំលោភបំពានអធិបតេយ្យភាពទឹកដី និង ការភាពមិនអាចបំពារបំពានបាននៃប្រទេសអ៊ុយក្រែន)។ ក្រសួងមហាផ្ទៃមិនបានចោទប្រកាន់ថា លោក Nelli Shtepa បានផ្ដល់ការជួយដល់ «កងប្រដាប់អាវុធ» និង «ក្រុមភេរវករ» នៅក្នុងតំបន់ Slavyansk ។

**ថ្ងៃទី ១៥ខែកក្កដា** លោក Alexander Samsonov ដែលជាអភិបាលខេត្តស្តីទី Slavyansk ត្រូវបានចាប់ខ្លួនក្រោមបទចោទប្រកាន់«នៃអំពើបះបោរបំបែករដ្ឋ និង រៀបចំកងទ័ពដោយខុសច្បាប់»។

**ថ្ងៃទី ១៦ ខែកក្កដា** លោក D. Yarosh មេដឹកនាំ«ស្លាបស្ដាំ» គណបក្សរ៉ាឌីកាល់ជាតិបានប្រកាសអំពីការបង្កើតទាហានស្ម័គ្រប្រយុទ្ធអ៊ុយក្រែនប្រឆាំងនឹង«ក្រុមបំបែករដ្ឋ» ក្នុងភាពខាងត្បូង-កើតអ៊ុយក្រែន។

**ថ្ងៃទី ២២ ខែកក្កដា** លោក A. Lukyanov អ្នកសម្របសម្រួលចលនាសង្គមនៃសហភាពប្រជាជនអ៊ុយក្រែន និងជាសកម្មជនប្រឆាំងនឹងចលនាហ្វាស៊ីស បានបាត់ខ្លួន។

**ថ្ងៃទី ២២ ខែកក្កដា** នៅក្រុងគៀវ លោក N. Levchenko អនុប្រធានសភាអ៊ុយក្រែនមកពីគណបក្ស «ភូមិភាគ»ត្រូវបានគេវាយតប់ក្នុងពេលកំពុងបោះឆ្នោតស្ដីអំពី«ការចល័តដោយផ្នែក» ហើយបន្ទាប់មកត្រូវបានគេអូសចេញពីកន្លែងជជែកពិភាក្សានៅក្នុងសភា។

**ថ្ងៃទី ២៣ ខែកក្កដា** ក្នុងកំឡុងពេលប្រជុំពេលព្រឹកក្នុងសភាអ៊ុយក្រែនមានការប្រតាយប្រតប់គ្នារវាងសមាជិកសភាមកពីគណបក្ស «សេរីភាព» និង គណបក្ស «កុម្មុយនិស្ត»។ លោក P. Simonenko មេដឹកនាំបក្សកុម្មុយនិស្តត្រូវបានគេវាយតប់ដោយសមាជិកសភាមកពីបក្ស «សេរីភាព» ហើយព្យាយាមទាញលោកចេញពីកន្លែងនិយាយក្នុងសភា ដោយបានចោទប្រកាន់ថាកំពុងផ្សព្វផ្សាយព័ត៌មានមិនពិតអំពីស្ថានភាពដែលកំពុងកើតឡើងនៅភាគខាងត្បូង-កើតនៃប្រទេស។
**ថ្ងៃទី ២៣ ខែកក្កដា** សាកសពដែលមានស្លាកស្នាមរងរបួស លោក V. Kovshun លេខានៃគណបក្សកុម្មុយនិស្តប្រចាំភូមិ Glinka និង អនុក្រុមប្រឹក្សារងភូមិ ប្រចាំនៃសង្កាត់ Kumachiovo, Starobeshevsky ត្រូវបានគេរងឃើញនៅដូញៀតស្ក៏។ សាកសពត្រូវបានគេធ្វើទារុណកម្មរហូតដល់ស្លាប់នៅឯប៉ុស្តិ៍ត្រួតពិនិត្យឆ្មាំជាតិអ៊ុយក្រែនជិតភូមិ Luzhki ។ មុនពេលស្លាប់ លោក V. Kovshun បានទទួលការគម្រាមសម្លាប់ជាច្រើនដងពីក្រុមជាតិនិយមជ្រុលអ៊ុយក្រែន។
**ថ្ងៃទី ២៤ ខែកក្កដា** សមាជិកសភាអ៊ុយក្រែនលោក A. Turchinov បានប្រកាសរំលាយសាខារងនៃគណបក្សកុម្មុយនិស្តអ៊ុយក្រែននៅក្នុងសភាដោយបានហៅនេះព្រឹត្តិការណ៍ដ៏សំខាន់ និង សំដែងនូវក្តីសង្ឃឹមថា នឹងមិនមានបក្សកុម្មុយនិស្តតទៅទៀតនៅក្នុងសភាអ៊ុយក្រែន។
**ថ្ងៃទី ២៩ ខែ កក្កដា** សន្តិសុខជាតិអ៊ុយក្រែនបានឃុំខ្លួន «អភិបាលក្រុង Nikolayev» គឺលោក D. Nikonovដោយជាប់សង្ស័យថា «បង្កគ្រោះថ្នាក់ដល់អធិបតេយ្យភាពអ៊ុយក្រែន»
**ថ្ងៃទី ៣០ ខែកក្កដា** លោក O. Lyashko តំណាងរាស្ត្រនៅក្នុងសភាជាមួយលោក Y. Borisov ប្រធានរដ្ឋបាលនៃក្រុង Stakhanov ក្នុងភូមិភាគ ឡូហានស្ក៏ ដែលត្រូវបានគេចោទប្រកាន់ពីបទបង្កអំពើភេរវកម្ម ហើយត្រូវបានគេនាំទៅជាមួយគាត់ដោយពុំដឹងទិសដៅ។
**ថ្ងៃទី ៥ ខែសីហា** សមាជិកនៃចលនាស្ត្រីនៅខារកូវដែលបានធ្វើបាតុកម្មដោយសន្តិវិធីប្រឆាំងសង្គ្រាមនៅកណ្តាលក្រុងគៀវជិតអគារសេភាត្រូវបានក្រុមក្មេងស្ទាវពីក្រុម «ស្លាបស្តាំ» ដោយការបាញ់កាំជ្រួច និង ដុំថ្មទៅលើបាតុករ។
**ថ្ងៃទី ១៧ ខែសីហា** ជនមិនស្គាល់អត្តសញ្ញាណមួយក្រុមបានចាប់ពង្រត់អភិបាលក្រុងស្តីទីនៃ Severodonetskគឺលោក A. Gavrilenko និង លេខាម្នាក់ S. Kunitsa នៃក្រុមប្រឹក្សាទីក្រុងដែលគ្រប់គ្រងដោយកម្លាំងសន្តិសុខជាតិអ៊ុយក្រែន។ ក្រុមអ្នកចាប់ពង្រត់ពាក់ឯកសណ្ឋានជាយោធា និង បិទមុខ។
**ថ្ងៃទី ២៦ សីហា** មេដឹកនាំបក្សកុម្មុយនិស្ត លោក P. Simonenko បាននិយាយនៅក្នុងសន្និសិទកាសែតនៅ « Golos» ទីភ្នាក់ងារសារព័ត៌មានថា កងសន្តិសុខជាតិអ៊ុយក្រែនបានចាប់ខ្លួនសមាជិកបក្សរបស់ខ្លួន ហើយបានប្រើទារុណកម្មទៅលើពួកគេ។ លោក  P. Simonenko អះអាងថា បក្សកុម្មុយនិស្តនឹងផ្ញើឯកសារជាផ្លូវការទៅកាន់បេសកម្ម OSCE ក្នុងករណីធ្វើទារុណកម្មទៅលើសមាជិកគណបក្ស។
**ថ្ងៃទី ២៨ ខែសីហា** ពួកជាតិនិយមជ្រុលមិនស្គាល់អត្តសញ្ញាណបានវាយប្រហារទៅលើសកម្មជនបក្សប្រឆាំងនៅ Priluki (ភូមិភាគ Chernigov) និង បានវាយតប់ទៅលើពួកគេ។ សមាជិកនៃក្រុមដែល

ហៅខ្លួនឯងថា «គណៈកម្មាការបោសសំអាត» នៅ Priluki លោក O. Kostiuk បានរាយការណ៍ថា សារព័ត៌មានក្នុងស្រុក រួមទាំងអង្គពង្រឹងច្បាប់សុទ្ធតែគាំទ្រនិងអនុម័តអោយមានការប្រើប្រាស់អំពើហិង្សាប្រឆាំងនឹងអ្នកនយោបាយប្រឆាំង។
**ថ្ងៃទី ៣០ ខែសីហា** សកម្មជនសាធារណៈបានធ្វើកូដកម្មប្រឆាំងនឹងសង្គ្រាមនៅទីលានសេរីភាពក្នុងភាគកណ្ដាលនៃ Kherson ដោយទាមទារអោយ «បញ្ឈប់សង្គ្រាម!» និង «បញ្ឈប់ការតម្លើងពន្ធ» បានទទួលការរងរបួសដោយសារការវាយប្រហារនិងការវាយតប់ដោយសកម្មជន អ៊ីរ៉ូ-ម៉ៃដាន់។
**ថ្ងៃទី ៣១ ខែសីហា** ក្រោមសម្ពាធនៃអ្នកគាំទ្រ « EuroMaidan» សាលាឧទ្ធរនៅភូមិភាគ Kherson បានដោះលែង V. Goncharevskiy ពីការឃុំខ្លួន។ លោកត្រូវបានគេសង្ស័យថាបានសម្លាប់មនុស្សដោយការរុញទម្លាក់ពីបង្អួចនៃសភាពាណិជ្ជកម្មក្នុងតំបន់អូដេសាកាលពីថ្ងៃទី ២ ឧសភា។ តុលាការបានសម្រេចដោះលែងជនសង្ស័យបើទោះជាការពិតមាននៅក្នុងវីដេអូដែលអាចបញ្ជាក់ថាលោកពិតជាមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងបទឧក្រិដ្ឋ។
**យប់ថ្ងៃទី ៣១ ខែសីហា ដល់ថ្ងៃទី ១ ខែ កញ្ញា** សកម្មជនមួយចំនួនពីបក្សកុម្មុយនិស្តក្នុងក្រុង Dneprodzerzhinskត្រូវបានគេចាប់ឃុំខ្លួនបន្ទាប់ពីលំនៅដ្ឋានរបស់ពួកគេត្រូវបានកម្លាំងនគរបាលចុះឆែកឆេរ។ ជាពិសេស លំនៅដ្ឋានរបស់លោក S. Tkachenko អនុប្រធានក្រុមប្រឹក្សា Dneprodzerzhinskពីបក្សកុម្មុយនិស្តនិងជាឪពុករបស់កូនបីនាក់ក្នុងបន្ទុក ត្រូវបានឆែកឆេរដោយមនុស្សមួយក្រុមមិនមានអត្តសញ្ញាណច្បាស់លាស់៕ បន្ទាប់មក លោក S. Tkachenko ត្រូវបានគេនាំយកទៅឃុំខ្លួននៅរដ្ឋបាលកងសន្តិសុខជាតិអ៊ុយក្រែន។
**ថ្ងៃទី ៧ ខែ កញ្ញា** ជនមិនស្គាល់អត្តសញ្ញាណមួយក្រុមបានដុតឡានលោក O. Boyko ( សមាជិកបក្សភូមិភាគ ) អនុប្រធានក្រុមប្រឹក្សាក្រុង Berdyansk ( ភូមិភាគ Zaporozhe )
**ថ្ងៃទី ១១ ខែ កញ្ញា** នៅក្នុងសម័យប្រជុំក្រុមប្រឹក្សាភូមិភាគ Rovensky  អ្នកតំណាងនៃចលនា "Chestno v Drogobyche" បានអំពាវនាវអោយលោក A. Radzievskiy ( គណបក្សភូមិភាគ ) អភិបាលក្រុង Drogobychក្នុងភូមិភាគ Lvov លាលែងចេញពីដំណែងដោយហេតុផលនយោបាយ។ សកម្មជនអ្នកជាតិនិយមបានចោទប្រកាន់អភិបាលក្រុងថា ជានិមិត្តរូបនៃ «ប្រព័ន្ធអាណាចក្រម៉ូស្គូ»។
**ថ្ងៃទី ១១ ខែ កញ្ញា** នៅក្នុងសម័ប្រជុំក្រុមប្រឹក្សាភូមិភាគ Rivne អ្នកតំណាងនៃអង្គការរ៉ាឌីកាល់ស្លាបឆ្វេង UNA-UNSO លោក A. Pantiukhov បានអំពាវនាវអ្នកតំណាងគណបក្សភូមិភាគលាលែងពីតំណែងក្នុងរយៈពេល ១៥ ថ្ងៃ។  លោក A. Pantiukhov បានហៅគាត់ថា «ឆ្កែ» ហើយគំរាម«បោះចោលពួកគេនៅក្នុងកន្លែងចាក់សំរាម» ប្រសិនបើអតីត«អ្នកភូមិភាគ»មិនស្ដាប់ពាក្យសំដីគាត់។
**ថ្ងៃទី ១៤ ខែកញ្ញា**នៅទីលានសេរីភាពនៅខារកូវគេឃើញមានការប៉ះទង្គិចគ្នារវាងអ្នកគាំទ្រអ្នកគាំទ្រអោយប្រទេសអ៊ុយក្រែនក្លាយទៅជាសហព័ន្ធ និង ក្រុមរ៉ាឌីកាល់ជាតិនិយម។
**ថ្ងៃទី ១៨ ខែកញ្ញា** មានប្រជាជនជាច្រើនរយនាក់បានចុះដើរតាមផ្លូវនៅខារកូវដើម្បីចូលរួមប្រឆាំងនិងប្រាក់ខែទាប នៅក្នុងប្រទេសអ៊ុយក្រែន។ ពួកគេធ្វើកូដកម្មនៅក្នុងលានប្រជាធិបតេយ្យ ដើម្បីអំពាវនាវ

អោយមានសុខសន្តិភាពនៅ ភូមិភាគ ដូនបាស្ស ហើយប្រឆាំងទៅនឹងការវាយទម្លាក់រូបសំណាក់ឰសូវៀតអ្នកប្រឆាំងបានកាន់បដាដោយសរសេរថា «បញ្ឈប់ហ្វាស៊ីស!» «អ៊ុយក្រែនគ្មានហ្វាស៊ីស!» «សូមអោយពួកនាយទុនរស់នៅដោយប្រាក់ខែតិច!» និង «កុំប៉ះពាល់រូបសំណាក់សូវៀត» ។ អ្នកចូលរួមនៅក្នុងកូដកម្មត្រូវបានគេវាយប្រហារដោយមនុស្សពាក់មុខមួយក្រុម។ ប៉ូលីសដែលនៅថែរក្សានៅទីនោះ មិនបានចាត់វិធានការណ៍អោយបានត្រឹមត្រូវនោះទេ។

**ថ្ងៃទី ១៥ ខែកញ្ញា** មានក្មេងស្ទាវជាងម្ភៃនាក់ដែលប្រកាសថាពួកគេមកពីអង្គការ UNA-UNSO បានចូលទៅក្នុងការិយាល័យបក្សកុម្មុយនិស្ត ភូមិភាគ Volyn ដែលកំពុងរៀបចំការបោះឆ្នោតមុនអាណត្តិកំណត់។ ពួកគេបានប្រើប្រាស់កាំភ្លើងម៉ាក Makarov ក្លង់គំរាម និង បានវាយលេខាទីមួយគណបក្សលោក P. Buschik ហើយទាត់ជាក់យ៉ាងសាហាវព្រៃផ្សៃខណៈលោកដួលលើកំរាលឥដ្ឋ។ ក្មេងស្ទាវទាំងនោះក៏បានវាយមុខ លោក A. Kononovich មេដឹកនាំគណបក្ស ដែលធ្វើអោយបាក់ខ្ទង់ច្រមុះ ខណៈដែលលោកព្យាយាមជួយសមាជិករបស់ខ្លួន។ នៅពេលដែលប៉ូលីសមកដល់ពួកគេមិនបានបញ្ឈប់ក្រុមក្មេងស្ទាវទាំងនោះទេ។ ប៉ូលីសបានចាប់ផ្តើមធ្វើដូចជាពួកគេកំពុងស៊ើបអង្កេតប ខណៈដែលក្រុមជនល្មើសបានចាកចេញទៅដោយសុវត្ថិភាព។

**ថ្ងៃទី ១៦ ខែ កញ្ញា** សកម្មជន «អូតូ ម៉ៃដាន់» មួយក្រុមបានធ្វើកូដកម្មនៅជិតសភាអ៊ុយក្រែនដោយបានទាមទារអោយមានការអនុម័តច្បាប់ «ស្តីអំពីការបោសសម្អាតអំណាច» និង បានចាប់សមាជិកសភា លោកV. Zhuravskiy (មកពីគណបក្សភូមិភាគ)។ លោកត្រូវបានគេបោះនៅក្នុងធុងសម្រាមដែលមានដាក់កង់ឡានទៅពីលើ និង បានចាក់វត្ថុរាវ ដែលទំនងអាចឆេះបាន ព្រមទាំងគំរាមដុតលោកថែមទៀត។

**ថ្ងៃទី ១៧ ខែ កញ្ញា** យោងតាមការចេញផ្សាយ «កញ្ចក់សប្តាហ៍» គណៈកម្មាធិការរៀបចំការបោះឆ្នោតបានបដិសេធចុះបញ្ជីជាបេក្ខជនសមាជិកសភា លោក A. Onischenko អតីតសមាជិកបក្ស «ភូមិភាគ»។

**ថ្ងៃទី ១៧ ខែកញ្ញា** សមាជិកនៃកងកម្លាំង«ការពារខ្លួន» នៃតំបន់ Kherson បានគប់ស៊ុត និង ចាក់ *viridis nitentis* (សារធាតុរាវពណ៌ខៀវសំរាប់លាងសម្អាតរបួស) ទៅលើអ្នកចូលរួមក្នុងការប្រជុំជាមួយលោក S. Tigipko មេដឹកនាំ បក្ស «អ៊ុយក្រែនខ្លាំង»។ ក្រុមកងកម្លាំង «ការពារខ្លួន» ដែលពាក់ខោអាវប៉ារ៉ា និង ខោអាវកីឡាផងនោះ បានព្យាយាមចូលទៅកន្លែងដែលលោក S. Tigipko កំពុងជួបប្រជុំជាមួយអ្នកគាំទ្រ។ ទោះជាយ៉ាងណា បន្ទាប់ពីសន្តិសុខដែលធ្វើការនៅអគារការិយាល័យកណ្តាលចាក់សោរពីខាងក្នុង ក្រុមនេះនៅតែរងចាំដើម្បីធ្វើសកម្មភាពគប់ស៊ុតទៅលើអ្នកចូលរួមដែលចាកចេញពីការប្រជុំ។ ក្មេងស្ទាវទាំងនោះបានស្រែកដោយចោទប្រកាន់ថា "ពួកបំបែកខ្លួននិងជនក្បត់ផលប្រយោជន៍ប្រទេសអ៊ុយក្រែន»។ ប៉ូលីសមិនបានធ្វើអន្តរាគមន៍នៅក្នុងអ្វីដែលកំពុងកើតឡើងនេះនោះទេ។

**ថ្ងៃទី១៨ខែកញ្ញា** នៅទីលានសេរីភាពខារកូវ មានការប៉ះទង្គិចគ្នារវាងអ្នកគាំទ្រការ«បង្កើតសហព័ន្ធអ៊ុយក្រែន»និង ក្រុមជាតិនិយមជ្រុលអ៊ុយក្រែន។

**ថ្ងៃទី ១៨ ខែកញ្ញា** ការិយាល័យព័ត៌មានរបស់ព្រះរាជអាជ្ញារនៅភូមិភាគ Chernigov បានផ្តល់ព័ត៌មានថា តុលាការរដ្ឋបាលភូមិភាគ Chernigov បានសម្រេចបញ្ឈប់រាល់សកម្មភាពនយោបាយគណបក្ស«ប្លុករុស្ស៊ី»ប្រចាំភូមិភាគ Chernigov។
**ថ្ងៃទី ១៨ ខែកញ្ញា** ពួកជ្រុលនិយម «ស្លាបស្តាំ»បានសម្រុកចូលក្នុងការិយាល័យលោក V. Fedak ប្រធាននាយកដ្ឋានបុគ្គលិកនៅ Ternopol ដោយបានទាមទារអោយលោកលាលែងពីតំណែង។ បន្ទាប់មក លោកV. Fedak ត្រូវបានគេសែងយកទៅទម្លាក់ក្នុងធុងសម្រាម ដោយក្រុមជ្រុលនិយមទាំងនោះបានហៅលោកថាជា«មន្ត្រីពុករលួយ» ជាអ្នកប្រឆាំងនឹងក្រុមម៉ៃដាន់ ហើយជាអ្នកដែលទទួលបានមុខតំណែងក្នុងពេលកាន់អំណាចរបស់លោកប្រធានាធិបតី V. Yanukovich។
**ថ្ងៃទី ២១ ខែកញ្ញា** អ្នកជាតិនិយមបានវាយប្រហារមកលើក្រុមអ្នកគាំទ្រប្រឆាំងម៉ៃដាន់នៅខារកូវ។ សាក្សីបាននិយាយថា ការប៉ះទង្គិចគ្នាកើតឡើងផ្តើមចេញពីការបង្ករឿងនៃអ្នកគាំទ្របាល់ទាត់ និង ក្រុមសកម្មជន«ស្លាបស្តាំ» ជាមួយនឹងអង្គការ « Gromad′ska Varta Kharkov »។ បន្ទាប់ពីហេតុការណ៍ប៉ះទង្គិចគ្នានេះក្រុមអ្នកជាតិនិយមបានចោល *viridis nitentis* ( សារធាតុរាវសំរាប់លាងសំអាតរបួស ) និង ចោលដុំថ្មទៅលើក្រុមអ្នកគាំទ្រប្រឆាំងម៉ៃដាន់។
**ថ្ងៃទី ២៣ ខែ កញ្ញា** កូដកម្មប្រឆាំងសង្គ្រាមមួយបានកើតឡើងនៅ Kherson។ អង្គការ "Molod″! Gromada!Vlada!″ ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំកូដកម្មនេះ។ ទោះបីជាយ៉ាងណា អាជ្ញាធររដ្ឋ និង អ្នកគាំទ្ររបស់ពួកគេ -សកម្មជនជាតិនិយម-បានភ្ជាប់កូដកម្មនេះទៅ «ក្រុមបំបែករដ្ឋ»។ ពួកអ្នកជាតិនិយមបានស្រែកជាមួយនឹងពាក្យស្លោកថា «ការបំបែករដ្ឋមិនអាចបានសម្រេចឡើយ» ជាដើម។ ប៉ូលីសបានចាប់ឃុំខ្លួនអ្នករៀបចំកូដកម្មនេះបន្ទាប់ពីពួកគេមកដល់ទីលានសេរីភាព។
**ថ្ងៃទី ២៣ ខែកញ្ញា** សកម្មជនមកពីអង្គការជាតិនិយមបានអំពាវនាវអោយលោក I. Rybakov ដែលជាអ្នកនយោបាយល្បីល្បាញ និង បច្ចុប្បន្នជាអនុប្រធានសភាអ៊ុយក្រែន ( គណបក្ស«ការកំណែទំរង់ដើម្បីអនាគត» មិនមានចូលជាមួយបក្សដទៃទៀត ) អោយដកបេក្ខជនរបស់ខ្លួនសម្រាប់ការបោះឆ្នោតនាពេលខាងមុខនេះ។ អ្នកជាតិនិយមបាននាំយក រូបតុក្កតាលោក I. Rybakov មកកន្លែងធ្វើកូដកម្ម ដោយព្យាយាមដុតវាចោល ប៉ុន្តែដោយសារអាកាសធាតុមិនអំណោយផល គំរោងរបស់ពួកគេត្រូវបរាជ័យ។ ពាក្យស្លោកប្រឆាំងនឹងរុស្ស៊ីក៏ត្រូវបានគេប្រើប្រាស់ផងដែរ។
**ថ្ងៃទី ២៤ ខែកញ្ញា** កងកម្លាំង «ស្លាបស្តាំ» បានប្រកាសប្រាប់ អ្នកដែលឈរឈ្មោះនៅក្នុងការបោះឆ្នោតសភាថា ពួកគេនឹងមិនអោយ «ជនក្បត់»ចូលទៅអង្គុយក្នុងសភាអ៊ុយក្រែនជាដាច់ខាត។ បើមិនដូច្នោះទេនោះ ពួកជាតិនិយមរ៉ាឌីកាល់ទាំងនោះសន្យាវិលត្រលប់ពីតំបន់ប្រតិបត្តិការសឹកប្រឆាំងភេរវជន ហើយ អ្នកទាំងនោះនឹងទទួលទណ្ឌកម្មយ៉ាងសមរម្យបំផុត។
**ថ្ងៃទី ២៥** អភិបាលរងទី១ Kherson លោក I. Pastukh បាននិយាយនៅក្នុងសន្និសិទ្ធសង្ខេបថា ក្រុមប្រឹក្សាក្រុងKherson ក្នុងពេលថ្មីៗនេះបានទទួលកំណត់ត្រាពីក្រុមអ្នកផ្តួចផ្តើម អង្គការក្រៅរដ្ឋាភិបាល សមាគមដើម្បីកូដកម្មដោយសន្តិវិធី «យើងទាំងអស់គ្នាដើម្បីសន្តិភាព» «ប្រជាជននៃក្រុង Kherson ដើម្បីសន្តិភាព» «ស្ត្រី Khersonដើម្បីសន្តិភាព» ។ លោកបានហៅស្ថានភាពបច្ចុប្បន្នថា «ជាការបង្ក

រឿង» ហេតុដូចនេះហើយអាជ្ញាធរមូលដ្ឋានបានទាក់ទងទៅកងសន្តិសុខជាតិអ៊ុយក្រែន និង ស្នើសុំទៅតុលាការអោយហាមឃាត់កូដកម្មដោយសម្អាងទៅលើលិខិតដែលផ្ញើពីរដ្ឋបាលក្រុងនៃក្រសួងមហាផ្ទៃក្នុងភូមិភាគKherson ចំពោះការមិនមានសមត្ថភាពធានាអោយមានការធ្វើកូដកម្មបែបនេះធ្វើឡើងក្នុងក្របខណ្ឌច្បាប់។

**ថ្ងៃទី ២៥ ខែ កញ្ញា** ក្រុមសកម្មជនអនាមិកបានចាប់លោក V. Pilipishin អនុប្រធានសភាមកពីគណបក្សប្រជាជនទៅក្នុងធុងសម្រាម និង បានចាក់ថ្នាំពណ៌ក្រហមទៅលើលោកទៀតផង។ លោក V. Pilipishinចង់ចុះឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតក្នុងពេលខាងមុខ ប៉ុន្តែសកម្មជនទាំងនេះបានបំផ្លាញគម្រោងរបស់លោក។ លោកត្រូវបានគេវាយតប់ និង ធាក់ដោយក្រុមមនុស្សបិទមុខជាង ៣០ នាក់ដែលរង់ចាំលោកនៅទីស្នាក់ការកណ្តាលគណកម្មាធិការរៀបចំការបោះឆ្នោត។

**ថ្ងៃទី ២៥ ខែកញ្ញា** កងកម្លាំង «ការពារខ្លួន»ម៉ៃដាន់បានវាយប្រហារទៅលើសមាជិកក្រុមប្រឹក្សាភូមិភាគនៅCherkassy។ ពួកក្រុមជ្រុលនិយមបានចាប់សមាជិកក្រុមប្រឹក្សាលោក A. Kharlamov និង V. Vovchenkoគ្រវែងទៅក្នុងធុងសម្រាម។

**ថ្ងៃទី២៦ ខែកញ្ញា** មេដឹកនាំគណបក្សកុម្មុយនិស្ត លោក Piotr Simonenko បានអះអាងបញ្ជាក់នៅក្នុងកិច្ចប្រជុំជាមួយអ្នកតំណាង OSCE នៅក្នុងសភាអ៊ុយក្រែនថា សមាជិកគណបក្សរបស់លោកត្រូវបានគេធ្វើអោយភ័យខ្លាច ក្នុងគោលបំណងការពារមិនអោយឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោតសភាខាងមុខ។

**ថ្ងៃទី ២៦ ខែកញ្ញា** ក្រុមកងកម្លាំង «ស្លាបស្តាំ» បានរំខានការជួបប្រជុំក្រុមប្រឹក្សាក្រុងនៅ Melitopol ។ កងកម្លាំង «ស្លាបស្តាំ»បានអំពាវនាវអោយលេខាក្រុមប្រឹក្សាក្រុង លោក S. Minko បញ្ចូលការលាលែងពីតំណែងនៅក្នុងរបៀបវារៈ ឬ ចាកចេញពីតំណែងដោយស្ម័គ្រចិត្ត។

**ថ្ងៃទី ២៦ ខែកញ្ញា** ប្រហែលម៉ោងពីរល្ងាច សកម្មជនពី«ស្លាបស្តាំ» និង ក្រុមរ៉ាឌីកាល់ផ្សេងៗទៀតបានវាយប្រហារទៅលើក្រុមអ្នកធ្វើយុទ្ធនាការរបស់បក្សកុម្មុយនិស្តអ៊ុយក្រែននៅជិតស្ថានីយ៍ខាងត្បូងគៀវ។ ក្រុមអ្នកជាតិនិយមបានបំផ្លិចបំផ្លាញតង់សម្រាប់សំរាក និង បានគ្រវែងចោលខិតប័ណ្ណឃោសនាបោះឆ្នោត។

**ថ្ងៃទី ២៧ ខែ កញ្ញា** សកម្មជនជាតិនិយម រួមទាំង«កងអាសាស្ម័គ្រ Aidar» បានរំខានដល់ការជួបប្រជុំរបស់លោក V. Zhuravsky អនុប្រធានសភាអ៊ុយក្រែននិងអ្នកគាំទ្រដោយការចោលស៊ុត នៅក្នុងសង្កាត់ Volodarsk-Volyn ក្នុងភូមិភាគ Zhitomir។

**ថ្ងៃទី ២៧ ខែ កញ្ញា** ប៉ូលីសអ៊ុយក្រែនបានបំបែកកូដកម្មនៅខារកូវ។

**ថ្ងៃទី ២៩-៣០(យប់)** អ្នកជាតិនិយមជ្រុលអ៊ុយក្រែនបានវាយតប់យ៉ាងសាហាវឃោរឃៅទៅលើបាតុករនៅទីលានសេរីភាពក្នុងភូមិភាគ ខារកូវ (ជិតរូបសំណាកឡេនីនដែលត្រូវបានគេផ្តួល)។ មនុស្ស ៣នាក់បានរងរបួសហើយត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ។

**ថ្ងៃទី ៣០ ខែកញ្ញា** ជនអនាមិកម្នាក់បានវាយប្រហារទៅលើតង់យុទ្ធនាការបោះឆ្នោតរបស់គណបក្សកុម្មុយនិស្តអ៊ុយក្រែន នៅ Melitopol (ភូមិភាគ Zaporozhe)។

**ថ្ងៃទី ៣០ កញ្ញា** អ្នកជាតិនិយមជ្រុលបានវាយតំណាងរាស្ត្រប្រចាំ Odessa គឺលោក N. Shufrich។ សាក្សីដែលឃើញហេតុការណ៍បាននិយាយថា N. Shufrich និង សហការីដែលមកពីគណបក្ស «ប្លុកប្រឆាំង»គឺលោក N. Skorik បានដើរចេញពីរថយន្តនៅជិតរដ្ឋបាលភូមិភាគអូដេសា ក៏ត្រូវបានក្រុមអ្នកគាំទ្រ «  EuroMaidan» វាយតប់យ៉ាងឃោរឃៅ។ ជាលទ្ធផល លោក N. Shufrich ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យក្នុងសភាពធ្ងន់ធ្ងរ។

**ថ្ងៃទី ១ ខែតុលា** លោក A. Avakov រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានអំពាវនាវអោយក្រុមរ៉ាឌីកាល់អ៊ុយក្រែនបញ្ឈប់ការធ្វើខុសឆ្គងប្រឆាំងនឹងមន្ត្រី និង អ្នកនយោបាយ។ លោកបានសរសេរនៅក្នុងប្រព័ន្ធហ្វេសប៊ុក៖ «ប្រសិនបើយើងមាន N. Shufrich បែកមុខមាត់ និង Pilipishin ស្លាប់ជាច្រើននាក់បែបនេះ អឺរ៉ុបនឹងបែរខ្នងដាក់បដិវត្តន៏ដ៏ជោគជ័យរបស់យើង ហើយរួមទាំងអាមេរិកផងដែរ...»

**ថ្ងៃទី ១២ តុលា** នៅទីក្រុង នីកូលៃយ៉េវ មានការវាយប្រហារពីរកន្លែងទៅលើតង់យុទ្ធនាការរបស់គណបក្ស «ប្លុកប្រឆាំង»។ ការវាយប្រហារនេះកើតឡើងនៅចំណុចប្រសព្វរវាងមហាវិថី «លេនីន» និង ផ្លូវ« ក្រុមខែតុលា»និង ចំណុចប្រសព្វរវាង មហាវិថីលេនីន និង ផ្លូវ « Riumin»។ នៅក្នុងហេតុការណ៏ទាំងពីរនេះ សម្ភារៈផ្សេងៗសម្រាប់ធ្វើការឃោសនាត្រូវបានគេប្រមូលយកអស់។

**ថ្ងៃទី ១៥ ខែតុលា** មេធាវីអតីតអភិបាលក្រុង N. Shtepa បាននិយាយថា កូនក្តីរបស់លោកត្រូវបានគេវាយ ធ្វើបាបយ៉ាងឃោរឃៅនៅក្នុងការិយាល័យព្រះរាជអាជ្ញាក្នុងតំបន់ខារកូវ។

**ថ្ងៃទី ១៦ ខែតុលា** ពេលព្រឹកនៅទីលាន Tamozhniaក្នុងភូមិភាគអូដេសា ជនអនាមិកពីរនាក់បានវាយប្រហារទៅលើអ្នកឃោសនាគណបក្ស«អ៊ុយក្រែនខ្លាំង»។ ពួកគេបានវាយតប់ទៅលើអ្នកគាំទ្រ និង បំផ្លាញអ្វីៗដែលក្រុមអ្នកគាំទ្របានរៀបចំ។ S. Fabrikant អនុប្រធានគណបក្សបានអោយដឹងអំពីការរីកសាយភាយនៃទំងន់នយោបាយមកលើគណបក្ស«អ៊ុយក្រែនខ្លាំង»។ លោកស្រីបាននិយាយថា សប្តាហ៏មុនមានការគួរអោយកត់សំគាល់អំពីការកើនឡើងនៃការវាយប្រហារមកលើសកម្មជនរបស់គណបក្ស មានករណីខ្លះគឺចាប់ពង្រត់ ការគំរាមកំហែង និង ការសំឡុត។

**ថ្ងៃទី២០ ខែតុលា** «ព័ត៌មានជាតិអ៊ុយក្រែន»បានអោយដឹងថា ច្បាប់ស្តីអំពី «ការបោសសំអាតអំណាច» ត្រូវបានគេអនុវត្តជាមួយស្ត្រីមានទំងន់ និង ស្ត្រីដែលឈប់សម្រាកសម្រាលកូន។

**ថ្ងៃទី ២៦ ខែតុលា** ក្រសួងមហាផ្ទៃអ៊ុយក្រែនបានអោយដឹងថា ប៉ូលីសភូមិភាគគៀវបានរាយកាណ៏មានការកើតឡើងនៃការរំលោភលើច្បាប់បោះឆ្នោត ២៥ដងកំឡុងការបោះឆ្នោតថ្មីៗនេះ។ ២០ករណីបានកើតឡើងនៅភូមិភាគ Dnepropetrovsk។ យោងតាមមន្ត្រីពង្រឹងច្បាប់អ៊ុយក្រែន ការរំលោភខ្លាំងជាងគេគឺរួមមាន ការយុទ្ធនាការឃោសនា សន្លឹកឆ្នោតត្រូវបានគេយកដោយខុសច្បាប់ វត្តមានរបស់ជនសង្ស័យនៅតាមទីកន្លែងបោះឆ្នោត។ យោងតាមក្រសួងមហាផ្ទៃ មានសន្លឹកឆ្នោតមិនបានការចំនួន ២០០០០ត្រូវបានគេរកឃើញនៅក្នុងអគារគណកម្មាធិការសង្កាត់នៃភូមិភាគ Dnepropetrovsk។ ករណីនៃការខូចសន្លឹកឆ្នោតត្រូវបានគេរាយការណ៏ មានកើតឡើងនៅសង្កាត់ពីរ នៃភូមិភាគ Dnepropetrovsk។  ប៉ូលីសបានអោយដឹងផងដែរ អំពីការរីកសាយភាយនៃកូនសៀវភៅយុទ្ធនាការបោះឆ្នោត និង សារតាមទូរស័ព្ទដៃ។

**ថ្ងៃទី ២៦ ខែតុលា** ការិយាល័យសារព័ត៌មាននៃក្រសួងមហាផ្ទៃអ៊ុយក្រែនក្នុងភូមិភាគ Kirovograd បានអោយដឹងថា មានពីរករណីព្រហ្មទណ្ឌកើតឡើងទាក់ទងនឹងការចោទប្រកាន់ថាបានរំលោភលើច្បាប់បោះឆ្នោត។
**ថ្ងៃទី ២៦ ខែតុលា** យោងតាមទីភ្នាក់ងារព័ត៌មាន Interfax អ្នកសារព័ត៌មាន និងអ្នកអង្កេតការណ៍បានរាយការណ៍អំពីការរំលោភលើច្បាប់បោះឆ្នោតមួយចំនួននៅតាមកន្លែងបោះឆ្នោតក្នុងភូមិភាគអូដេសា។ ជាពិសេស តាមរបាយការណ៍របស់គណៈកម្មាធិការអ្នកបោះឆ្នោតអ៊ុយក្រែនក្នុងភូមិភាគអូដេសា បានរាយការណ៍អំពីសន្លឹកឆ្នោតលើសមានចំនួនច្រើននៅតាមកន្លែងបោះឆ្នោតទាំង ៨ នៅអូដេសា។
ថ្ងៃទី ៣០ ខែតុលា ប្រធានការិយាល័យសារព័ត៌មានរដ្ឋបានអោយដឹងថា ប្រធានាធិបតីអ៊ុយក្រែន P. Poroshenko បានបណ្តេញអភិបាលសង្កាត់ចំនួន ៣០ ក្រោមច្បាប់ «ការបោសសំអាតអំណាច»។ ៨ អភិបាលសង្កាត់ គឺនៅជូញៀតស្គ័ ៧ នៅ Dnepropetrovsk ៧ នៅ Zaporozhe ៤នៅ Odessa ២ នៅ Sumsk និង ២ ទៀតនៅ Rivne និង Kharkov។

## ការរំលោភសិទ្ធិជនភាគតិច ការរើសអើង ការស្អប់បរទេស និង ជាតិនិយមជ្រុល

## កាតិកាអន្តរជាតិស្តីអំពីសិទ្ធិស៊ីវិល និង នយោបាយ

## (ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦)

### មាត្រាទី ២០

១. ការឃោសនាណាមួយអំពីសង្គ្រាមត្រូវហាមឃាត់ដោយច្បាប់។
២. ការគាំទ្រអោយមានការស្អប់ខ្ពើមជាតិ សាសន៍ ឬ សាសនាដែលបង្កើតអោយមានការរើសអើង ការខ្វះការសន្តោសប្រណី ឬ អំពើហិង្សាត្រូវហាមឃាត់ដោយច្បាប់។

### មាត្រាទី ២៦

មនុស្សគ្រប់រូបមានភាពស្មើគ្នានៅចំពោះមុខច្បាប់ និង រួចផុតពីការរើសអើងណាមួយ ព្រមទាំងទទួលបានការការពារស្មើគ្នានៅចំពោះមុខច្បាប់។ ក្នុងន័យនេះ ច្បាប់ត្រូវហាមឃាត់មិនអោយមានការរើសអើង និងការធានាការពារមនុស្សគ្រប់រូបស្មើគ្នា និង ប្រសិទ្ធភាពប្រឆាំងនឹងការរើសអើងគ្រប់បែបយ៉ាងរួមមាន ជាតិសាសន៍ ព័ណ៌សម្បុរ ភេទ ភាសា សាសនា និន្នាការនយោបាយ ប្រភពជាតិ និង ប្រភពដើមសង្គម ទ្រព្យសម្បត្តិ កំណើត និង ឋានៈ។

### មាត្រាទី ២៧

នៅក្នុងបណ្តារដ្ឋដែលមានជាតិពន្ធុ សាសនា ឬ ភាសាភាគតិច បុគ្គលដែលស្ថិតក្នុងក្រុមជនភាគតិចមិនត្រូវបានគេបដិសេធសិទ្ធក្នុងសហគមន៍ ជាមួយសមាជិកក្រុម សប្បាយរីករាយជាមួយវប្បធម៌របស់ពួកគេទទួលស្គាល់សាសនា និង ការអនុវត្តសាសនា ឬ ការប្រើប្រាស់ភាសារបស់ខ្លួន។

**កាតិកាសញ្ញាអន្តរជាតិស្តីអំពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងជាតិសាសន៍**
**(ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៦៥)**
**មាត្រាទី ៤**
បណ្តារដ្ឋភាគីថ្កោលទោសរាល់ការឃោសនាទាំងអស់ និង អង្គការទាំងអស់ដែលឈរលើគោលគំនិត ឬ ទ្រឹស្តីនៃជាតិសាសន៍ខ្ពង់ខ្ពស់ជាងជាតិសាន៍មួយទៀត ឬ ព័ណ៌សម្បុរ ឬ ជនជាតិ ដែលការឃោសនានេះធ្វើឡើងក្នុងគោលបំណងបង្កើតភាពស្អប់ខ្ពើមជាតិសាសន៍ និង ការរើសអើងគ្រប់ទម្រង់ និងចាត់វិធានការណ៍ជាបន្ទាន់ព្រមទាំងវិធានការណ៍ជាវិជ្ជមានក្នុងគោលដៅលុបបំបាត់រាល់ការញុះញង់ ឬ ធ្វើសកម្មភាពរើសអើង។ យោងតាមគោលការណ៍ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និង សិទ្ធិដូចដែលមានចែងនៅក្នុងមាត្រាទី៥នៃកាតិកានេះ ៖
ក. ប្រកាសជាបទល្មើសដែលអាចត្រូវផ្តន្ទាដោយច្បាប់រាល់ការឃោសនាដោយផ្អែកលើភាពខ្ពង់ខ្ពស់នៃជាតិសាសន៍ ឬ ការស្អប់ខ្ពើម ការញុះញង់អោយមានការរើសអើងជាតិសាសន៍ រួមទាំងរាល់សកម្មភាពហិង្សា ឬ ការញុះញង់ប្រឆាំងនឹងសាសន៍ឬក្រុមមនុស្សដែលមានព័ណ៌ខុសគ្នា ឬ ជាតិពន្ធុផ្សេង ព្រមទាំងការជួយណាមួយដល់សកម្មជនហ្វាស៊ីស រួមទាំងការចំនាយហិរញ្ញវត្ថុទៀត។
(ខ) ត្រូវប្រកាសខុសនឹងច្បាប់ និងហាមឃាត់អង្គការ និង សកម្មភាពឃោសនាដែលលើកស្ទួយនិងញុះញង់អោយមានការរើសអើងជាតិសាសន៍។ ត្រូវទទួលស្គាល់ការចូលរួមនៅក្នុងការរៀបចំ ឬ សកម្មភាពថាជាបទល្មើសដែលត្រូវផ្តន្ទាទោសដោយច្បាប់។
(គ) មិនត្រូវអនុញ្ញាតអោយអាជ្ញាធរសាធារណៈ ឬ ស្ថាប័នសាធារណៈ ជាតិ ឬ ក្នុងស្រុក លើកស្ទួយ ឬ ញុះញង់អោយមានការរើសអើងជាតិសាសន៍។

**កាតិកាសញ្ញាដើម្បីការការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន (ទីក្រុងរ៉ូម ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៥០)**
**មាត្រាទី ១៤ ការហាមឃាត់ការរើសអើង**
ការប្រើប្រាស់សិទ្ធិនិងសេរីភាពដែលមានចែងនៅក្នុងកាតិកានេះត្រូវបានធានាដោយមិនមានការរើសអើងគ្រប់រូបភាព រួមមាន ការរើសអើងជាតិសាសន៍ ព័ណ៌សម្បុរ ភេទ ភាសា សាសនា និន្នាការនយោបាយ ប្រភពជាតិ និង ប្រភពដើមសង្គម ទ្រព្យសម្បត្តិ កំណើត និង ឋានៈ។

**ថ្ងៃទី ៣ ខែកក្កដា** នៅកន្លែងត្រួតពិនិត្យព្រំដែន Uspenka ក្នុងភូមិភាគដូញៀត៏ សន្តិសុខជាតិអ៊ុយក្រែនបានឃុំខ្លួនឧត្តមសេនីយ៏កូសាក់រុស្ស៊ី ពីភូមិភាគ Kurgan ។ V. Popov ត្រូវបានគេសង្ស័យថាជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពភេរវកម្មនៅលើទឹកដីអ៊ុយក្រែន។
**ថ្ងៃទី៤ ខែកក្កដា** ប្រមុខនៃកងសន្តិសុខអ៊ុយក្រែន V. Nalyvaichenko បានប្រកាសថា ការស៊ើបអង្កេតពាក់ព័ន្ធនឹងការផ្តត់ផ្គង់ហិរញ្ញវត្ថុដល់ក្រុមភេរវករនៅអ៊ុយក្រែនដោយសមាជិកក្រុមប្រឹក្សាសម្រប

សម្រួលអ៊ុយក្រែន គឺលោក A. Selivanov ដែលជាប្រធាននៃអង្គការប្រឆាំងនឹងរដ្ឋាភិបាល «កូសាក់ស្មោះត្រង់»។

**ថ្ងៃទី១០ ខែ កក្កដា** នៅ Lvov ក្រុមប្រឹក្សាក្រុងបានអនុម័តក្រឹត្យមួយដោយតម្រូវអោយដាក់ផលិតផលដែលនាំចូលពីប្រទេសរុស្ស៊ីទាំងអស់ដាច់ដោយឡែកពីផលិតផលអ៊ុយក្រែនក្រោមផ្លាក «ផលិតនៅប្រទេសរុស្ស៊ី»។ បទបញ្ញត្តិថ្មីនេះតម្រូវអោយអនុវត្តនៅតាមផ្សារទំនើប ហាងទំនិញតូចៗ និង ផ្សារ។ ការរំលោភលើក្រឹត្យនេះនឹងត្រូវមានទោស។

**ថ្ងៃទី ១៨ ខែកក្កដា** ក្រុមប្រឹក្សាក្រុង Ternopol បានអនុម័តការសំរេចស្តីអំពីផលិតផលទីផ្សារពិសេសនៃផលិតផលផលិតនៅប្រទេសរុស្ស៊ី។ «ចាប់ពីពេលនេះទៅ ពលរដ្ឋទាំងអស់នឹងអាចឃើញយ៉ាងច្បាស់នូវផលិតផលរុស្ស៊ី ហើយពលរដ្ឋអាចសំដែងនូវ«ជំហរស៊ីវិល»ចំពោះប្រទេសឈ្លានពាន។ នេះជាការស្រង់ពាក្យសំដីរបស់អភិបាលក្រុង S. Nadal បានលើកឡើងទាក់ទងនឹងការសំរេចនេះ។ ប៉ូលីសក្រុងជាអ្នកមានកាតព្វកិច្ចដើម្បីបំពេញអោយបានពេញលេញនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង។

**យប់ថ្ងៃទី ២០/២១ កក្កដា** នៅគៀវ  ការិយាល័យធនាគារស្តង់ដារុស្ស៊ីបានទទួលរងការវាយប្រហារ។ សមាជិកក្រុមគណកម្មាការព័ណ៌ខ្មៅ បានចោលគ្រាប់បែកផ្សែង និង កាំជ្រួចចូលទៅក្នុងអគារ។ ក្រុមអ្នកវាយប្រហារបានស្រែកប្រកាសថា «អ៊ុយក្រែនត្រូវបណ្តេញអ្នកជំនួញរុស្ស៊ីទាំងអស់ពីទឹកដីរបស់ខ្លួន។ ប្រសិនរដ្ឋមិនអាចធ្វើវាបានទេ ពលរដ្ឋម្នាក់ៗត្រូវធ្វើវាដោយខ្លួនឯង»។

**ថ្ងៃទី ២៣ ខែ កក្កដា** លោក E. Grinchenko អាយុ ៥២ឆ្នាំ ជាពលរដ្ឋរស់នៅអូដេសា ត្រូវបានក្រុមមនុស្សដែលពោរពេញដោយកំហឹងវាយតប់ដោយសារគាត់បានបដិសេធមិនដោះចេញ«បូ St. George»ពីឡានរបស់គាត់ ហើយបដិសេធមិនស្រែក «ជយោអ៊ុយក្រែន!»។ ច្រមុះរបស់គាត់បានបាក់ហើយខោអាវត្រូវបានគេចាប់ហែក។

**ថ្ងៃទី ២៥ ខែកក្កដា** អ្នកដឹកនាំគណបក្សរ៉ាឌីកាល់ជាតិនិយមអ៊ុយក្រែន «ស្លាបស្តាំ» D. Yarosh ត្រូវបានប៉ូលីសអាំងទែប៉ូលតាមចាប់ខ្លួនក្រោមបទចោទបានញុះញង់ជាសាធារណៈអោយបង្កអំពើភេរវកម្ម និងសកម្មភាពជ្រុលនិយមតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

**ថ្ងៃទី ៣១ ខែកក្កដា** ប៉ុស្តិ៍ទូរទស្សន៍រុស្ស៊ី «រុស្ស៊ី ២៤» បានផ្សព្វផ្សាយ ពាក្យសំដីរបស់លោក B. Butkevichដែលត្រូវបានគេចាក់ផ្សាយលើកមុននៅទូរទស្សន៍ Hromadske TV។ លោកB. Butkevich ជាអ្នកកាសែតដែលធ្វើការអោយទស្សនាវដ្តី Tyzhden ( សប្តាហ៏អ៊ុយក្រែន ) បានលើកឡើងនូវគំនិតបំបាត់ចោល«អ្នករស់នៅគ្មានប្រយោជន៍»ចំនួន ១.៥ លាននាក់ពីដូញៀតស្គ៍ និង ឡូហានស្គ៍។ តាមយោបល់លោកតំបន់នានាគួរត្រូវបានប្រើប្រាស់ដើម្បីបូមយកធនធានក្រោមដី។ «នៅ Donbass ជាតំបន់ដែលគួរអោយអស់សង្ឃឹម និង ការធ្លាក់ទឹកចិត្ត។ នៅទីនោះមានមនុស្សអត់ប្រយោជន៍រស់នៅយ៉ាងច្រើនកុះករ។ ខ្ញុំកំពុងនិយាយអ្វីដែលខ្ញុំគួរនិយាយ។ នៅភូមិភាគដូញៀតស្គ៍មានប្រជាជនរស់នៅទាំងអស់ប្រហែល ៤លាននាក់។ តាមយោបល់របស់អ្នកកាសែតរូបនេះ អ៊ុយក្រែនមិនត្រូវការ«យល់អំពី Donbass»នោះទេ។ «យើងត្រូវការយល់អំពីផលប្រយោជន៍ជាតិអ៊ុយក្រែន។ ហើយ Donbass គួរត្រូវប្រើដើម្បីទាញយកធនធានធម្មជាតិ។ ទាក់ទងនឹងDonbass ខ្ញុំមិនមានវិធីសាស្រ្ត

ដើម្បីធ្វើអោយវាសម្រេចតាមគោលបំណងខាងលើលឿននោះទេ។ ទោះបីយ៉ាងណាក៏ដោយមានចំណុចមួយសំខាន់បំផុតនោះត្រូវធ្វើជាបន្ទាន់: «សម្លាប់មនុស្សដែលគួរសម្លាប់»។

**ថ្ងៃទី ៣ ខែ សីហា** ក្រុមជាតិនិយមរ៉ាឌីកាល់ រួមមានសកម្មជន «ស្លាបស្តាំ»និង គណបក្ស «សេរីភាព» បានបង្កភាពគ្មានសណ្តាប់ធ្នាប់នៅអូដេសា ក្នុងគោលបំណងរំខានដល់ការប្រគុំតន្ត្រីរបស់អ្នកចម្រៀងអ៊ុយក្រែននាង A. Lorak ដោយសារនាពេលថ្មីៗនាងបានទៅសំដែងនៅគ្រីម៉េ ហើយបានទទួលនូវការផ្តល់ពានរង្វាន់តន្ត្រីរុស្ស៊ី។ មានជនបិទមុខនិងប្រដាប់ដោយអាវុធប្រហែល ២០០នាក់បានសំរុកចូលទៅកន្លែងប្រគុំតន្ត្រី។ ពួកគេបានស្រែកនូវពាក្យស្លោកដដែលៗប្រឆាំងនឹងអ្នកចម្រៀង។

**ថ្ងៃទី ៣ ខែសីហា** យោងតាមទីប្រឹក្សាក្រសួងមហាផ្ទៃអ៊ុយក្រែនលោក A. Gerashchenko ក្រសួងមានគោលបំណងបដិសេធអ្នកសម្តែងរុស្ស៊ីចំនួន ៥០០នាក់ មិនអោយចូលមកក្នុងទឹកដីអ៊ុយក្រែនត្បិតអ្នកទាំងនោះបានគាំទ្រ«ការភ្ជាប់គ្រីម៉េដោយប្រទេសរុស្ស៊ី និង ការផ្តាច់ចេញពីអ៊ុយក្រែន»

**ថ្ងៃទី ៥ ខែសីហា** នៅនីកូឡាយ៉េវ ជនអនាមិកបានបាញ់ថ្នាំលើការិយាល័យពីរនៃធនាគាររុស្ស៊ី Sberbankនិងបានជះថ្នាំក្រហមទៅលើកន្លែងដទៃផ្សេងទៀត។

**ថ្ងៃទី ៧ ខែ សីហា** ការិយាល័យអគ្គព្រះរាជអាជ្ញានៃប្រទេសអ៊ុយក្រែនបានស្នើអោយមានការលុបចោលសេចក្តីសំរេចនៃក្រុមប្រឹក្សាក្រុងខារកូវដែលបានបំពាក់រង្វាន់កិត្តិយសពលរដ្ឋខារកូវដល់លោក A. Shishkin សមាជិកក្រុមប្រឹក្សាសហព័ន្ធ ។

**ថ្ងៃទី ១៤ ខែ សីហា** សមាជិកនៃក្រុមប្រឹក្សាក្រុង Rovno បានសម្រេចអោយ «ម្ចាស់អាជីវកម្មទាំងអស់ក្នុងក្រុង Rovno ចាំបាច់ត្រូវបន្ថែមម៉ាកជាពិសេសទៅលើផលិតផលរុស្ស៊ីដោយដាក់ថា «ផលិតផលពីរុស្ស៊ី»។

**ថ្ងៃទី ១៦ ខែសីហា** អភិបាលក្រុង Novoukrainka (ភូមិភាគ Kirovograd) គឺលោក A. Korennoy បានសំនូមពរក្នុងកិច្ចប្រជុំជាផ្លូវការថា ផលិតផលរុស្ស៊ីនៅក្នុងគ្រប់ហាងទាំងអស់ក្នុងតំបន់ចាំបាច់ដាក់អោយដាច់ដោយឡែកឬត្រូវបិទផ្លាកពិសេស «មនុស្សពណ៌ខៀវតូច» ឬ ទង់ជាតិរុស្ស៊ី។

**ថ្ងៃទី ១៨ ខែសីហា** នៅ Ternopol មានជនអនាមិកបានគូសវាសលើរូបសំណាក Alexander Pushkin និង បានសរសេរប្រាថ្នាចង់អោយប្រធានាធិបតីរុស្ស៊ី វ្លាឌីមៀរ ពូទីន ស្លាប់បាត់បង់ជីវិត។

**ថ្ងៃទី ២២ សីហា** នៅគៀវ ជនអនាមិកមួយក្រុមបានលាបថ្នាំលើរបងស្ថានទូតរុស្ស៊ីនៅអ៊ុយក្រែនដោយដាក់ពណ៌ទៅតាមទង់ជាតិប្រទេសនេះ។

**ថ្ងៃទី ២២ សីហា** នៅគៀវ ពួកក្រុមរ៉ាឌីកាល់ជាតិនិយមបានវាយប្រហារទៅលើស្ថានីយ៍ចាក់ប្រេងដែលមានម៉ាករុស្ស៊ី TNK និង Lukoil ។ ជនល្មើសបានលាបថ្នាំនៅស្ថានីយ៍ប្រេងដោយសរសេរថា «បរាជ័យស្ថានីយ៍ហ្គាសរុស្ស៊ី» ហើយបានចោលគ្រាប់បែកផ្សែងចោលទៅក្នុងស្ថានីយ៍។

**ថ្ងៃទី ២៥ ខែ សីហា** នៅក្នុងអគាររដ្ឋបាលសាសាធារណៈនៃភូមិភាគ Poltava សៀវភៅរបស់ជនជាតិនិយមអ៊ុយក្រែនមួយរូប V. Bobrovich ដែលមានចំណងជើង «របៀបដែលពួក Cossacks ធ្វើសង្គ្រាមនៅ Caucasus៖កំណត់ហេតុមេបញ្ជាការ Ustym» ត្រូវបានដាក់បង្ហាញដោយមានការគាំទ្រពី

សំណាក់អភិបាលក្រុង V. Bugaychuk។ ក្នុងកំឡុងពេលដាក់បង្ហាញសៀវភៅនេះ អ្នកនិពន្ធបាន អំពាវនាវអោយ «ដើបឡើងកាប់សម្លាប់ប្រជាជនរុស្ស៊ី»។

**ថ្ងៃទី ២៧ ខែ សីហា** សារព័ត៌មានអនឡាញ "Exclusively Lvov Life" ដែលមានប្រជាប្រិយនៅក្នុង ក្រុង បានបង្ហោះវីដេអូនៃការជេរប្រទេចដាក់បណ្តាសាប្រឆាំងនឹងពលរដ្ឋរុស្ស៊ី និង មេដឹកនាំ។

**ថ្ងៃទី ២៨ ខែ សីហា** នៅគៀវ អាជ្ញាធរអ៊ុយក្រែនបានឃុំខ្លួនសមាជិកស្ថានទូតរុស្ស៊ីពីររូប រួមមានអង្គរក្ស ផ្ទាល់របស់ឯកអគ្គរដ្ឋទូតផងដែរ បើទោះជាពួកគេបានបង្ហាញលិខិតឆ្លងដែនការទូត។

**ថ្ងៃទី ២៨ ខែ សីហា** នៅខារកូវ កូដកម្មរបស់អ្នកជាតិនិយមអ៊ុយក្រែនបានធ្វើឡើងប្រឆាំងនឹងអ្វីដែល ពួកគេហៅថា «ការឈ្លានពានរុស្ស៊ី» ។ សកម្មជនទាំងនោះមានកាន់បដា និង ទង់ជាតិអ៊ុយក្រែន ប្រមូលផ្តុំគ្នានៅពីមុខអគា អគ្គកុងស៊ុលរុស្ស៊ី។ ពួកគេស្រែកទាមទារប្រឆាំង «អ្នកក្រុងម៉ូស្គូ» និង ប្រធានាធិបតីរុស្ស៊ី វ្លាឌីមៀរពូទីន។ អ្នកចូលរួមនៅក្នុងកូដកម្មបានចោលគ្រាប់បែកផ្សែង និង ផាវចូល ទៅក្នុងអគ្គកុងស៊ុល ហើយប៉ូលីសត្រូវបានគេដាក់ឈរជើងនៅក្បែរនោះ។

**ថ្ងៃទី ២៨ ខែ សីហា** លើភ្នំ Kerek ក្នុង Beregovo (ភូមិភាគ Zakarpattia) ជាទីកន្លែងដែលសហគម ន៍ ហុងគ្រីរស់នៅ ជនអនាមិកមួយក្រុមបានបំផ្លាញទង់ជាតិហុងគ្រី ដែលដោតនៅក្បែរទង់ជាតិអ៊ុយក្រែ ន។ អភិបាលក្រុងZ. Babyak សំដែងការខឹងសម្បារចំពោះការវាយប្រហារទៅលើនិមិត្តរូបហុងគ្រី និង បានអំពាវនាដល់អ្នករស់នៅក្នុងក្រុងដោយបញ្ជាក់ថា អំពើប្រព្រឹត្តបែបនេះអាចនឹងគំរាមកំហែងសុខ សន្តិភាពនៃទីក្រុង ហើយវាអាចបណ្តាលអោយការមិនចុះសម្រុងគ្នារវាងជាតិសាសន៍។ លោកបាន អំពាវនាវអោយអាជ្ញាធរចាត់វិធានការចំពោះករណីនេះ និង ផ្តន្ទាទោសអ្នកដែលបានប្រព្រឹត្ត។

**ថ្ងៃទី ២៧ ខែសីហា** គណកម្មាធិការប្រតិបត្តិក្រុង Mukachevo (ភូមិភាគ Zakarpattia) បានសម្រេច ផ្លាស់ប្តូរវិថីនានាដែលមានឈ្មោះបុគ្គលប្រវត្តិសាស្ត្រល្បីៗរុស្ស៊ី។

**ថ្ងៃទី២៨ ខែ សីហា** នៅគៀវ ទស្សនាវដ្តីប្រចាំសប្តាហ៍ Delovaya Stolitsa (ទីក្រុងពាណិជ្ជកម្ម) បាន បោះពុម្ពផ្សាយអត្ថបទមួយដែលមានចំណងជើងថា «របៀបបោសសំអាតពិតពរុស្ស៊ី» ក្នុងអ្វីដែលអ្នក និពន្ធបានអំពាវនាវអោយអាជ្ញាធរសន្តិសុខអនុវត្តនូវសកម្មភាពរបស់ក្រុមបះបោរ។ ក្នុងចំនោមវិធាន ការណ៍ដែលលើកឡើងដោយទស្សនាវដ្តីមានដូចខាងក្រោមៈ

-ដកចេញនូវបញ្ហាភាសារុស្ស៊ីជាភាសារដ្ឋទី២ ពីរបៀវារៈនយោបាយនៃសង្គមអ៊ុយក្រែន។

-អនុវត្តនូវ«មិន-រុស្ស៊ីនិយម» នៅក្នុងប្រព័ន្ធអប់រំដោយជំនួសភាសារុស្ស៊ីដោយភាសាអង់គ្លេសនៅក្នុង វិស័យអប់រំ (តាំងពីថ្នាកមត្តេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សា»។

-ដកចេញភាសារុស្ស៊ីចេញពីប្រព័ន្ធផ្សព្វផ្សាយអ៊ុយក្រែន។

-លុបចោលការចាកផ្សាយបទចម្រៀងរុស្ស៊ីពីវិទ្យុ ជាពិសេសពីការផ្សព្វផ្សាយហ្វ្រកង់ FM។

-រឹតបន្តឹងការលក់សៀវភៅរុស្ស៊ីនៅក្នុងប្រទេសអ៊ុយក្រែន។

-ជំនួសឈ្មោះទីក្រុង ភូមិអ៊ុយក្រែន ដែលបន្សល់ពីសូវៀត ។

**ថ្ងៃទី ២៩ ខែ សីហា** អនុប្រធានរដ្ឋបាលសាធារណៈនៃភូមិភាគ . Dnepropetrovsk លោក G. Korban ត្រូវបានអ្នកកាសែតដាក់ឈ្មោះថា «អ្នកវាយឆ្មក់ប្រកបដោយអាជីពលេខ១ នៅប្រទេសអ៊ុយក្រែន» ក្រោយពីលោកបាននិយាយថា «ចាំបាច់ត្រូវធ្វើជាតូនីយកម្មទ្រព្យសម្បត្តិរុស្ស៊ីនៅអ៊ុយក្រែន»។ ថ្ងៃទី ២៩ ខែសីហា នៅ Lvov កុងស៊ុលរុស្ស៊ីត្រូវបានទទួលរងការវាយប្រហារ។ ពួកណាឌីកាល់ជាតិនិយមបានហែកស្លាកពីអគារ និង ព្យាយាមដាក់សំបកកង់តាមរបងអគាកុងស៊ុល។ អាជ្ញាធរមិនបានចាត់វិធានការណ៍អ្វីការពារពីសកម្មភាពនេះឡើយ។

**ថ្ងៃទី ៣០ ខែ សីហា** នៅក្នុងកាសែត Halychyna នៃក្រុមប្រឹក្សាភូមិភាគ Ivano-Frankovsk ដែលទទួលការផ្គត់ផ្គង់ការបោះពុម្ពដោយថវិការភូមិភាគ នៅក្នុងផ្នែកទំព័រមុខបានដាក់ថា «សត្រូវគឺរុស្ស៊ី» ត្រូវបានបោះពុម្ព។

**ថ្ងៃទី ៣០ ខែសីហា (ពេលយប់)** នៅ Lutsk ជនអនាមិកមួយក្រុមបានចាក់ទំលុះកង់រថយន្តទាំង៤ របស់នាយកមជ្ឈមណ្ឌលវប្បធម៌រុស្ស៊ី លោក O. Sagan ហើយបានចងបូដែលមានពណ៌ខៀវ និង លឿងនៅនឹងកញ្ចក់ខាងក្រោយ។

**ថ្ងៃទី ៣១ ខែ សីហា** ទស្សនាវដ្តីអាមេរិក «នយោបាយការបរទេស» បានដកស្រង់យកកស្តុតាងដែលថាក្រុម neo-Nazis ជាពិសេសក្រុមអាសាស្ម័គ្រ «Azov» កំពុងវាយប្រយុទ្ធជាមួយក្រុមងើបបះបោរនៅភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែន មានមេដឹកនាំដែលនូវតែប្រកាន់ខ្ជាប់ទស្សនះរបស់ក្រុមអ្នកជាតិនិយមជំនាន់ឆ្នាំ ១៩៣០-១៩៤០។

**ថ្ងៃទី ៣១ ខែសីហា** អតីតអភិបាលក្រុង Uzhgorod លោក S. Ratushnyak បានធ្វើការសំណូមពរដោយបានសរសេរនៅក្នុងបណ្តាញហ្វេសប៊ុកថា អាជ្ញាធរអ៊ុយក្រែនគួរតែបង្កើតអោយមានកងកម្លាំងទ័ពដែលរើសចេញពីពួកជ្វីព រូម៉ា និង តាតា ដើម្បីបញ្ជូនទៅប្រយុទ្ធនៅក្នុងតំបន់ «អាតូ»។ គាត់បានសរសេរថា ក្រុមនៃជនភាគតិចទាំងនេះមិនបានផ្តល់ប្រយោជន៏អ្វីទាល់តែសោះដល់ប្រទេសអ៊ុយក្រែន ប៉ុន្តែមានតែ «ចំនាយយ៉ាងខ្ជះខ្ជាយរាប់រយពាន់ដុល្លារនៃលុយរបស់យើង»។

**តាំងពីថ្ងៃទី ១ ខែកញ្ញា** នៅក្រុង Uzhgorod មានការរៀបចំយុទ្ធនាការប្រឆាំងនឹងទំនិញដែលនាំចូលពីប្រទេសរុស្ស៊ី។ នៅក្នុងហាងទំនិញ ភោជនីយដ្ឋាន មានការបិទនូវស្លាកដែលសរសេរថា ទំនិញរុស្ស៊ីមិនមានលក់នៅទីនេះទេ។

**ថ្ងៃទី១ ខែកញ្ញា** គណៈកម្មាធិការរៀបចំការបោះឆ្នោតកណ្តាលរបស់អ៊ុយក្រែនបានបដិសេធការបង្កើតតំបន់បោះឆ្នោតដាច់ដោយឡែកដែលបានលើកឡើងដោយក្រុមជនភាគតិចហុងគ្រី Transcarpathia ។ ប្រធាននៃសង្គមវប្បធម៌ហុងគ្រីនៅក្នុងតំបន់Transcarpathia បានស្នើសុំជាផ្លូវការទៅកាន់គណៈកម្មាធិការរៀបចំបោះឆ្នោតកណ្តាលដោយយោងទៅលើមាត្រាទី ១៨ វាក្យខណ្ឌទី ៣ នៃច្បាប់របស់អ៊ុយក្រែន»ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ» ។

**ថ្ងៃទី ១ ខែកញ្ញា** ប្រមុខនៃក្រសួងការពារជាតិអ៊ុយក្រែន លោក V. Heletey បានប្រកាសថា ប្រតិបត្តិការដើម្បីរំដោះភាគខាងកើតនៃប្រទេសអ៊ុយក្រែនពិពួកភេរវករបានមកដល់ទីបញ្ចប់ហើយ ហើយ «សង្គ្រាមនៃមហាស្នេហាជាតិ» បានចាប់ផ្តើម។ ជនរងគ្រោះនឹងមានចំនួនរាប់មឺននាក់។

**ថ្ងៃទី ២ ខែកញ្ញា** ក្រុមប្រឹក្សាក្រុង Chernovtsy បានស្នើសុំប្រធាននៃធនាគារជាតិប្រទេសអ៊ុយក្រែន លោកV. Hontaryeva អោយពិចារណាលទ្ធភាពលុបចោលអាជ្ញាប័ណ្ណដែលផ្តល់អោយធនាគាររុស្ស៊ី Sberbank JSCនិង ធនាគារស្តង់ដារុស្ស៊ី ក្រោមលេសថា ធនាគារទាំងនេះបានចូលរួមពាក់ព័ន្ធនឹងការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ពួកងើបបះបោរ។

**ថ្ងៃទី ៣ ខែ កញ្ញា** នៅលើគេហទំព័រផ្លូវការ ទីភ្នាក់ងារភាពយន្តរដ្ឋអ៊ុយក្រែន បានដាក់ទណ្ឌកម្មមិនចាក់ផ្សាយភាពយន្តរុស្ស៊ី និង កម្មវិធីទូរទស្សន៍។

**ថ្ងៃទី ៤ ខែកញ្ញា** នៅលើប៉ុស្តិ៍ទូរទស្សន៍សភា "Rada" អនុប្រធានសភាអ៊ុយក្រែនបានបញ្ជាក់ថា រុស្ស៊ីនឹងមិនចាកចេញពីអ៊ុយក្រែនឡើយ ហើយ ឱកាសតែមួយគត់ដែលអាចបញ្ឈប់សង្គ្រាមគឺការដេកប្រធានាធិបតីរុស្ស៊ីវ្លាឌីមៀរ ពូទីនពីប្រមុខរដ្ឋ។

**ថ្ងៃទី ៦ ខែកញ្ញា (ពេលព្រឹក)** នៅក្នុងភូមិ Zhnyatino នៃសង្កាត់ Mukachevo (ភូមិភាគ Zakarpattia) អ្នកស្រុកបានរកឃើញផ្នែកនៃកន្លែងកប់រណ្តៅសាកសពរួមនៅក្នុងទីបញ្ចុះសពប្រូតេស្តង់មួយកន្លែងត្រូវបានបំផ្លាញ ។ ថ្មដាក់ផ្កាបែកបាក់ ចំណែក កម្រងផ្កាត្រូវបានដុតបំផ្លាញ។ ថ្មបញ្ចុះសាកសពនៅក្នុងទីបញ្ចុះសពអ៊ុយក្រែនមិនមានការខូចខាតនោះទេ។ ប្រជាជនហុងគ្រីភាគតិច ដែលភាគច្រើនគឺជាអ្នកកាន់គ្រិស្តសាសនាបែបប្រូតេស្តង់ ដែលតំណាងអោយ ៦៥%នៃអ្នកស្រុកដែលរស់នៅ Zhnyatino's និង ប្រហែល ៣០ភាគរយគឺជនជាតិអ៊ុយក្រែនដែលគោរពប្រតិបត្តិសាសនាគ្រិស្តបែបកាតូលិកក្រិក។ យោងតាមអ្នកតំណាងនៃគណបក្ស ហុងគ្រីលោក S. Oros មិនដែលមានជម្លោះជាតិសាសន៍ ឬសាសនារវាងអ្នកស្រុកនោះទេ។

**ថ្ងៃទី ៧ ខែកញ្ញា** ទូរទស្សន៍អាល្លឺម៉ង់បានបង្ហាញអោយឃើញកងទ័ពអ៊ុយក្រែនក្នុងសំលៀកបំពាក់ទាហានមានភ្ជាប់ដោយរូបសញ្ញាណាស៊ី នៅលើមួក។ វីដេអូត្រូវបានថតដោយក្រុមការងារនៃប៉ុស្តិ៍ទូរទស្សន៍ឯកជនរបស់ប្រទេសនរវេស ប៉ុស្តិ៍លេខ ២ ដែលរៀបចំរបាយការណ៍ស្តីអំពី កងអាសាស្ម័គ្រអ៊ុយក្រែន «អាហ្សូវ» ក្នុងក្រុង Urzuf។

**ថ្ងៃទី ៨ ខែកញ្ញា** នៅក្នុងសង្កាត់នៃភូមិភាគ Kirovograd មានការជួបប្រជុំរវាងនាយកសាលា។ កិច្ចប្រជុំបានសម្រេចហាមប្រាមការបង្រៀនភាសារុស្ស៊ីនៅក្នុងសាលា។ មុខវិជ្ជានេះត្រូវបានគេដកចេញពីកាលវិភាគសិក្សាទាំងស្រុង។ មន្ត្រីអ៊ុយក្រែនបានគិតថា នាយកសាលាណាដែលនៅតែបង្រៀនភាសារុស្ស៊ីជាមុខវិជ្ជាសិក្សានោះគឺជា «ក្រុមអ្នកបំបែកទឹកដី» ហើយនឹងជាអ្នកចូលរួមជាមួយ «ភេរវករ»។

**ថ្ងៃទី ៩ ខែកញ្ញា** ការិយាល័យព្រះរាជអាជ្ញានៃសង្កាត់ Svatovo ក្នុងភូមិភាគឡូហានស្គ៍ បានប្រកាសថាមានការជាប់សង្ស័យចំពោះសកម្មភាពអភិបាលក្រុងស្តីទីនៃក្រុង Rubezhnoye គឺលោក A. Khomenkoក្នុងការផ្តល់ជំនួយដល់ពួកភេរវករ។ លោកបានដើរតួនាទីយ៉ាងសកម្មគាំទ្រប្រជាជនដែលមិនគាំទ្រជាមួយនឹងអាជ្ញាធរអ៊ុយក្រែនថ្មី និង បានគាំទ្រគំនិតអំពីការបង្កើតសហព័ន្ធអ៊ុយក្រែន។

**ថ្ងៃទី ១១ ខែ កញ្ញា** កាសែត « Guardian» បានបោះពុម្ពអត្ថបទមួយដែលបានហៅក្រុមកងអាសាស្ម័គ្រ «អាហ្សូវ» និង ក្រុមអង្គភាពផ្សេងទៀតថា ជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់រដ្ឋាភិបាលអ៊ុយក្រែនហើយប្រជាថែមទាំងរដ្ឋ... អាស្រ័យដោយការងាកទៅស្តាំជ្រុលពេក សូម្បីតែពួក neo-Nazi ។

**ថ្ងៃទី ១១ ខែ កញ្ញា** នៅពេលជួបប្រជុំរបស់ក្រុមប្រឹក្សាក្រុង នីកូឡាយេវ បានសម្រេចនូវកាតព្វកិច្ចត្រូវតែដាក់ផ្លាករាល់ទំនិញរុស្ស៊ី។ នៅ Zhitomir ក្រុមជាតិនិយមបានចែកចាយខិតប័ណ្ណប្រឆាំងនឹងពួករុស្ស៊ី ដោយការទាមទារមិនអោយទិញទំនិញរុស្ស៊ី។
**ថ្ងៃទី ១១ ខែ កញ្ញា** សមាជិកនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សសម្រាប់ព័ត៌មាន និង ការពិគ្រោះយោបល់ដែលធ្វើការក្រោមធ័ត្រនៃអង្គការក្រៅរដ្ឋាភិបាល « Romanicherhen» បានរាយការណ៏អោយដឹងស្ដីអំពីការរំលោភបំពានសិទ្ធិមនុស្សនៃក្រុមជនភាគតិច រ៉ូម៉ា ក្នុងក្រុង Uzhgorod។ ជាពិសេស គេបានរកឃើញកុមារជាតិរ៉ូម៉ាមិនត្រូវបានគេអនុញ្ញាតអោយចូលរៀននៅសាលាលេខ ១៣ និង ១៤។ យោងតាមការសម្រេចនៃអតីតអភិបាលក្រុង លោក V. Pogorelov និង ប្រមុខនាយកដ្ឋានអប់រំលោក N. Komaritsky។ សាលាលេខ ១៤ ត្រូវរៀបចំឡើងវិញ ហើយថ្ងៃទី ១ កញ្ញា មានកុមារជាតិ រ៉ូម៉ា ជាង ៣០នាក់ ដែលបានរៀននៅទៅនោះអស់ រយៈពេល ៤ឆ្នាំហើយនោះមិនត្រូវបានគេអនុញ្ញាតិអោយបន្តការសិក្សាទៀតបាន។
**ថ្ងៃទី ១១ ខែ កញ្ញា** ព្រះសង្ឃរាជវិហារកាតូលិកអ៊ុយក្រែន N. Zalyznyak មានជីការនៅក្នុងពិធីបុណ្យសពនៃក្រុមប្រយុទ្ធ «ស្លាបស្ដាំ»បានសំណូមពរថា កងសន្តិសុខអ៊ុយក្រែនម្នាក់ត្រូវតែសម្លាប់កងទ័ពបះបោរផ្ដាច់ទឹកដី។
**ថ្ងៃទី ១១ ខែ កញ្ញា** គេហទំព័រព័ត៌មាន « Ternopol Information Bureau» បានទាញយកចំណាប់អារម្មណ៏អ្នកអានចំពោះព្រឹត្តិការណ៏ដែលបានកើតឡើងដោយអ្នកបើកឡានក្នុងស្រុកត្រូវបានគេចោទប្រកាន់ថាបានលើកស្ទួយ វប្បធម៌រុស្ស៊ី។ ជនស្នេហាជាតិមិនចូលចិត្តការពិតដែលថា បទភ្លេងរុស្ស៊ីត្រូវបានគេប្រើប្រាស់ទូលំទូលាយ នៅលើរថយន្តដឹកអ្នកដំណើរក្នុងក្រុង។
**ថ្ងៃទី ១២ ខែកញ្ញា** ក្រុមប្រឹក្សាក្រុងរង Ivano-Frankovsk គឺលោក Z. Bolyuk បានសំណូមពរអោយពិនិត្យមើលហេតុផលដែលភាសារុស្ស៊ីមួយចំនួនធំត្រូវបានគេបោះពុម្ពផ្សាយនៅតាមហាងទំនិញនៅ Transcarpathia។
**ថ្ងៃទី ១៨ ខែកញ្ញា** នៅទីក្រុងគៀវ Dnepropetrovsk, Vinnitsa, Poltava, Zhitomir និង បណ្ដាក្រុងផ្សេងៗទៀតការហ្វឹកហាត់សម្រាប់ «យុវជនស្ម័គ្រចិត្ត»ត្រូវបានគេចាប់ផ្ដើម។ ក្នុងសិក្ខាសាលាដែលមិនគិតតម្លៃ សកម្មជនមកពីអង្គការរ៉ាឌីកាល់ជាតិនិយមបានប្រាប់យុវជនក្មេងៗអ៊ុយក្រែនអំពីរបៀបរៀបចំនិងធ្វើបាតុកម្មនិង ការស្វែងរកប្រជាជនដែលមានចិត្តស្រដៀងគ្នាក្នុងការបង្កើតយុទ្ធនាការព័ត៌មាន។
**ថ្ងៃទី ១៨ ខែ កញ្ញា** អភិបាលក្រុង Khmelnitsky លោក S. Melnik បានលើកឡើងសំនើនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាទាក់ទងនឹងផលិតផលរុស្ស៊ីរួមទាំងថ្នាំពេទ្យត្រូវដាក់បិទផ្លាកជាមួយនឹងរូបភាពសត្វកូឡូរ៉ាដូ។
**ថ្ងៃទី ១៩ ខែកញ្ញា** ប្រធានរដ្ឋបាលភូមិភាគ Chernovtsy គឺលោក Vanzuryak បានស្នើសុំអោយមានការហាមឃាត់ការបញ្ចាំងរឿងកុនរុស្ស៊ីនៅភូមិភាគ Chernovtsy។
**ថ្ងៃទី ១៩ ខែកញ្ញា** វីដេអូមួយបានផុសឡើងនៅលើអ៊ីនធឺណេតដែលបានបង្ហាញកុមារ «កងអាសាស្ម័គ្រ» ឈ្មោះ «ហ្វាកុន» ត្រូវបានគេបង្កើតឡើងក្នុងភូមិ ណូវីតសា (ភូមីភាគ Ivano-Frankovsk)។

កុមារតូចដែលនៅក្នុងវីដេអូបានច្រៀងចម្រៀងជាតិអ៊ុយក្រែន និង បានស្រែកនូវពាក្យស្លោក «ជយោ អ៊ុយក្រែន! មហាជោគជ័យចំពោះអ្នកក្លាហាន!» «សេចក្តីស្លាប់មានដល់អ្នកក្រុងមូស្គូ» «ជយោជាតិកំណើត បរាជ័យទៅសត្រូវ»

**ថ្ងៃទី ៩ ខែ កញ្ញា** នៅ Dnepropetrovsk សកម្មភាពបង្ហាញអំពីសកម្មភាពភ័យខ្លាច បានកើតឡើងនិង បានដាក់សញ្ញាផលិតផលដែលនាំមកពីប្រទេសរុស្ស៊ី។ នៅក្នុងហាងទំនិញ មានការជេរប្រទេចលោកប្រធានាធិបតីវ្លាឌីមៀរពូទីនផងដែរ។

**ថ្ងៃទី ២១ ខែ កញ្ញា** នៅ. Kramatorsk មនុស្សមួយក្រុមអនាមិកបានបាញ់ថ្នាំគូសវាសទៅលើរូបសំណាកឡេនីនដោយដាក់ព័ណ៌ជាទង់ជាតិអ៊ុយក្រែន និង «ក្រុមស្តាំនិយម»។

**ថ្ងៃទី ២២ ខែកញ្ញា** នៅភូមិ នីកូឡាយ៉េវ មនុស្សបិទមុខបានរំលោភលើវិមានដែលគេសងសាងនៃបណ្តាជនប្រល័យពូជសាសន៍។

**ថ្ងៃទី ២២ ខែ កញ្ញា** ក្នុងទំព័រហ្វេសប៊ុក មេដឹកនាំ សេរីភាព O. Tyahnybok បានអំពាវនាវអោយអាជ្ញាធរអ៊ុយក្រែនបោះបង់ចោលគោលគំនិតស្រម៉ៃអំពីលទ្ធភាពនៃការបញ្ឈប់បាញ់តាមរយៈការធ្វើសម្បទាននយោបាយនិងទឹកដីទៅអោយពូទីន។ ការបន្តឈ្លានពានរបស់រុស្ស៊ី និង ការកាន់កាប់គ្រីម៉េ ជាសក្ខីភាពបញ្ជាក់ថា សម្បទានគឺគ្រាន់តែជំរុញអោយពូទីនបានចិត្តកាន់តែខ្លាំង។

**ថ្ងៃទី ២៥ ខែកញ្ញា** តាមសំណើនៃសមាជិកសភាអ៊ុយក្រែន លោក Turchinov នាយកដ្ឋានអង្កេតនៃក្រសួងមហាផ្ទៃបានបើកករណីឧក្រិដ្ឋកម្មប្រឆាំងនឹងតំណាងរាស្ត្រចំនួន ២៤នាក់។

ថ្ងៃ**ទី ៣០ ខែកញ្ញា (យប់)** ក្រុមជនអនាមិកបានវាយប្រហារទៅលើការិយាល័យ ធនាគារ Sberbank។ ទ្វារបង្អួចត្រូវបានបាក់បែក និង ខាតបង់។

**ថ្ងៃទី ៣០ ខែ កញ្ញា** អនុប្រធានសភា I. Farion បាននិយាយថា «សង្គ្រាមជាមួយប្រទេសរុស្ស៊ីមិនងាយនឹងចប់ឡើយ» ។

**ថ្ងៃទី ២ ខែតុលា** នៅក្នុងកិច្ចសម្ភាសជាមួយអ្នកកាសែតបរទេស ឧបនាយករដ្ឋមន្ត្រីទី១អ៊ុយក្រែន លោក A. Sych បាននិយាយថា រដ្ឋាភិបាលអ៊ុយក្រែនមានគោលបំណងបញ្ចូលចំនួនកូតាសម្រាប់ការបោះពុម្ពជាភាសារុស្ស៊ីដោយមូលហេតុនៃសន្តិសុខព័ត៌មាន។

**ថ្ងៃទី៩ ខែតុលា** ក្រុមប្រឹក្សាក្រុងគៀវ បានដាក់ចេញនូវការណែនាំអោយដាក់ម៉ាក និង តម្លៃភ្ជាប់ជាមួយទំនិញមកពីប្រទេសរុស្ស៊ី។ ការសម្រេចនេះគឺជាផ្នែកមួយនៃវិធានការណ៍សម្របសម្រួលសកម្មភាពព័ត៌មាន និង ការពារសន្តិសុខព័ត៌មានសាធារណៈក្នុងរដ្ឋធានីគៀវ។

**ថ្ងៃទី ១៤ ខែ តុលា** នៅតាមបណ្តាទីក្រុងអ៊ុយក្រែនមួយចំនួន ក្នុងឱកាសនៃការប្រារព្ធពិធីរំលឹកដល់ថ្ងៃនៃការបង្កើតកងទ័ពអ៊ុយក្រែន គេឃើញមានការដើរជាក្បួនដោយដៃកាន់ចន្លុះភ្លើងក្នុងទំរង់ជា Neo-Nazis រួមផ្សំនឹងសេចក្តីថ្លែងការណ៍ប្រកបដោយភាពស្អប់ខ្ពើម។ ជាពិសេស អនុប្រធានសភាអ៊ុយក្រែន លោក I. Farion បាននិយាយនៅចំពោះមុខពួកក៉ាឌីកាល់ជាតិនិយមគៀវអំពាវនាវ «បាញ់សម្លាប់ពួកអ្នកក្រុងម៉ូស្គូ» «បំផ្លាញក្រុងមូស្គូ» »ចំនុចខ្មៅនៃសន្តិសុខអឺរ៉ុប» ទាំងនេះសុទ្ធសឹងតែជាពាក្យដែលហ៊ីត្លែរប្រើប្រាស់ និង ការញុះញង់អោយប្រើប្រាស់កម្លាំង។

**ថ្ងៃទី ១៤ ខែ តុលា** កងទ័ពអ៊ុយក្រែនបានគ្រវីទង់នៃ«ក្រុមស្លាបស្ពាំ» និង «សេរីភាព» ដើរសំដៅមកសភា ដោយទាមទារអោយអនុម័តច្បាប់លើកលែងទោស  ទទួលស្គាល់ក្រុមប្រយុទ្ធស្ថិតក្នុងកម្រិតជាតិ និង ហាមមិនអោយមាននយោគមនកុម្មុយនិស្ត ។ មិនតែប៉ុននោះ គ្រាប់បែកសាំង និង ផាវ ត្រូវបានគេបោះចូលទៅក្នុងអគារសភា។
**ថ្ងៃទី ១៥ ខែតុលា** ក្រុមហ៊ុន Zaporizhstal បានបញ្ជាក់ថា ក្រុមមនុស្ស១០០-១៥០នាក់ដែលបានពាក់មុខជិតមានពាក់សញ្ញា«ក្រុមស្លាបស្ពាំ»បានបិទផ្លូវចូលទៅក្នុងអគាររបស់ខ្លួន។
**ថ្ងៃទី ២១ តុលា** នៅ Lvov សមាជិកនៃចលនាក្រុមតស៊ូដើម្បីឯករាជ្យ បានចែកចាយខិតប័ណ្ណដើម្បីរំលឹកដល់ខួបនៃការសំលាប់កុងស៊ុលសូវៀតលោក Maylov ដោយអ្នកជាតិនិយម Lemik នៅឆ្នាំ ១៩៣៣។ ពួកគេអះអាងថា «ថ្ងៃនេះ ទង្វើប្រកបដោយវីរភាពនៃអ្នកជាតិនិយម គឺស្ថិតនៅក្នុងការចងចាំរៀងរហូត»។ តាមសកម្មជនជាតិនិយម «ប្រជាជនអ៊ុយក្រែននឹងតែងតែស្វែងរក Nikolay Lemik ម្នាក់សម្រាប់ Alexey Maylov របស់ពួកគេ»។
**ថ្ងៃទី ២៣ ខែតុលា** នៅ Kirovograd គណបក្ស Batkivshchyna បានរៀបចំការសម្តែងនៅពីមុខរដ្ឋបាលសាធារណៈភូមិភាគ: អ្នកទាំងអស់គ្នាអាចបាញ់ទៅលើរូបថតប្រធានាធិបតីរុស្ស៊ីដោយកាំភ្លើងរបស់ខ្លួន។យោងតាមសារព័ត៌មានក្នុងស្រុក គំនិតនេះត្រូវបានប្រើប្រាស់ដោយអ្នកជាតិនិយមនៅ Rovno,Poltava និង Cherkassy។
**ថ្ងៃទី ២៨ ខែតុលា** ប្រមុខនៃក្រសួងវប្បធម៌រុស្ស៊ីបាននិយាយថា បញ្ជីឈ្មោះសិល្បករចំនួន ១៤នាក់ត្រូវបានគេហាមឃាត់មិនអោយចូលទៅក្នុងទឹកដីប្រទេសអ៊ុយក្រែន។

**ការរំលោភបំពានសិទ្ធិមានសេរីភាពនៃការគិត មនសិការ និង សាសនា**
**សេចក្តីប្រកាសសិទ្ធិមនុស្សជាសកល (ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨)**
**មាត្រាទី ៣**
មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិត សេរីភាព និង សន្តិសុខផ្ទាល់ខ្លួន
**មាត្រាទី ៥**
គ្មាននរណាម្នាក់ជាកម្មវត្ថុនៃការធ្វើទារុណកម្ម ឬ អំពើសាហាវយង់ឃ្នង អមនុស្សធម៌ និងបន្ទាបបន្ថោកតម្លៃឡើយ។
**មាត្រាទី ១៨**
មនុស្សគ្រប់រូបមានសិទ្ធិមានសេរីភាពនៃការគិត មនសិការ និង ជំនឿសាសនា។ សិទ្ធិនេះរួមបញ្ចូលសេរីភាពផ្លាស់ប្តូរសាសនា ឬ ជំនឿ និង សេរីភាពនៅម្នាក់ឯង ឬ ក្នុងសហគមន៍ជាមួយអ្នកដទៃ និង ក្នុងទីសាធារណៈ ឬ ជាឯកជន ក្នុងការសំដែងជំនឿសាសនា ការប្រតិបត្តិ និង ការបូជា ។

**កាតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិស៊ីវិល និង នយោបាយ**
**(ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦)**
**មាត្រាទី ៦**
មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិតពីកំនើត។ សិទ្ធិនេះត្រូវបានការពារដោយច្បាប់។ គ្មានជនណាម្នាក់មានសិទ្ធិដកហូតសិទ្ធិនេះបានឡើយ។
**មាត្រាទី ៧**
គ្មានជនណាម្នាក់ជាកម្មវត្ថុនៃការធ្វើទារុណកម្ម ឬ អំពើសាហាវយង់ឃ្នងអមនុស្សធម៌ និង បន្ទាបបន្ថោកតម្លៃឡើយ។ ជាពិសេស គ្មានជនណាម្នាក់ ជាកម្មវត្ថុនៃការពិសោធន៏វិទ្យាសាស្ត្រ និង វេជ្ជសាស្ត្រដោយគ្មានការយល់ព្រមពីបុគ្គលនោះឡើយ។
**មាត្រាទី ៨**
ក. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ជាកម្មវត្ថុនៃការចាប់ខ្លួន ឬ ឃុំឃាំងខ្លួនឡើយ។ គ្មានជនណាម្នាក់អាចដកហូតសេរីភាពដលើកលែងតែស្របទៅតាមនីវិធីដែលមានចែងនៅក្នុងច្បាប់។
**មាត្រាទី ១៨**
ក. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេរីភាពនៃគំនិត មនសិការ និង សាសនា។ សិទ្ធិនេះត្រូវរួមបញ្ចូលនូវសេរីភាពមានសាសនា ឬ ជំនឿដែលជាជំរើសរបស់បុគ្គល និង សេរីភាពទាំងបុគ្គល និង ក្នុងសហគមន៏ជាមួយអ្នកដទៃ និង ជាសាធារណៈ ឬ ឯកជន។ ប្រតិបត្តិជំនឿនិង សាសនា ដោយការបូជាប្រតិបត្តិ និង ការបង្រៀន។
*ខ.* គ្មានជនណាម្នាក់ជាកម្មវត្ថុនៃការគម្រាមបង្ខំ ដែលធ្វើអោយប៉ះពាល់សេរីភាពមានសាសនា និង ការទទួលយកសាសនា ឬជំនឿនៃជម្រើសរបស់បុគ្គលនោះ។
**មាត្រាទី២០**
ក. រាល់ការឃោសនាដើម្បីសង្គ្រាមត្រូវបានហាមប្រាមដោយច្បាប់។
ខ. រាល់ការជំរុញអោយមានការស្អប់ខ្ពើមជាតិ សាសន៏ និង សាសនា ដែលបណ្តាលអោយមានការញុះញង់ឈានដល់ការរើសអើង ការប្រឈមមុខ ឬ អំពើហិង្សា ត្រូវបានហាមប្រាមដោយច្បាប់។
**មាត្រាទី ២៦**
មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ និង ទទួលបានការការពារស្មើគ្នាដោយច្បាប់គ្មានការរើសអើង។ ក្នុងន័យនេះ ច្បាប់ត្រូវហាមប្រាមរាល់ការរើសអើងនិងការធានាអោយបានចំពោះមនុស្សគ្រប់រូបទទួលបានការការពារស្មើគ្នា និង ប្រកបដោយប្រសិទ្ធិភាពប្រឆាំងទៅនឹងការរើសអើងគ្រប់រូបភាពដូចជាជាតិសាសន៏ ពណ៌ ភេទ ភាសា សាសនា និន្នាការនយោបាយ ទ្រព្យសម្បត្តិ កំណើត និង ឋានៈដទៃទៀត។

**កាតិកាសញ្ញាការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន**
**( ទីក្រុង រ៉ូម ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ )**
**មាត្រាទី ២ សិទ្ធិរស់រានមានជីវិត**
មនុស្សគ្រប់រូបមានសិទ្ធរស់រានមានជីវិតត្រូវបានធានាដោយច្បាប់។ គ្មានជនណាម្នាក់ត្រូវបានគេដក ហូតសិទ្ធិនេះដោយចេតនាឡើយ។ ការកាត់ទោសប្រហារជីវិតគឺត្រូវធ្វើឡើងតាមរយៈតុលាការដោយ យោងទៅលើបទឧក្រិដ្ឋដែលជននោះបានប្រព្រឹត្ត។
**មាត្រាទី ៣ ការហាមប្រាមការធ្វើទារុណកម្ម**
គ្មានជនណាម្នាក់ជាកម្មវត្ថុនៅការធ្វើទារុណកម្មឬទទួលរងនូវអំពើអមនុស្សធម៌ និង ការបន្ទាបបន្ថោក ឡើយ។
**មាត្រាទី ៥ សិទ្ធិទទួលបានសេរីភាព និង សន្តិសុខ**
មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន។
**មាត្រាទី ៩ សេរីភាពនៃការគិត មនសិក្សា និង សាសនា**
ក.មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេរីភាពនៃគំនិត មនសិការ និង សាសនា។ សិទ្ធិនេះរួមបញ្ចូល នូវសេរីភាពនៃការផ្លាស់ប្តូរសាសនា ឬ ជំនឿ និង សេរីភាពនៅម្នាក់ឯង ឬក្នុងសហគមន៏ជាមួយអ្នក ដទៃទៀតនិង ក្នុងសាធារណៈ ឬ ជាឯកជន ប្រតិបត្តិសាសនានិង ជំនឿ ក្នុងការគោរពបូជា ។
**មាត្រាទី១៤**
ការទទួលបានសិទ្ធិនិងសេរីភាពដូចដែលបានចែងនៅក្នុងកាតិកាសញ្ញានេះត្រូវបានធានាដោយគ្មានការ រើសអើងគ្រប់រូបមានដូចជា ភេទ ជាតិសាសន៏ ពណ៌ ភាសា សាសនា និន្នាការនយោបាយ ទ្រព្យ សម្បត្តិកំណើត និង ឋានៈដទៃទៀត។

**កាតិកាសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងអំពើសាហាវយង់ឃ្នង អមនុស្សធម៌ និង ការបន្ទាបបន្ថោក**
**(ថ្ងៃទី ១០ ខែធ្នូឆ្នាំ ១៩៨៤)**
**មាត្រាទី២**
ក. ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការណ៏អោយមានប្រសិទ្ធិភាពតាមនីតិវិធីច្បាប់ រដ្ឋបាល និង តុលាការ ដើម្បីការពារមិនអោយមានការធ្វើទារុណកម្មកើតមានលើទឹកដីក្រោមដែនគតិយុត្តិរបស់ខ្លួនឡើយ។
ខ. គ្មានកាលៈទេសៈលើកលែងណាឡើយ ទោះរដ្ឋនោះកំពុងធ្វើសង្គ្រាមឬទទួលការគំរាមកំហែង ដោយសង្គ្រាម អសន្តិសុខនយោបាយផ្ទៃក្នុង ឬ ករណីបន្ទាន់ជាសាធារណៈដទៃទៀតអាចធ្វើអោយប៉ះ ពាល់ដល់ការអនុវត្តការធ្វើទារុណកម្ម។
គ. រាល់បញ្ជារបស់មន្ត្រីថ្នាក់លើឬ អាជ្ញាធរសាធារណៈ មិនត្រូវបានប្រើប្រាស់ជាលេសក្នុងការធ្វើទារុណ កម្ម។

**ពិធីសារបន្ថែមពាក់ព័ន្ធនឹងកាតិកាសញ្ញាហ្សឺណែវថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និង ពាក់ព័ន្ធការ ការពារជនរងគ្រោះក្នុងជម្លោះប្រដាប់អាវុធមិនអន្តរជាតិ**
**( ពិធីសារ២ ហ្សឺណែវ ថ្ងៃទី ៨ ខែមិថុនា ១៩៧៧ )**

មាត្រាទី៩ ការការពារបុគ្គលិកសុខាភិបាល និង សាសនា

ក. បុគ្គលិកសុខាភិបាលនិងសាសនាត្រូវបានគោរពនិងការពារ ព្រមទាំងបានទទួលនូវការជួយតាមលទ្ធភាពដើម្បីសម្រេចបាននូវការបំពេញភារកិច្ចរបស់ខ្លួន។ បុគ្គលិកទាំងនោះតមិនត្រូវបានបង្ខំអោយធ្វើការដែលមិនមែនជាបេសសកម្មមនុស្សធម៌នោះឡើយ។

**ពីថ្ងៃទី ១ ដល់ ២ ខែ កក្កដា** ព្រះវិហារសាសនាគ្រិស្តអ៊ុយក្រែនពីរដែលស្ថិតនៅក្រោមការទំនុកបម្រុងមូស្គូ ក្នុងភូមិ Antipovka និង Pyriatyn ត្រូវបានគេដុតបំផ្លាញ។

**ថ្ងៃទី ១៣ ខែ កក្កដា** មនុស្សមួយក្រុមប្រដាប់ដោយអាវុធ និង មានឯកសណ្ឋានជាទាហានបានចូលទៅក្នុងព្រះវិហារ Saint Michael ស្ថិតនៅ Krasnoarmeysk ( ភូមិភាគ Donetsk ) ក្នុងកំឡុងនៃការប្រារព្ធពិធីរំលឹកដល់ព្រះយេស៊ូហើយបានរារាំងរំខានដល់ការប្រារព្ធពិធីនេះ។

**ថ្ងៃទី ១៧ ខែ កក្កដា** ក្នុងកំឡុងពេលបុណ្យសាសនានៅ Slavyanskអ្នកជាតិនិយមរ៉ាឌីកាល់មួយក្រុមបានសំរុកចូលក្នុងព្រះវិហារហើយបានគំរាមបព្វជិត Vitaly Vesely ដោយប្រកាសថា នៅអ៊ុយក្រែនគ្មានកន្លែងសម្រាប់វិហារគ្រិស្តអរថូដុកដែលស្ថិតក្រោមម៉ូស្គូនោះទេ។

**ថ្ងៃទី ២០ ខែកក្កដា** ក្រុមជាតិនិយមមួយក្រុមបានបង្ខំបព្វជិត Vadim Yablonskyជីករណ្តៅសម្រាប់ខ្លួន។នៅថ្ងៃជាមួយគ្នានោះដែរ ពួកគេបានដាក់ខ្នោះបព្វជិត Victor Stratovich ហើយដាក់កញ្ចប់ធំនៅលើព្រះកេសលោក និងបាននាំទៅក្នុងព្រៃជាទីដែលគេបង្ខំអោយលោកអង្គុយលត់ជង្គង់ សួរចំលើយនិងជេរប្រមាថកាតទាន។

**ថ្ងៃទី ២៨ ខែ កក្កដា** ក្នុងកំឡុងពេលការវាយប្រហារដោយកាំភ្លើងធំពីកងទ័ពអ៊ុយក្រែន គ្រាប់មួយបានធ្លាក់ចំ  Gorlovka ។ សំណាងល្អ ពុំមានអ្នករងរបួសឬស្លាប់បាត់បង់ជីវិតឡើយ។

**ថ្ងៃទី ២៨ ខែកក្កដា** បព្វជិត Georgy Nikishev ក្នុងព្រះវិហារ Sts. Peter and Paul ក្នុងក្រុង Pervomaysk បានបាត់បង់ជីវិតដោយសាររងរបួសពីការបាញ់ផ្គក់របស់កងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ៣០ ខែ កក្កដា** នៅក្នុងភូមិ Krasnoarmeyskoe ក្រុមជនអនាមិកប្រដាប់ដោយអាវុធបានចូលក្នុងផ្ទះរបស់បព្វជិត I. Sergienko។ បព្វជិតត្រូវបានគេប្រមាថកាតទាននិងទទួលរងការចោទប្រកាន់ថាបានផ្តល់ជំនួយនិងគាំទ្រពួកទណ្ឌិត ព្រមទាំងបានផ្ញើលុយទៅកាន់មូស្គូ។

**ថ្ងៃទី ៣០ ខែ កក្កដា** បព្វជិត Yevgeny Podgorny ត្រូវបានកងកម្លាំងអ៊ុយក្រែនឃុំខ្លួននៅកន្លែងត្រួតពិនិត្យជិតទីក្រុង Amvrosievka។ ក្នុងខណៈពេលកំពុងឆែកឆេរ រថយន្តរបស់លោកត្រូវបានបំផ្លាញ។ បព្វជិតទទួលរងការប្រមាថកាតទានដោយចោទប្រកាន់ថាបានផ្តល់ការឧបត្ថម្ភដល់ក្រុមបះបោរផ្តាច់ទឹកដី។ បព្វជិត Yevgeny Podgorny ត្រូវបានគេចង ហើយវាយតប់យ៉ាងទម្ងន់។ រូបឈើឆ្កាងរបស់លោកត្រូវបានគេបណ្តាច់ ហើយពួកគេបានបាញ់គំរាមនៅក្បែរព្រះកេសរបស់លោក។

**ថ្ងៃទី ៣១ ខែ កក្កដា** បព្វជិតនៃព្រះវិហារ សាំង ចច ត្រូវបានសម្លាប់ដោយបំណែកគ្រាប់នៅពេលដែលលោកបានវិលត្រលប់មកផ្ទះវិញបន្ទាប់ពីកិច្ចការក្នុងព្រះវិហារ។
**ថ្ងៃទី ៧ ខែសីហា** នៅព្រះវិហារ «ភាពទន់ភ្លន់នៃមាតាព្រះ»ក្នុងភូមិភាគឡូហានស្គ៍បានទទួលរងការបាញ់ផ្តក់ពីកាំភ្លើងធំដែលបណ្តាលអោយខូចខាតយ៉ាងធ្ងន់ធ្ងរ។
**ថ្ងៃទី ១០ ខែសីហា** ភ្នាក់ងារសារព័ត៌មានគ្រិស្តសាសនាបានអោយដឹងថា បព្វជិតនៃព្រះវិហារក្នុងភូមិ Gorlovka៦នាក់បានរងរបួសដោយការបាញ់ប្រហារ។
**ថ្ងៃទី ១៧ ខែ សីហា** Y. Bublik ប្រធានរងនៃគណបក្ស សេរីភាព បាននិយាយថា ការជ្រើសរើសសម្តេចសង្ឃOnuphrius ជាប្រមុខសាសនាអរថូដុកគឺប្រៀបដូចជាការបោះឆ្នោតជ្រើសយក យ៉ាណូកូវិចជាប្រធានាធិបតីឆ្នាំ ២០១០។
**ថ្ងៃទី ២០ ខែ សីហា** បព្វជិត Polinovskiy អនុប្រធានគណបក្ស សេរីភាពនៃក្រុង ម៉ាលីន (ភូមិភាគ Zhitomir)បានគាំទ្រគំនិតផ្តួចផ្តើមក្នុងការបិទព្រះវិហារ និង បញ្ជូនបព្វជិតទៅតុលាការក្រោមបទចោទថា «អំពាវនាវអោយបះបោរបំបែករដ្ឋ»។
**ថ្ងៃទី ២២ខែ សីហា** ពីធីបុណ្យដែលរំលឹកដល់ព្រះវិហារ Myrrhbearers ត្រូវបានគេធ្វើនៅខារកូវ។ អ្នកជាតិនិយមរ៉ាឌីកាល់ព្យាយាមរំខានដល់ការប្រារព្ធពីធី។
**ថ្ងៃទី ២៣ ខែ សីហា** គ្រាប់កាំភ្លើងមួយគ្រាប់បានធ្លាក់លើវិហារគ្រិស្តសាសនាសាំងចន នៅ Kronstadt នៃទីក្រុង Kirovskoe (ដូញៀតស្គ៍) នៅពេលថ្ងៃសៅរ៏ពេលយប់។ មនុស្សបីនាក់បានស្លាប់ និង ៦នាក់បានរងរបួស។
**ថ្ងៃទី ២៥ ខែសីហា** កងទ័ពអ៊ុយក្រែនបានបើកការវាយប្រហារបាញ់ផ្តក់មកលើព្រះវិហារ សាំង ចន ក្នុងភូមិTrudovskie បានរងការខូចខាតទាំងស្រុង។
**ថ្ងៃទី ២ (យប់)** អ្នកស្នេហាជាតិរ៉ាឌីកាល់បានវាយប្រហារមកលើបព្វជិតនៃព្រះវិហារ សាំង បាបារ៉ា។ អ្នកវាយប្រហារបានសំរុកចូលវាយតប់បព្វជិតដោយបានបំផ្លាញនូវវត្ថុដ៏ពិសិដ្ឋជាដើម។
**ថ្ងៃទី ៣ ខែ កញ្ញា** ព្រះវិហារនៅ Rovno បានធ្វើសេចក្តីប្រកាស៖ នៅពេលថ្មីៗ ក្រុមរ៉ាឌីកាល់ និង បព្វជិតមួយចំនួនដែលគេហៅថា សម្តេចសង្ឃក្រុងគៀវ បានប្រព្រឹត្តិនូវការឈ្លានពានយ៉ាងសាហាវឃោរឃៅនៅក្នុងបរិវេណព្រះវិហារ។
**ថ្ងៃទី ៧ ខែកញ្ញា** អ្នកដើរតាមសម្តេចសង្ឃក្រុងគៀវបានចាប់បព្វជិត៣អង្គ។
**ថ្ងៃទី ២៦ កញ្ញា** អង្គភាពរងនៃកងសន្តិសុខជាតិអ៊ុយក្រែនបានចាប់យករូបម្តាយព្រះ ដែលស្ថិតនៅក្បែរព្រលានយន្តហោះដូញៀតស្គ៍ ។
**ថ្ងៃទី ៣០ ខែ** កញ្ញា ប្រជាជនបានប្រទះឃើញសាកសពបុរសម្នាក់គេដាក់ចោលនៅលើរបងដែកព្រះវិហារPavlovo Pole ក្នុងភូមិភាគ Dzerzhinsk។
**ថ្ងៃទី ៥ ខែតុលា** នៅ Pereiaslav-Khmelnytskyi (ភូមិភាគគៀវ) មានការប៉ុនប៉ងចាប់បព្វជិត Boris និង Gleb។ជនអនាមិកនៅក្នុងសម្លៀកបំពាក់ប៉ារ៉ាដឹកនាំដោយសមាជិកក្រុមប្រឹក្សាក្រុងបានកាត់សោរ

ទ្វាររបស់ព្រះវិហារ។ ពួកគេមានភាពសាហាវយង់ឃ្នង ដោយបានគំរាមបណ្តេញចេញគ្រិស្តសាសនិកពីព្រះវិហារ និង បានដកយកកម្ពុជព្រះសង្ឃរាជពីព្រះកេសព្រះអង្គ Mikhnivich ។
**ថ្ងៃទី ១២ ខែតុលា** អ្នកតំណាងដែលគេស្គាល់ថា សង្ឃរាជក្រុងគៀវ និង កងកម្លាំងប្រដាប់ដោយអាវុធ បានប៉ុនប៉ង់ចាប់បព្វជិតក្នុងព្រះវិហារ ( Holy Trinity Church )ក្នុងភូមិ Povcha ក្នុងភូមិភាគ Rovno ។ នៅពេលដែលពួកគេចាប់បាន កងកម្លាំងទាំងនោះបានច្រានបព្វជិតទាំងអស់ទៅជ្រុងម្ខាងនៃព្រះវិហារដោយបង្ខំ។ អ្នកតំណាងឱ្យអាជ្ញាធរក៏បានចូលរួមក្នុងការវាយប្រហារនេះផងដែរ។ លោក V. Chaika និង លោក Kozak បានធ្វើសកម្មភាពបង្កទំនាស់ដោយបានញុះញង់អោយប្រជាជនចូលឆ្មក់តាមព្រះវិហារ។ ពួកសកម្មជនទាំងនោះបានវាយតប់បព្វជិតយ៉ាងផ្សៃព្រៃបំផុត។

**អ្នកផ្លាស់ទីលំនៅនិងជនភៀសខ្លួន**
**កាតិកាសញ្ញាពាក់ព័ន្ធនឹងឋានៈជនភៀសខ្លួន (ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៥១)**
**គោលការណ៍ណែនាំស្តីអំពីការបំលាស់ប្តូរទីកន្លែងខាងក្នុង (១៩៩៨)**
**គោលការណ៍ទី១**
**ក.** ជនផ្លាស់ទីក្នុងប្រទេសត្រូវទទួលបាននូវសេចក្តីរីករាយ គុណភាពពេញលេញ មានសិទ្ធិស្មើគ្នា ហើយសេរីភាពទទួលការការពារដោយច្បាប់អន្តរជាតិ និង ក្នុងស្រុក។ គ្មានការរើសអើងណាមួយចំពោះជនបំលាស់ទី។ រាល់គ្រប់ជនបំលាស់ទីមិនត្រូវបានទទួលការរើសអើងដែលធ្វើអោយប៉ះពាល់ដល់ការរីករាយនៃសិទ្ធិនិងសេរីភាព។
**គោលការណ៍ទី ២**
**ក.** អាជ្ញាធររដ្ឋត្រូវមានភារកិច្ចជាចំបងនិង ទំនួលខុសត្រូវខ្ពស់ក្នុងការផ្តល់នូវការការពារនិងជំនួយមនុស្សធម៌ដល់ជនផ្លាស់ទីលំនៅដោយស្ថិតក្នុងគតិយុត្តិ។
ខ. ជនផ្លាស់ទីលំនៅមានសិទ្ធិស្នើសុំទទួលការការពារនិងជំនួយមនុស្សធម៌ពីសំណាក់អាជ្ញាធរ។ ពួកគេតមិនត្រូវកាត់ទោសប្រហារជីវិតឬផ្តន្ទាទោសដោយសារសំណើនេះ។
គោលការណ៍ទី ៥
ជនផ្លាស់ប្តូរលំនៅ:
ក. សិទ្ធិក្នុងការទទួលសុវត្ថិភាពក្នុងផ្នែកដទៃទៀតក្នុងប្រទេស។
ខ.សិទ្ធិក្នុងការទទួលបានការចាកចេញពីប្រទេស
គ.សិទ្ធិក្នុងការស្វែងរកសិទ្ធិជ្រកកោននៅក្នុងប្រទេសផ្សេងៗ
ឃ. សិទ្ធិបានទទួលការការពារប្រឆាំងនឹងការបង្ខំអោយត្រលប់ទៅវិញ ឬ បង្ខំអោយតាំងទីលំនៅកន្លែងជីវិត សុវត្ថិភាព សេរីភាព និងសុខភាពស្ថិតក្នុងភាពគ្រោះថ្នាក់។

**ថ្ងៃទី ១៤ ខែ កក្កដា** លោក Konstantin Romodanovskiy ប្រធានភ្នាក់ងារអន្តោប្រវេសន៏សហព័ន្ធ

រុស្ស៊ីបាននិយាយថា មានជនជាតិអ៊ុយក្រែន ជាង ៣០០០០នាក់បានស្នើសុំឋានៈជាជនភៀសខ្លួន ហើយបណ្ដោះអាសន្នស្នាក់នៅក្នុងប្រទេសរុស្ស៊ី។ តាំងពីថ្ងៃដំបូងនៃការប្រយុទ្ធគ្នាមានប្រជាជនអ៊ុយក្រែ ជាង ១៣០០០០នាក់បានស្នើសុំក្នុងរយៈពេលវែងនៅលើដែនដីរុស្ស៊ី។

**ថ្ងៃទី១៥ខែកក្កដា** ជនភៀសខ្លួន ២៤ ៧២០នាក់ បានស្នាក់នៅក្នុងជំរំជនភៀសខ្លួនក្នុងប្រទេសរុស្ស៊ី។

**ថ្ងៃទី ១៧ ខែកក្កដា** លោក Konstantin Romodanovskiy បាននិយាយថា តាំងពីថ្ងៃទី ១ ខែមេសាថា ជនភៀសខ្លួនចំនួន ១៥១៧០០០នាក់ដែលបានមកដល់ទឹកដីរុស្ស៊ីពីអ៊ុយក្រែន។ ៣៣០ ០០០ នាក់ បានស្នើសុំអោយអាជ្ញាធររុស្ស៊ីដោះស្រាយ។

**ថ្ងៃទី ២១ ខែ កក្កដា** ក្រុមអង្គការអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្សបានទាមទារអោយប្រធានាធិបតីអ៊ុយក្រែនជានាអោយបាននូវប្រព័ន្ធកណ្តាលដែលគ្រប់គ្រងចំនួនពិតប្រាកដនៃជនផ្លាស់ប្តូរទីកន្លែង ហើយ និងការបង្កើតនូវស្នាក់ការសម្របសម្រួលដែលផ្តល់ដល់អ្នកទាំងនោះនូវជម្រក និង ជំនួយសង្គម។

**ថ្ងៃទី ២៧ ខែ កក្កដា** មានជនផ្លាស់ប្តូរទីកន្លែងជាង ២៣ន់នាក់មកពីភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែនត្រូវបានផ្តល់ទីជម្រកនៅភូមិភាគ Rostov ។ យោងតាមមជ្ឈមណ្ឌលសារព័តមាននៃក្រសួងការពារស៊ីវិលនៃសហព័ន្ធរុស្ស៊ី មានចំនួនជនភៀសខ្លួនសរុប ៤១ ៥៦២នាក់ ដែលក្នុងនោះ ១៣៣២១៥ ជាកុមារ ត្រូវបានផ្តល់ជម្រកនៅភូមិភាគ Rostov។

**ថ្ងៃទី ៣០ ខែ កក្កដា** ក្រសួងអន្តោប្រវេសន៍រុស្ស៊ីបានចេញផ្សាយនូវទិន្នន័យថ្មីអំពីប្រជាជនអ៊ុយក្រែនបានរត់គេចចេញពីប្រទេសរបស់គេ។ តាំងពីការចាប់ផ្តើមជម្លោះ មានប្រជាជនលើសពី ៧៣០ពាន់នាក់បានចាកចេញពីប្រទេសអ៊ុយក្រែន និង មកដល់ទឹកដីប្រទេសរុស្ស៊ី។

ថ្ងៃទី ៥ ខែ សីហា ទីភ្នាក់ងារជនភៀសខ្លួនអង្គការសហប្រជាជាតិបានប៉ាន់ស្មានថា មានប្រជាជន ១១៧ពាន់នាក់បានក្លាយជាអ្នកផ្លាស់ប្តូរទីជម្រកនៅក្នុងប្រទេស បន្ទាប់ពីការប្រយុទ្ធគ្នានៅភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែន។ លោក Vincent Cochetel អ្នកតំណាងការិយាល័យនៃឧត្តមក្រុមប្រឹក្សាអង្គការសហប្រជាជាតិដើម្បីជនភៀសខ្លួនបានគូសបញ្ជាក់ថា នៅក្នុងសប្តាហ៍កន្លងទៅមានអ្នកស្រុកប្រមាណ ៦.៣ពាន់នាក់ត្រូវបានបង្ខំអោយចាកចេញពីផ្ទះសម្បែងរបស់ពួកគេ។ ចំនួនជនផ្លាស់ប្តូរទីលំនៅពីឡូហានស្ក៍និង ដូញៀតស្ក៍បានកើនឡើងយ៉ាងគំហុក។ នៅដើមខែមិថុនា មានចំនួន ២.៦ ពាន់នាក់ ប្រៀបធៀប ១០២.៦ពាន់នាក់នៅដើមខែ សីហា។

សព្វថ្ងៃនេះ អ្នកស្រុកភាគខាងត្បូង-កើតអ៊ុយក្រែនមាន ៨៧ភាគរយដែលបានផ្លាស់ប្តូរទីជម្រកក្នុងប្រទេស។«កង្វះខាតក្នុងពេលបច្ចុប្បន្ននៃប្រព័ន្ធតែមួយបានផ្តល់ការលំបាកក្នុងការចាត់វិធានការណ៍ផ្តល់ជំនួយ។  ជម្រកដែលផ្តល់ដល់ជនភៀសខ្លួនមួយភាគធំមានអាចទប់ទល់អាកាសធាតុត្រជាក់ក្នុងខែរងារដែលនឹងមកដល់ក្នុងពេលប៉ុន្មានខែទៀតបាននោះទេ។

**ចាប់ពីថ្ងៃទី ១ មករា ដល់ថ្ងៃទី ១ខែសីហា** មានជនភៀសខ្លួនអ៊ុយក្រែនចំនួន 168,677 បានដាក់ពាក្យសុំមកក្រសួងអន្តោប្រវេសន៍រុស្ស៊ី ដែឡក្នុងនោះ ៦៣៤៧នាក់បានស្នើសុំក្នុងឋានៈជាជនភៀសខ្លួន ៤៨៩១៤នាក់ ស្នើសុំជម្រកបណ្តោះអាសន្ន និង ២៨ ១៣៤នាក់ សុំចូលសញ្ជាតិរុស្ស៊ី ៥៩ ៨៥៨នាក់

សុំការអនុញ្ញាតិរស់នៅបណ្តោះអាសន្នលើទឹកដីរុស្ស៊ី ១៩៩៤៣នាក់ សុំរស់នៅលើទឹកដីរុស្ស៊ី និង ៥៤៨១ ស្នើសុំចូលរួមក្នុងកម្មវិធីការផ្លាស់ប្តូរទីលំនៅរបស់បងប្អូនរួមជាតិ។
**ថ្ងៃទី ១ ខែ កញ្ញា** ការិយាល័យឧត្តមក្រុមប្រឹក្សាអង្គការសហប្រជាជាតិសើម្បីជនភៀសខ្លួនបានប៉ាន់ស្មានថាមានប្រជាជនចំនួន ២៦០ពាន់នាក់បានផ្លាស់ប្តូរទីលំនៅក្នុងប្រទេសអ៊ុយក្រែន។
**ថ្ងៃទី ១ ខែតុលា** លោក Konstantin Romodanovskiy ប្រមុខនៃក្រសួងអន្តោប្រវេសន៍រុស្ស៊ីបាននិយាយថាតាំងពីថ្ងៃដំបូងនៃជម្លោះនៅភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែនមានប្រជាជនអ៊ុយក្រែនជិត ២០០ពាន់នាក់បានស្នើសុំឋានៈជាជនភៀសខ្លួន ឬ ស្នើសុំជម្រកបណ្តោះអាសន្ន។ គាត់បានគូសបញ្ជាក់ថា ប្រជាជនប្រហែល ៨៨០ ពាន់នាក់បានចាកចេញពីភាគខាងត្បូង-កើតតាំងពីថ្ងៃទី ១ ខែមេសា ហើយពេលបច្ចុប្បន្នកំពុងស្នាក់នៅលើទឹកដីរុស្ស៊ី ជាង ១៩៥ ពាន់នាក់បានស្នើសុំឋានៈជាជនភៀសខ្លួន។ ចំណែក ១០០ពាន់នាក់ទៀតបានស្នើសុំការអនុញ្ញាតិរស់នៅជាបណ្តោះអាសន្ននៅប្រទេសរុស្ស៊ី។ យោងតាមទិន្នន័យរបស់ក្រសួងអន្តោប្រវេសន៍នៅថ្ងៃទី **២០ ខែ វិច្ឆិកា** មានជនជាតិអ៊ុយក្រែនសរុបដែលកំពុងស្នាក់នៅក្នុងប្រទេសរុស្ស៊ី ៨៣១ ០៨៥នាក់ ហើយ ៧៩៥ ជំរុំជនភៀសខ្លួនបណ្តោះអាសន្នដែលបានផ្តល់ជម្រកប្រជាជនចំនួន ៣៨ ៦៤៣នាក រួមមាន ១២ ០៤៦ ជាកុមារអាយុក្រោម ១៨ឆ្នាំ ។៤៤៤៤៤២នាក់ត្រូវបានផ្តល់ជម្រកដោយផ្នែកឯកជន ១១៥៦៧៦នាក់នៅតំបន់ព្រំដែនរុស្ស៊ី។ដើម្បីកំណត់ឋានៈតាមផ្លូវច្បាប់របស់ពួកគេ ៤៨៦ ២៣៣ ប្រជាជនអ៊ុយក្រែន រួមមាន ១១០ ៨៧០នាក់ នៅតាមតំបន់ព្រំដែន បានស្នើសុំមកក្រសួងអន្តោប្រវេសន៍រុស្ស៊ី ២៤៣១៤១ បានដាក់ពាក្យស្នើសុំជម្រកបណ្តោះអាសន្នលើទឹកដីរុស្ស៊ី និង ៥៧២១នាក់ បានស្នើសុំឋានៈជាជនភៀសខ្លួន។

**ការរំលោភលើសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌**
**សេចក្តីប្រកាសសិទ្ធិមនុស្សជាសកល (ថ្ងៃទី១០ខែធ្នូ ឆ្នាំ ១៩៤៨)**
**មាត្រាទី ១៧**
ក. មនុស្សគ្រប់រូបមានសិទ្ធិមានកម្មសិទ្ធជាឯកជន ឬ រួមជាមួយអ្នកដទៃទៀត។
ខ. គ្មានជនណាម្នាក់អាចត្រូវបានគេដកហូតយកសិទ្ធិនេះបានឡើយ។
**មាត្រាទី ២២**
មនុស្សគ្រប់រូប ជាសមាជិករបស់សង្គម មានសិទ្ធិទទួលបានសន្តិសុខសង្គម និង ត្រូវបានធ្វើអោយសម្រេចតាមរយៈកិច្ចខិតខំប្រឹងប្រែងជាតិ និង កិច្ចសហប្រតិបត្តិការអន្តរជាតិ ហើយដោយអនុលោមទៅនឹងការរៀបចំ និង ធនធានរបស់រដ្ឋនីមួយៗនៃសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និង វប្បធម៌ ដែលមានសារសំខាន់បំផុតសម្រាប់ភាពថ្លៃថ្នូរ និង ការអភិវឌ្ឍន៍របស់បុគ្គល។
**មាត្រាទី ២៦**
មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ។
**មាត្រាទី ២៧**

ក. មនុស្សគ្រប់រូបមានសិទ្ធិចូលរួមដោយសេរីក្នុងជីវិតវប្បធម៌របស់សហគមន៍ រីករាយសិល្បៈ និង ចែករំលែក
នៃភាពជឿនលឿនផ្នែកវិទ្យាសាស្ត្រ និង ផលប្រយោជន៍។

**កាតិកាអន្តរជាតិស្តីអំពី សិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និង វប្បធម៌ ( ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦)**

**មាត្រាទី ១១**

ក.រដ្ឋភាគីដែលបានចុះហត្ថលេខាកាតិកាអន្តរជាតិនេះទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបដើម្បីទទួលបានកម្រិតនៃការរស់នៅមានភាពសមរម្យ សម្រាប់ខ្លួនគាត់ និង គ្រួសារ រួមមាន ភាពសមរម្យផ្នែកចំណីអាហារ សម្លៀកបំពាក់ និង ផ្ទះសម្បែង ហើយអាចបន្តធ្វើអោយប្រសើរបន្ថែមទៀតនៅលក្ខខណ្ឌក្នុងការរស់នៅ។ រដ្ឋភាគី នឹងចាត់វិធីការដ៏សមរម្យក្នុងការធានាអោយបានការធ្វើអោយសម្រេចនៃសិទ្ធិនេះ ដោយការទទួលស្គាល់នូវសារសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិដោយឈរនៅលើមនសិការសេរី។

ខ. រដ្ឋភាគីក្នុងកាតិកាសញ្ញានេះ បានទទួលស្គាល់សិទ្ធិជាមូលដ្ឋាននៃមនុស្សគ្រប់រូបរួចផុតពីសេចក្តីស្រេកឃ្លាន ដោយចាត់វិធានការជាបុគ្គលផ្ទាល់ខ្លួនឬ តាមរយៈកិច្ចសហប្រតិបត្តិការណ៏អន្តរជាតិ រួមទាំងកម្មវិធីជាក់លាក់ណាមួយ។

**មាត្រាទី ១២**

ក. រដ្ឋភាគីក្នុងកាតិកាសញ្ញានេះទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបទទួលបានសេចក្តីសប្បាយរីករាយទាំងផ្លូវកាយ និង ចិត្តក្នុងកំរិតខ្ពស់បំផុត។

**មាត្រាទី ១៣** រដ្ឋភាគីនៃកាតិកាសញ្ញានេះទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបានការអប់រំ។ពួកគេយល់ព្រមថា ការអប់រំគឺជាមធ្យោបាយដែលនាំអោយមានការអភិវឌ្ឍន៏យ៉ាងពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និង ភាពថ្លៃថ្នូរ ព្រមទាំងពង្រឹងនូវការគោរពសិទ្ធិមនុស្ស និង មូលដ្ឋានសេរីភាពជាមូលដ្ឋាន។

**មាត្រាទី១៥**

រដ្ឋភាគីទទួលស្គាល់សិទ្ធិនៃមនុស្សគ្រប់រូបៈ
ក. ចូលរួមក្នុងជីវិតវប្បធម៌។

**ពិធីការបន្ថែមលេខ១ ពាក់ព័ន្ធនឹងកាតិកាសញ្ញាដើម្បីការការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន (ក្រុង ប៉ារីស៏ ថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៥២)**

**មាត្រាទី១ ការការពារទ្រព្យសម្បត្តិ**

មនុស្សគ្រប់រូបត្រូវទទួលបានសេរីភាពក្នុងការមានកម្មសិទ្ធិរបស់ខ្លួន។ គ្មានបុគ្គលណាម្នាក់អាចដកហូតយកកម្មសិទ្ធិរបស់បុគ្គលនីមួយៗបានឡើយ លើកលែងក្នុងករណីផលប្រយោជន៏សាធារណៈ និង ជាកម្មវត្ថុនៃលក្ខខណ្ឌដែលផ្តល់ដោយច្បាប់ និង គោលការណ៏ទូទៅនៃច្បាប់អន្តរជាតិ។

**មាត្រាទី ២ សិទ្ធិទទួលបានការអប់រំ**
គ្មានជនណាម្នាក់ត្រូវបានគេបដិសេធសិទ្ធិទទួលបានការអប់រំឡើយ។ ក្នុងការប្រតិបត្តិនៃតួនាទីទាក់ទងទៅនឹងការអប់រំ និង ការបង្រៀន រដ្ឋត្រូវគោរពសិទ្ធិរបស់ឳពុកម្តាយដោយធានាយ៉ាងណាអោយការអប់រំនិង ការបង្រៀននោះ សមស្របទៅនឹងជំនឿសាសនា និង ទស្សនវិជ្ជារបស់ពួកគេ។

**ពិធីសារបន្ថែមពាក់ព័ន្ធនឹងកាតិកាសញ្ញាហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៥៩ និង ពាក់ព័ន្ធនឹងការការពារជនរងគ្រោះក្នុងជម្លោះមិនមែនអន្តរជាតិ (ពិធីសារ២ ហ្សឺណែវ ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧**

**មាត្រាទី ១៤ ការការពារនៃកម្មវត្ថុដែលមានសារសំខាន់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋស៊ីវិល**
យុទ្ធសាស្ត្រ ធ្វើអោយជនស៊ីវិលអត់ឃ្លាន ត្រូវបានហាមឃាត់។ ហេតុដូចនេះហើយទង្វើនៃការវាយប្រហារការបំផ្លាញ ការផ្លាស់ប្តូរ ឬ ធ្វើអោយក្លាយជារបស់មិនមានប្រយោជន៏រាល់សម្ភារៈទាំងឡាយណាដែលមានសារសំខាន់ដល់ការរស់នៅរបស់ប្រជាជនស៊ីវិលដូចជា ឃ្លាំងស្បៀង តំបន់កសិកម្មសម្រាប់ការផលិតអាហារគ្រាប់ធញ្ញជាតិ ទឹកស្អាត និង គ្រឿងផ្គត់ផ្គង់នានាជាដើម។
**មាត្រាទី ១៦** ការការពារកម្មវត្ថុវប្បធម៌ និង ទីកន្លែងសក្ការបូជាដោយការអនុលោមទៅនឹងកាតិកាសញ្ញាទីក្រុងឡាអេស្តីអំពីការការពារនៃសម្បត្តិវប្បធម៌ ក្នុងជម្លោះប្រដាប់អាវុធ នៅថ្ងៃទី១៤ ខែ ឧសភា ឆ្នាំ១៩៥៤ ហាមដាច់ខាតការប្រព្រឹត្តសកម្មភាពណាមួយដែលប៉ះទង្គិចដល់
វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈនានា ឬ កន្លែងសក្ការបូជាដែលតំណាងអោយកេរមរតកវប្បធម៌ឬដួងព្រលឹងរបស់ប្រជាជន និង ការប្រើប្រាស់កម្មវត្ថុខាងលើដើម្បីគាំទ្រក្នុងសកម្មភាពយោធាឡើយ។
**ថ្ងៃទី ១ ខែ កក្កដា** ការប្រយុទ្ធគ្នាបានបណ្តាលអោយដាច់ចរន្តអគ្គិសនីនៅក្នុងតំបន់ ស្លាវែគ (ភូមិភាគដូញៀត)កន្លែងសំខាន់ៗជាច្រើនដូចជាមន្ទីរសម្ភព និង មន្ទីរពេទ្យវះកាត់ក្នុងក្រុងត្រូវបានផ្អាកដំណើរការដោយសារការដាច់ចរន្តអគ្គិសនី។
**ថ្ងៃទី១ ខែកក្កដា** នៅឡូហានស្ក៏ គ្រាប់បានធ្លាក់ចំសាលារៀនលេខ ១៤ និង ៣៥ បណ្តាលអោយខូចខាតផ្ទះសម្បែងជាច្រើនខ្នង។
**ថ្ងៃទី ២ ខែ កក្កដា** ដោយសារការបាញ់ផ្គក់ពីសំណាក់កងទ័ពអ៊ុយក្រែន  ប្រព័ន្ធបង្ហូរលូ និង ស្ថានីយ៍បូមទឹកត្រូវបានបញ្ឈប់ដំណើរការ។
**ថ្ងៃទី ៣ ខែ កក្កដា** នៅ Slavyansk ការបាញ់ផ្គក់ដោយកងកម្លាំងអ៊ុយក្រែនបានបណ្តាលអោយមានការខូចខាតស្ថានីយ៍ផលិតអគ្គិសនីៈ ម៉ាស៊ីនបំលែងចំនួនពីរ អគារសំខាន់នៃស្ថានីយ៍ផលិតអគ្គិសនីធុងប្រេងចំហេះ ដែលមានសមត្ថភាពផ្ទុកបាន ២០០០តោនត្រូវបានបំផ្លិចបំផ្លាញ។ ក្នុងនោះផងដែរមានការហៀរប្រេងចេញផងដែរ។
**ថ្ងៃទី ៣ ខែ កក្កដា** នៅភូមិ នីកូឡាយ៉េវ បំពង់កំដៅ និង រោងចក្រផលិតអគ្គីសនីត្រូវបានបំផ្លាញដោយសារការបាញ់ផ្គក់នៃកាំភ្លើងធំដោយកងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ៣ ខែ កក្កដា** នៅ Kramatorsk ដោយសារការបន្តបាញ់ផ្លូក់ពីកងទ័ពអ៊ុយក្រែន មន្ទីរពេទ្យព្យាបាលជំងឺបានជួបប្រទះនឹងការខ្វះខាតថ្នាំសង្កូវ។ក្រុមប្រឹក្សាទីក្រុងគឺជាគោលសំខាន់ក្នុងការទម្លាក់គ្រាប់បែក។ ខ្សែបណ្តាញអគ្គិសនី និង ផ្លូវរថភ្លើងត្រូវបានបំផ្លាញ។
**ថ្ងៃទី ៤ ខែ កក្កដា** នៅភូមិភាគឡូហានស្គ៍ ស្ពានមួយកន្លែងឆ្លងកាត់ទន្លេដូញៀតស្គ៍ត្រូវបានបាក់។
**ថ្ងៃទី ៥ ខែកក្កដា** នៅដូញៀតគ៏ ការខ្វះខាតទឹកត្រូវបានអាជ្ញាធរប្រកាស។
**ថ្ងៃទី ៧ ខែកក្កដា** នៅឡូហានស្គ៍ និង ដូញៀតស្គ៍ ស្ពានចំនួនបីត្រូវបានគេបំផ្លាញ។
នៅភូមិភាគឡូហានស្គ៍ ស្ពានផ្លូវដែកកាត់ទន្លេ ទេប្លាយ៉ាត្រូវបានបំបាក់។ ផ្លូវដែកជាង ១០០ម៉ែត្រ និង ស្ពាន ២៥ម៉ែត្រត្រូវបានគេកំទេច។នៅដូញៀតស្គ៍ ស្ពានឆ្លងកាត់ Seversky ទន្លេដូញៀតស្គ៍ ត្រូវបានកាត់ផ្តាច់។
**ថ្ងៃទី ៨ ខែ កក្កដា** កងទ័ពអាកាសអ៊ុយក្រែនបានបើកការវាយប្រហារមកលើតំបន់ជាយក្រុងដូញៀតស្គ៍។ កងទ័ពអ៊ុយក្រែនបានទម្លាក់គ្រាប់បែកទៅលើសង្កាត់ Petrovsky ហើយគ្រាប់បែកមួយចំនួនបានធ្លាក់ទៅលើអណ្តូងរ៉ែលេខ ៤-២១។
**ថ្ងៃទី ៨ ខែ កក្កដា** នៅទីប្រជុំជន Belozerka ជនអនាមិកពាក់ម៉ាស បានវាយផ្តួលរំលំរូបសំណាកឡេនីន។
**ថ្ងៃទី ៩ ខែកក្កដា** នៅឡូហាន លទ្ធផលនៃការប្រយុទ្ធគ្នា បំពង់បង្ហូរឧស្ម័នចំនួន ៦២ ត្រូវបានបំផ្លាញ។ គ្រួសារជិត ១០០០០ ត្រូវរស់នៅដោយគ្មានឧស្ម័នប្រើប្រាស់។
**ថ្ងៃទី ៩ ខែ កក្កដា** រូបតាំងចំនួន ៦៤ ដែលគិតជាប្រាក់ចំនួន ១៨៥០០០ដុល្លារត្រូវបានគេលួចចេញពីសារមន្ទីរប្រវត្តិសាស្ត្រគៀវ។ បន្ទាប់រដ្ឋប្រហារខែកុម្ភៈ ឆ្នាំ ២០១៤ អគារនេះត្រូវបានកាន់កាប់ដោយសកម្មជនម៉ៃដាន់។
**ថ្ងៃទី ១០ ខែ កក្កដា** ដោយសារការបាញ់ផ្លូក់គ្រាប់កាំភ្លើងធំដោយទាហានអ៊ុយក្រែន ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកនៅក្នុងក្រុង Severodonetsk រងការខូចខាតយ៉ាងដំណំ។ ស្ថានីយ៍ផលិតអគ្គិសនីដែលមានកម្លាំងតង់ស្យុងខ្ពស់ត្រូវបានផ្អាកដំណើរការទាំងស្រុង។
**ថ្ងៃ១០ ខែ កក្កដា** នៅឡូហានស្គ៍ ការប្រយុទ្ធគ្នាបានបង្កអោយមានការខូចខាតយ៉ាងដំណំ។ អគ្គិសនីត្រូវបានកាត់ផ្តាច់ ប្រព័ន្ធផ្គត់ផ្គង់ទឹកត្រូវបានខូចខាតដែលមានអ្នកស្រុករស់នៅជាង ៥២០នាក់។
**ថ្ងៃទី ១៤ ខែ កក្កដា** នៅសង្កាត់ Youzhny ក្នុងភូមិភាគ ឡូហានស្គ៍ ជាលទ្ធផលនៃការទម្លាក់គ្រាប់បែកបង្កឡើងដោយទាហានអ៊ុយក្រែន សាលារៀនលេខ ៥១ មត្តេយ្យលេខ ៥៣ និង អគារលេខ ៥ និង ៦ រងការខូចខាតដោយផ្នែក។ នៅសង្កាត់ Mirny គ្រាប់បានធ្លាក់ចំអគារលេខ ៨ ហើយអគារផ្សេងមួយទៀតដែលបានបណ្តាលអោយមានអគ្គីភ័យឆាបឆេះចេះពីជាន់ទីមួយនៃអគារ ១៣អា។ នៅក្នុងទីប្រជុំជន Telman ស្ថានីយ៍ផលិតអគ្គិសនីតង់ស្យុងខ្ពស់ត្រូវបានបំផ្លាញដោយគ្រាប់កាំភ្លើង។
នៅសង្កាត់ Artyomovsky និង Kamennobrodsky អគ្គីសនីត្រូវបានកាត់ផ្តាច់ពីលំនៅដ្ឋាន ដែលមានមនុស្សរស់នៅចំនួន ៤៧៥០នាក់។ ប្រព័ន្ធទឹកស្អាតត្រូវបានកាត់ផ្តាច់ពីផ្នែកខាងត្បូងនៃសង្កាត់ ចំណែកឧស្ម័នត្រូវបានកាត់ផ្តាច់ពី Yekaterinovka និង Aleksandrovka។

**ថ្ងៃទី ១៤ ខែ កក្កដា** នៅភូមិភាគដូញៀតស្ក៍ ស្ពានពីរបានបាក់ចូលក្នុងទន្លេ។ ស្ពានទី១ស្ថិតនៅជិត ទីក្រុង Zuhres និង មួយទៀតស្ថិតនៅជិតទីប្រជុំជន Maryanovka។
**ថ្ងៃទី ១៥ ខែកក្កដា** នៅ Snezhny ភូមិភាគដូញៀតស្ក៍ ដោយសារការបាញ់ផ្លោក់គ្រាប់បានបំផ្លាញរោងចក្រផលិតនំប័ងមួយកន្លែងទាំងស្រុង។
**ថ្ងៃទី ១៦ ខែកក្កដា** នៅភូមិភាគដូញៀតស្ក៍ ការប្រយុទ្ធគ្នាបានប៉ះពាល់ដល់ស្ថានីយ៍ចម្រុះទឹក ដែលបានធ្វើអោយផ្នែកមួយចំនួននៅភាគខាងលិច និង ខាងត្បូងមានដូចជាសង្កាត់ Dimitrov, Dobropolye និង Dobropolye, Krasnoarmeysk និង Krasnoarmeysk, Novogrodovka, Selidovo, Ugledar, និង ទីប្រជុំជន Aleksandrovsk និង Volnovakha ពុំមានទឹកប្រើប្រាស់គ្រប់គ្រាន់អស់រយៈពេល ៥ថ្ងៃ។ ទន្ទឹមនឹងការដាច់ប្រព័ន្ធទឹក អាកាសធាតុមានសីតុណ្ហភាពក្តៅហួតហែង។ មនុស្សត្រូវបរិភោគទឹកបច្ចេកទេស។នៅក្នុងទីក្រុង Belitskoye នៃភូមិភាគដូញៀតស្ក៍ មន្ទីរពេទ្យសម្រាប់មនុស្សចាស់ ដែលមានអ្នកជំងឺជាង ១០០នាក់បានជួបកង្វះខាតយ៉ាងខ្លាំង។
**ថ្ងៃទី ១៧ ខែ កក្កដា** នៅដូញៀតស្ក៍ ជាលទ្ធផលនៃការបាញ់ផ្លោក់ដោយកាំភ្លើងធំរបស់កងទ័ពអ៊ុយក្រែន សាលាមត្តេយ្យ លេខ ៩៤ ត្រូវបានបំផ្លាញដោយផ្នែក។
**ថ្ងៃទី ១៨ ខែ កក្កដា** នៅឡូហានស្ក៍ គ្រាប់កាំភ្លើងធំរបស់កងទ័ពអ៊ុយក្រែនបានធ្លាក់ចំសាលាមត្តេយ្យលេខ ១៣៤។ ដំបូល និង កំរាលឥដ្ឋត្រូវបានបំផ្លិចបំផ្លាញ។ យោងតាមការិយាល័យក្រុមប្រឹក្សាក្រុងឡូហានស្ក៍ទទួលបន្ទុកការអប់រំនិងយុវជន ស្ថាប័នចំនួន ១៤ ត្រូវបានបំផ្លាញជាលទ្ធផលនៃការបាញ់ផ្លោងកាំភ្លើងធំតាំងពីការចាប់ផ្តើមការប្រយុទ្ធគ្នា។
**ថ្ងៃទី ១៨ ខែ កក្កដា** នៅឡូហានស្ក៍ ជាលទ្ធផលនៃការបាញ់ផ្លោក់ពីកងទ័ពអ៊ុយក្រែន អគ្គិសនីត្រូវបានកាត់ផ្តាច់បណ្តាញចែកចាយដែលបណ្តាលអោយរាំងស្ទះដល់ដំណើរការកន្លែងរុករករ៉ែ Krasny Partizan និង Dolzhanskaya-Kapitalnaya។
**ថ្ងៃទី ១៨-១៩ (យប់)** នៅអូដេសា បុគ្គលិកនៃក្រុមហ៊ុនម្នាក់ដែលគាំទ្រដោយសកម្មជនម៉ែដាន់បានបំផ្លាញទីកន្លែងរំលឹកវិញ្ញាណក្ខន្ធ័សោកនាដកម្មដែលបានកើតឡើងនៅអគារសហជីពពាណិជ្ជកម្មនៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤ (នៅថ្ងៃនោះ មនុស្សចំនួន ៤៨នាក់បានស្លាប់ និង ២០០នាក់បានរងរបួស)។
**ថ្ងៃទី ១៩ ខែ កក្កដា** នៅឡូហាន ជាលទ្ធផលនៃការបន្តបាញ់ផ្លោក់ អគារខ្ពស់មួយ ផ្ទះប្រជាពលរដ្ឋចំនួន ១៧ និង ស្ថាប័នចំនួន ៦ ក្នុងនោះ សាលារៀនលេខ ២ និង លេខ ២៩ សាលាសាសនាអរថូដុក និង មជ្ឈមណ្ឌលថែរក្សាសម្រស់ត្រូវបានរងការខូចខាតយ៉ាងដំណំ។
**ថ្ងៃទី ២១ ខែ កក្កដា** កងកម្លាំងអ៊ុយក្រែនបានបើកការវាយប្រហារប្រឆាំងនឹងដូញៀតស្ក៍ដោយប្រើប្រាស់អាវុធធុនធ្ងន់ និង រថក្រោះ ដោយបានបំផ្លិចបំផ្លាញផ្ទះសម្បែង និង អគារអស់ចំនួន ជាង ២០ ហើយបានបង្កើតនូវអគ្គីភ័យនៅក្រុមហ៊ុន Tochmash។ សកម្មភាពចរាចរណ៍ក្នុងក្រុងត្រូវបានបិទ ទូរស័ព្ទចល័ត ទូរទស្សន៍ និង អ៊ីនធឺណេតមានភាពអាក់រអួលមិនដំណើរការ។ ប្រព័ន្ធដឹកជញ្ជូនសាធារណៈនិង ហាងទំនិញនានាត្រូវបានបិទ។

ការផ្គត់ផ្គង់ចំណីអាហារ និង ថ្នាំពេទ្យពីអ៊ុយក្រែនត្រូវបានផ្អាកទាំងស្រុង។ ការផ្គត់ផ្គង់ទឹកបានចោទជាបញ្ហាយ៉ាងខ្លាំង។ ទឹកប្រើប្រាស់មានចាប់ពីម៉ោង ៥ល្ងាច ដល់ម៉ោង ១០ល្ងាច។ កង្វះខាតនេះកើតឡើងដោយសារស្ថានីយ៍ចំនួន ៣ ត្រូវបានបំផ្លាញដោយសារការបាញ់កាំភ្លើងធ្លោងរបស់កងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ២១ ក្នុងឡូហានស្ក៏** ជាលទ្ធផលនៃការបាញ់ផ្តក់ដោយកងទ័ពអ៊ុយក្រែន ខ្សែភ្លើងតភ្ជាប់ទៅរថយន្តក្រុងនិង ត្រាំ ត្រូវបានខូចខាតយ៉ាងដំណំ។ ការធ្វើដំណើរដោយយានអគ្គិសនីនៅក្នុងក្រុងត្រូវបានផ្អាក។

**ថ្ងៃទី ២១ ខែកក្កដា** ក្នុងភូមិ Orlovka (ដូញៀតស្ក៏) កងទ័ពដែលមកពីកងអាសាស្ម័គ្រអ៊ុយក្រែនបានផ្តួលរូបសំណាកឡេនីន។

**ថ្ងៃទី ២២ ខែ កក្កដា** លោក K. Vittrup អ្នកតំណាង ពិសេស OSCEទទួលបន្ទុកអង្កេតការណ៏នៅក្នុងប្រទេសអ៊ុយក្រែន កំពុងធ្វើការជាមួយនឹងសហការីរបស់លោក បន្ទាប់ពីបានឃើញលទ្ធផលនៃការទម្លាក់គ្រាប់បែកនិងការបាញ់ផ្លោងដោយកងទ័ពអ៊ុយក្រែនបានលើកឡើងថា « ពីរ បីថ្ងៃចុងក្រោយនេះខ្ញុំបានកត់សំគាល់ឃើញថា គ្រាប់បានធ្លាក់ចំគោលដៅស៊ីវិលទាំងស្រុង ដូចជា ផ្ទះសម្បែងរបស់ប្រជាជន រោងចក្រ ផ្ទះល្វែងជាដើម។ អ្នកស្រុកមិនបានធ្វើអ្វីទាំងអស់ ពួកគាត់គ្រាន់តែរស់នៅទីនេះប៉ុននោះ»។

**ថ្ងៃទី ៥ ខែកញ្ញា** កងកម្លាំងអ៊ុយក្រែនបានបាញ់ផ្លោងគ្រាប់រ៉ុក្កែតក្នុងទ្រង់ទ្រាយធំវាយប្រហារមកលើតំបន់ទីប្រជុំជននានាក្នុងភូមិភាគដូញៀតស្ក៏ ដោយបានបំផ្លាញសាលារៀន និង សាលាមត្តេយ្យ រួមទាំងផ្ទះសម្បែងជាច្រើនខ្នងទៀត។

**ថ្ងៃទី ៦ ខែកញ្ញា** គណកម្មាធិការកាកបាទក្រហមមិនអាចចែកចាយជំនួយមនុស្សធម៌នៅក្នុងភូមិភាគឡូហានស្ក៏បានឡើយដោយសារការបន្តបាញ់ផ្តក់ដែលធ្វើឡើងដោយកងទ័ពអ៊ុយក្រែន។

**ថ្ងៃទី ៨ ខែកញ្ញា** អង្គការសហប្រជាជាតិបានគូសបញ្ជាក់ថា សាលារៀនប្រហែល ២៩០ខ្នងត្រូវបានបំផ្លាញឬខូចខ្ទេចខ្ទីនៅក្នុងភូមិភាគ ឡូហានស្ក៏ និង ដូញៀតស្ក៏។

**ថ្ងៃទី ៩ ខែកញ្ញា** កងទ័ពអ៊ុយក្រែនបានបើកការបាញ់ប្រហារភូមិភាគ ដូញៀតស្ក៏ ដោយបានបំផ្លាញផ្លូវរថភ្លើងនៅក្បែរសង្កាត់ Avdeevka។

**ថ្ងៃទី ១២ ខែ កញ្ញា** នៅខារកូវ ជនអនាមិកមួយក្រុមបានវាយផ្តួលរូបសំណាកឡេនីន។

**ថ្ងៃទី ១៦ ខែ កញ្ញា** យោងតាមរបាយការណ៏អង្គការសហប្រជាជាតិ សហគ្រាសចំនួន39,985(តូចនិងមធ្យម)ត្រូវបានបិទមិនដំណើរការនៅដូញៀតស្ក៏ និង ឡូហានស្ក៏។ ការបិទនេះបានបណ្តាលអោយប៉ះពាល់សហគ្រិនចំនួន ៥៤ភាគរយក្នុងតំបន់ និង នយោជិកបាត់បង់ការងារ។ ពេលបច្ចុប្បន្នមានជនអត់ការងារធ្វើចំនួន ៣០០០០នាក់ ក្នុងភូមិភាគដូញៀតស្ក៏។

**ថ្ងៃទី ១៦ ខែ កញ្ញា** តាមរបាយការណ៏អង្គការសហប្រជាជាតិបានអោយដឹងថា រហូតមកដល់ថ្ងៃទី ១ ខែ កញ្ញាឆ្នាំ ២០១៤នេះ មានសាលារៀនចំនួន ៥៤៧ ក្នុងចំណោម ១០៩១ នៅភូមិភាគដូញៀតស្ក៏ និង ២៥០ ក្នុងចំនោម ៦៩០ ក្នុងភូមិភាគឡូហានស្ក៏ អាចបើកបវេសនកាលឆ្នាំសិក្សាថ្មីបានដោយ

អនុញ្ញាតអោយកុមារចំនួន១៩៦៣០០នាក់ចូលរៀន។ សាលារៀនចំនួន ៩៨៤ខ្នងផ្សេងទៀតមិនទាន់អាចបើកដំណើរការដូចធម្មតាវិញបានដោយសារការខូចខាតយ៉ាងធ្ងន់ធ្ងរ និង ការការពារសុវត្ថិភាពរបស់កុមារ។ អាស្រ័យដូចនេះហើយមានកុមារចំនួន ២៧០ ០០០នាក់ បានបាត់បង់ការសិក្សារបស់ខ្លួន។ លើសពីនេះទៀត យោងតាមព័ត៌មានដែលចេញផ្សាយដោយអង្គការសហប្រជាជាតិ ស្ថាប័នសុខាភិបាលចំនួន ៣២ ត្រូវបានបិទមិនដំណើរការ ហើយ ៤៥ ខ្នងបានទទួលរងការខូចខាត ឬបំផ្លាញនៅក្រុងដូញៀតស្ក៍។

**ថ្ងៃទី ១៧ ខែកញ្ញា** នៅឡូហានស្ក៍ ស្ថានីយ៍ផ្គត់ផ្គង់ចរន្តអគ្គិសនីនៅ Schastye បានផ្អាកមិនអាចដំណើរការបានដោយសារការខូចខាតពីគ្រាប់ផ្លោងរបស់កងទ័ពអ៊ុយក្រែន។ ទីប្រជុំជននៅភាគខាងត្បូងឡូហានស្ក៍គ្មានអគ្គិសនីប្រើប្រាស់។

**ថ្ងៃទី ២០ ខែកញ្ញា** កងកម្លាំងអាសាស្ម័គ្រ « Aidar» បានប្លន់ជំនួយមនុស្សធម៌អ៊ុយក្រែនដែលធ្វើដំណើរទៅកាន់ភូមិភាគឡូហានស្ក៍។ ក្រុម « Aidar» បានបញ្ឈប់រថយន្តដែលផ្ទុកដោយជំនួយមនុស្សធម៌ និង បានរឹបអូសយកសាច់កំប៉ុងអស់ជាច្រើន។ ពួកគេសំអាងលើហេតុផលថា មិនបានទទួលការផ្គត់ផ្គង់ពីក្រុងគៀវបានគ្រប់គ្រាន់ ហើយអះអាងថា ជំនួយអាហារទាំងអស់នេះនឹងអាចធ្លាក់ក្នុងដៃក្រុមភេរវករ។

## សេចក្តីសន្និដ្ឋាន

សៀវភៅស នេះត្រូវបានបោះពុម្ពឡើងគឺជាភស្តុតាងដែលបង្ហាញថា កងទ័ពអ៊ុយក្រែនបានប្រតិបត្តិការនៅជិត Donbass  បាញ់ផ្តក់មកលើទីកន្លែងដែលមានប្រជាជនរស់នៅច្រើនកុះករ ក្នុងភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែន និង ការបាញ់គ្នាទៅវិញទៅមករវាងសន្តិសុខជាតិអ៊ុយក្រែន ជាមួយនឹងក្រុមជីវពលកំពុងបន្ត ។ ដូចឃើញហើយថា កិច្ចព្រមព្រៀងឈប់បាញ់ដែលបានចុះហត្ថលេខានៅទីក្រុងមីនស្ក៏នៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៤ មិនត្រូវបានគោរពអោយបានខ្ជាប់ខ្ជួននោះឡើយ។

ការរំលោភសិទ្ធិមនុស្សត្រូវបានប្រព្រឹត្តឡើងដោយភាគីទាំងពីរនៃជម្លោះ។ ទោះបីជាយ៉ាងណា គេមិនអាចបំភ្លេចចោលនូវការពិតដែលបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅភាគខាងត្បូង-កើតនៃប្រទេសអ៊ុយក្រែនជាពិសេសការប្រើប្រាស់កងទ័ពមិនមានតុល្យភាព ការប្រើប្រាស់អាវុធដែលមានគ្រោះខ្លាំងខ្លាំង រួមមានអាវុធហាមឃាត់ដែលប្រើប្រាស់ដោយកងទ័ពអ៊ុយក្រែន និង កងកម្លាំងអ្នកជាតិនិយមរ៉ាឌីកាល់។

ពួកគេនៅតែបន្តការទម្លាក់គ្រាប់បែកទៅលើតំបន់ដែលមានមនុស្សរស់នៅកុះករក្នុង Donbass។

ទីតាំងនិង ជំហរជាគោលការណ៏របស់ប្រទេសរុស្ស៊ីនៅតែមិនមានការផ្លាស់ប្តូរ យើងគាំទ្រអោយមានការប្រកាន់អោយបានខ្ជាប់ខ្ជួននូវកិច្ចព្រមព្រៀងទីក្រុងមីនស្ក៏ដោយភាគីជម្លោះទាំងពីរ។ វាដល់ពេលហើយសំរាប់ក្រុងគៀវ ដើម្បីបញ្ចប់នូវការប៉ះប៉ងដើម្បីដោះស្រាយបញ្ហាដែលពាក់ព័ន្ធជាមួយភាគខាងត្បូង-កើតនៃប្រទេសដោយការប្រើប្រាស់ រថក្រោះ កាំភ្លើង និង មធ្យោបាយយោធាដទៃទៀត បញ្ឈប់នូវអំពើហិង្សានិង បើកការចចារជាមួយអ្នកតំណាងនៅដូញៀតស្ក៏ និង ឡូហានស្ក៏។ មិនមានផ្លូវណាក្រៅពីនេះនោះទេដោយពុំមានការសម្រេចចិត្តអនុវត្តនូវការចចារនេះទេ ការសន្ទនារវាងមេដឹកនាំអ៊ុយក្រែនជាមួយអ្នកដឹកនាំបរទេសអំពីការកសាងលទ្ធិប្រជាធិបតេយ្យគឺនៅតែមិនមានពន្លឺ។

សហគមន៏អន្តរជាតិគួរដាក់សម្ពាធលើអាជ្ញាធរអ៊ុយក្រែនដើម្បីធានាថា ពួកគេចាត់វិធានការពិតប្រាកដប្រកបដោយប្រសិទ្ធិភាពជាមួយគតិយុត្តិរបស់ពួកគេដើម្បីបំពេញនូវកាតព្វកិច្ចផ្នែកសិទ្ធិមនុស្ស រួមបញ្ចូលនូវសិទ្ធិរស់រានមានជីវិតជាមូលដ្ឋាន ការហាមឃាត់ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ ការបន្ទាបបន្ថោក សេរីភាពបញ្ចេញមតិ និង ប្រព័ន្ធផ្សព្វផ្សាយ ការជួបប្រជុំ ជាដើម។

រាល់បទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងកំឡុងវិបត្តអ៊ុយក្រែនត្រូវតែស៊ើបអង្កេតប្រកបដោយយុត្តិធម៌ និង ប្រសិទ្ធិភាព។ ករណីនេះ រួមបញ្ចូលយ៉ាងពិសេសករណីសម្លាប់អ្នកសារព័ត៌មានរុស្ស៊ី ករណីបាញ់កាំភ្លើងស្នៃបភីនៅគៀវ សោកនាដកម្មនៅអូដេសា ទីដែលប្រជាជនត្រូវបានគេដុតសម្លាប់ទាំងរស់ ក្នុងអគារសហជីពពាណិជ្ជកម្ម ការបាញ់សម្លាប់ជនស៊ីវិលនៅម៉ារីប៉ូល  ការធ្លាក់យន្តហោះម៉ាឡេស៊ី ការសម្លាប់រង្គាលនៅក្នុងរណ្តៅរួមក្នុងភូមិភាគដូញៀតស្ក៏ និង ឡូហានស្ក៏ដែលជាភស្តុតាងនៃការសម្លាប់ទ្រង់ទ្រាយធំ  ការស្លាប់របស់កុមារក្រោមការបាញ់ផ្តក់កាំភ្លើងធំ ការប្រើប្រាស់កម្លាំងច្រើនហួសហេតុ ការប្រើប្រាស់អាវុធហាមប្រាម រួមមានគ្រាប់បែកចង្កោម អាវុធមានសារធាតុផូស្វ័រ មីស៊ីលបាលីស្ទីក ជាដើម។វាជាការសំខាន់ណាស់ដែលអាជ្ញាធរអ៊ុយក្រែនបញ្ឈប់នូវការជំទាស់មិនអោយធ្វើការអង្កេតដោយឯករាជ្យតម្លាភាព និង ប្រសិទ្ធិភាពចំពោះករណីដែលបានរៀបរាប់ខាងលើ។យើងអំពាវនាវអោយប្រព័ន្ធ

ផ្សព្វផ្សាយអន្តរជាតិ អង្គការសិទ្ធិមនុស្សអន្តរជាតិ ក្រុមប្រឹក្សាអឺរ៉ុប និង OSCEអង្គការក្រៅរដ្ឋាភិបាល ចូលរួមយ៉ាងសកម្ម ប្រកបដោយយុត្តិធម៌ មិនប្រើប្រាស់ក្នុងន័យនយោបាយក្នុងការអង្កេតលើមូលហេតុ នៃវិបត្តិអ៊ុយក្រែន និង ការវិវត្តន៍របស់វា។ យើងជឿជាក់ថា ការគេចវេសពីការពិតការប៉នប៉ងលាក់បាំង ពីសហគមន៍អន្តរជាតិគឺជាវិធីមិនមានភាពស្មោះត្រង់ និង ប្រកបដោយក្តីអស់សង្ឃឹម។